សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Sciences Economiques**

**Royal University of law and Economics**

## សារណាបញ្ចប់ការសិក្សា

# យន្តការនៃការបកស្រាយច្បាប់ របស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: លោក **ឡឿន ម៉េងហេង**

លោក **ឆេង តារុន**

សាស្ត្រាចារ្យណែនាំ

លោក **តា សុទ្ធា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំ ឈ្មោះ **ឡើន ម៉េងហេង** និង **ឆេង តារុន** ជានិស្សិតឆ្នាំទី៤ មហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២០-២០២១ ជំនាន់ទី២១។

**សូមលំអោនកាយក្រាបប្រណិប័តន៍ និងសម្តែងនូវកតញ្ញូតាធម៌ និងកតវេទិតាយ៉ាងខ្ពង់ខ្ពស់ចំពោះជីដូន ជីតា ក្រុមគ្រួសារ ជាពិសេសមាតាបិតា៖**

**លោក សោ សាឡើន　　　　លោក អ៊ុន រ៉ុន**

**លោកស្រី មាន លីណា　　　លោកស្រី ឡេង សាមាត**

ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ ថែរក្សា និងទូន្មានប្រៀនប្រដៅ ប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងបានលើកទឹកចិត្តផ្នែកស្មារតី និងគាំទ្រផ្នែកធនធានដែលជាហេតុធ្វើឲ្យយើងខ្ញុំបាទ បានបន្តការសិក្សាគ្រប់ភូមិសិក្សារហូតមកដល់ឆ្នាំទី៤ នៃថ្នាក់បរិញ្ញាបត្រនេះប្រកបដោយភាពជោគជ័យ។

**សូមគោរពថ្លែងអំណរគុណផងដែរចំពោះ៖**

- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងជាបិតាស្ថាបនិកសន្តិភាព ដែលលោកបានខិតខំព្យាយាមក្នុងការដឹកនាំនាវាកម្ពុជា អភិវឌ្ឍប្រទេសជាតិតាមរយៈនយោបាយឈ្នះ ឈ្នះ កសាងស្ថិរភាពនយោបាយ សន្តិសុខសង្គម និងធ្វើពិពិធកម្មសេដ្ឋកិច្ចជាតិឲ្យមានភាពរីកចម្រើន ព្រមទាំងត្រូវបានទទួលស្គាល់លើឆាកអន្តរជាតិទាំងថ្នាក់តំបន់ និងថ្នាក់សកល។
- **ឯកឧត្តមសាកលវិទ្យាធិការ** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ គណៈគ្រប់គ្រងសាកលវិទ្យាល័យ និងមន្ត្រីគ្រប់ផ្នែកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំក្នុងការដឹកនាំ គ្រប់គ្រង បង្ហាត់បង្រៀន និងសម្របសម្រួល ណែនាំដល់យើងខ្ញុំឲ្យទទួលបានចំណេះដឹង បទពិសោធន៍យ៉ាងច្រើនអនេកទាំងក្នុងវិស័យនីតិសាស្ត្រ និងវិស័យយុត្តិធម៌។
- លោកសាស្ត្រាចារ្យ **តា សុទ្ធា** ជាសាស្ត្រាចារ្យណែនាំ ដែលលោកបានចំណាយពេលវេលាផ្ទាល់ខ្លួនដ៏មានតម្លៃរបស់លោក ក្នុងការបង្ហាត់បង្ហាញ ណែនាំ ផ្តល់គំនិត និងដំបូន្មានល្អៗពាក់ព័ន្ធនឹងប្រធានបទ ជាពិសេសលោកបានចូលរួមកែសម្រួល និងត្រួតពិនិត្យ ព្រមទាំងលើកទឹកចិត្តដល់យើងខ្ញុំ ក្នុងការស្រាវជ្រាវ និងតាក់តែងសារណាបញ្ចប់ការសិក្សាមួយនេះឡើង។
- លោក **ស៊ុន វ៉ាន់ឌី** ជាមិត្តនិស្សិតរួមក្រុម និងរួមជំនាន់ ដែលបានជួយរៀបចំ សម្រិតសម្រាំងផ្នែកបច្ចេកទេស និងរចនាបទនានាក្នុងសារណាបញ្ចប់ការសិក្សាមួយនេះ ដើម្បីញ៉ាំងឲ្យស្នាដៃកាន់តែមានសោភណ្ឌភាព និងសមស្របទៅតាមលក្ខណៈស្តង់ដារដែលសាកលវិទ្យាល័យបានកំណត់។

ជាទីបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធិពរជ័យ ដល់មាតាបិតា ជីដូនជីតា ក្រុមគ្រួសារ អាណាព្យាបាល ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ គណៈគ្រប់គ្រងសាកលវិទ្យាល័យ និងមន្ត្រីគ្រប់ផ្នែកទាំងអស់ ឲ្យជួបតែពុទ្ធពរទាំងបួនប្រការពោលគឺៈ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ការសិក្សាជំនាញនីតិសាស្ត្រអស់រយៈពេល ៤ ឆ្នាំមកនេះ ជាវឌ្ឍនភាពថ្មីមួយនៅលើវិថីនៃជីវិតសិក្សារបស់យើងខ្ញុំ។ ដោយមានការកំណត់ចក្ខុវិស័យ ការខិតខំប្រឹងប្រែងព្យាយាមរៀនសូត្រ ប្រកបដោយភាពអត់ធ្មត់ ស្មារតីយកចិត្តទុកដាក់ និងការទទួលខុសត្រូវខ្ពស់ ព្រមទាំងទទួលបានការលើកទឹកចិត្ត ការផ្តល់ចំណេះដឹង ការចែករំលែកបទពិសោធន៍ និងដំបូន្មានល្អៗពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យ បានធ្វើឲ្យយើងខ្ញុំទាំងពីររូបទទួលបានកាលានុវត្តភាព ព្រមទាំងការអនុញ្ញាត ពីសាកលវិទ្យាល័យ ក្នុងការសរសេរសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ **យន្តការនៃការបកស្រាយច្បាប់របស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា។**

សារណាបញ្ចប់ការសិក្សានេះ នឹងក្លាយទៅជាស្នាដៃថ្មីមួយ ដែលអាចជួយដល់អ្នកស្រាវជ្រាវ មិត្តនិស្សិត មិត្តអ្នកអាន ប្អូនៗនិស្សិតជំនាន់ក្រោយ មកពីគ្រប់មជ្ឈដ្ឋានទាំងអស់ ដើម្បីជាប្រទីបក្នុងការសិក្សាស្វែងយល់បន្ថែមពី យន្តការនានាស្តីពីការបកស្រាយច្បាប់របស់ក្រុមប្រឹក្សាធម្មនុញ្ញឲ្យកាន់តែពិស្តារជាងមុន។ ជាពិសេស ប្រធានបទ និងខ្លឹមសារនៃសារណានេះ ត្រូវបានតាក់តែងឡើងដោយផ្អែកទៅលើច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយរបស់កម្ពុជា ព្រមទាំងសៀវភៅ ឯកសារចងក្រង ជាច្រើនទៀតរបស់អ្នកជំនាញ និងសាស្ត្រាចារ្យល្បីៗជំនាញនីតិសាស្ត្រនៅកម្ពុជា។ ម៉្យាងវិញទៀត សារណានេះ អាចលេចចេញជារូបរាងបាន ដោយសារមានការជួយជ្រោមជ្រែង ជម្រុញ និងគាំទ្រពីលោកសាស្ត្រាចារ្យ **តា សុទ្ធា** ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការដឹកនាំ ផ្តល់អនុសាសន៍ល្អៗ និងត្រួតពិនិត្យ ក្នុងគោលដៅញ៉ាំងឲ្យសារណាបញ្ចប់ការសិក្សានេះមានលក្ខណៈល្អប្រសើរទាំងផ្នែកអក្ខរាវិរុទ្ធ និងផ្នែកអត្ថន័យ ប្រកបដោយសុក្រឹត្យភាព និងការវាយតម្លៃខ្ពស់។

ជាការពិតណាស់ សារណាបញ្ចប់ការសិក្សានេះ ប្រាកដជាមានលេចឡើងចំណុចខ្វះខាតមួយចំនួនជាក់ជាពុំខាន។ អាស្រ័យហេតុនេះ យើងខ្ញុំសូមធ្វើការអភ័យទោសទុកជាមុនពីសំណាក់លោក លោកស្រី សាស្ត្រាចារ្យ មិត្តអ្នកអាន អ្នកស្រាវជ្រាវនានាក្នុងករណីដែលនៅក្នុងស្នាដៃនេះ មានកំហុសខុសឆ្គងត្រង់ប្រការណាមួយទាំងខ្លឹមសារ និងអក្ខរាវិរុទ្ធ រួមទាំងចំណុចលើសលស់ ឬខ្វះខាត ឬខ្លឹមសារមិនពិស្តារនៅត្រង់ចំណុចណាមួយដែលបានលេចឡើងដោយអចេតនា។

ជាទីបញ្ចប់ យើងខ្ញុំពិតជាសេចក្តីសោមនស្សរីករាយ ក្នុងការទទួលយករាល់មតិរិះគន់ ការទិតៀននានាក្នុងន័យស្ថាបនាពីគ្រប់មជ្ឈដ្ឋានជុំវិញ ដើម្បីជាការកែលម្អរាល់កំហុសឆ្គង ចំណុចខ្វះខាត ក៏ដូចជាចូលរួមអភិវឌ្ឍសមត្ថភាពចំណេះដឹងឲ្យមានលក្ខណៈប្រសើរជាងមុន ព្រមទាំងធ្វើឲ្យសារណានេះកាន់តែមានលក្ខណៈត្រឹមត្រូវ និងមានភាពសុក្រឹត្យឡើងថែមមួយកម្រិតទៀត។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........................................ ១

## ជំពូកទី១

## សញ្ញាណទូទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

**ផ្នែកទី១៖ សារៈសំខាន់នៃការបង្កើតក្រុមប្រឹក្សាធម្មនុញ្ញ** ........................................ ៥

១.១. ស្ថានភាពគតិយុត្តនៃក្រុមប្រឹក្សាធម្មនុញ្ញ ឬតុលាការធម្មនុញ្ញក្នុងបរិការណ៍សកលលោក ........................................ ៥

១.២. ការវិវត្តរបស់ក្រុមប្រឹក្សាធម្មនុញ្ញក្នុងបរិបទកម្ពុជា ........................................ ៧

១.៣. បុព្វហេតុនៃការកកើតស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៨ ........................................ ៨

**ផ្នែកទី២៖ ការរៀបចំ និងដំណើរការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ** ........................................ ៩

២.១. ការរៀបចំនៃក្រុមប្រឹក្សាធម្មនុញ្ញ ........................................ ៩

២.១.១. ការតែងតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញដោយព្រះមហាក្សត្រ ........................................ ១០

២.១.២. ការជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញដោយរដ្ឋសភា ........................................ ១០

២.១.៣. ការតែងតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ........................................ ១១

២.២. ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ........................................ ១២

២.២.១. ការចូលកាន់តំណែង ........................................ ១៣

២.២.២. ការលាឈប់ និងការដកចេញពីតំណែងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ........................................ ១៣

២.២.៣. ការតែងតាំង ឬជ្រើសតាំងថ្មី ឬជំនួស ........................................ ១៤

**ផ្នែកទី៣៖ លក្ខណៈពិសេសរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ** ........................................ ១៥

៣.១. អភ័យឯកសិទ្ធិ ........................................ ១៥

៣.២. វិសមិតភាព ........................................ ១៥

៣.៣. វិន័យ និងចរិយាសម្បត្តិនៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ........................................ ១៦

៣.៤. ការឈប់សម្រាក និងការអនុញ្ញាតច្បាប់ឈប់ ........................................ ១៨

## ជំពូកទី២

## សមត្ថកិច្ចក្នុងការបកស្រាយរដ្ឋធម្មនុញ្ញ ច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និង ព្រឹទ្ធសភា

**ផ្នែកទី១៖ អង្គភាពជាសេនាធិការរៀបចំក្នុងការបកស្រាយ** ........................................ ២០

១.១. អគ្គលេខាធិការដ្ឋាន ........ ២០
១.២. នាយកដ្ឋានសេវាច្បាប់ និងវិវាទកម្ម ........ ២១
**ផ្នែកទី២៖ លក្ខខណ្ឌ និងគោលការណ៍ជាមូលដ្ឋាននៃការបកស្រាយ** ........ ២២
២.១. លក្ខខណ្ឌនៃការស្នើសុំបកស្រាយ ........ ២២
២.១.១. សមត្ថភាពបុគ្គលដែលមានសិទ្ធិស្នើសុំ ........ ២២
២.១.២. ការពិនិត្យលើទម្រង់ ឬបែបបទ ........ ២៤
២.១.៣. គោលបំណងនៃសំណើសុំបកស្រាយ ........ ២៤
២.២. គោលការណ៍វិនិច្ឆ័យជាសារវន្តនៃការបកស្រាយ ........ ២៥
២.២.១. គោលការណ៍ឆន្ទៈរបស់សភាធម្មនុញ្ញ ........ ២៦
២.២.២. គោលការណ៍មូលហេតុនៃច្បាប់ ........ ២៧
២.២.៣. គោលការណ៍ទ្រឹស្តី និងស្មារតីនៃច្បាប់ ........ ២៧
២.២.៣.១. គោលការណ៍អនុលោមភាព ឬស្រប ........ ២៨
២.២.៣.២. គោលការណ៍បដិលោមភាព ឬផ្ទុយ ........ ៣០
២.២.៣.៣. គោលការណ៍ប្រៀបធៀប ........ ៣២
២.២.៣.៤. គោលការណ៍ពាក្យពេចន៍ក្នុងអត្ថបទច្បាប់ ........ ៣៣
២.២.៣.៥. គោលការណ៍ចេតនារបស់អ្នកតាក់តែងច្បាប់ ........ ៣៤
**ផ្នែកទី៣៖ នីតិវិធីដែលត្រូវអនុវត្តនៅក្នុងការបកស្រាយ** ........ ៣៦
៣.១. ការចុះបញ្ជីនៅអគ្គលេខាធិការដ្ឋាន ........ ៣៦
៣.២. ការបែងចែកក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ ........ ៣៦
៣.៣. ការចេញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ........ ៣៧

## ជំពូកទី៣

## សមិទ្ធផលសំខាន់ៗរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

**ផ្នែកទី១៖ សមិទ្ធផលទាក់ទងនឹងការបកស្រាយច្បាប់** ........ ៤០
១.១. ការបកស្រាយរដ្ឋធម្មនុញ្ញ ........ ៤០
១.២. ការបកស្រាយច្បាប់ ........ ៤១
**ផ្នែកទី២៖ សមិទ្ធផលពាក់ព័ន្ធនឹងការត្រួតពិនិត្យធម្មនុញ្ញភាព** ........ ៤២
២.១. ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការ ........ ៤២
២.២. ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ធម្មតា ........ ៤៤

២.៣. ការត្រួតពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងព្រឹទ្ធសភា ........................................ ៤៦
**ផ្នែកទី៣៖ សមិទ្ធផលដែលជាបច្ច័យនៃការដោះស្រាយវិវាទបោះឆ្នោត** ........................ ៤៧
៣.១. ការដោះស្រាយបណ្ដឹងតវ៉ានឹងសេចក្ដីសម្រេចរបស់គ.ជ.ប ................................................... ៤៨
៣.២. ការដោះស្រាយបណ្ដឹងតវ៉ានឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត .................................. ៥០
៣.៣. ការដោះស្រាយបណ្ដឹងទាមទារឲ្យលុបឈ្មោះអ្នកបោះឆ្នោតចេញពីបញ្ជីបោះឆ្នោត ...................... ៥២
**សេចក្ដីសន្និដ្ឋាន** ........................................................................................................ ៥៥
**អនុសាសន៍** ............................................................................................................... ៥៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នីតិរដ្ឋ និងការបែងចែកអំណាច គឺដើរតួនាទីយ៉ាងស្និតរមួតជាមួយនឹងលទ្ធិប្រជាធិបតេយ្យសេរី ដែលត្រូវបានប្រទេសជាច្រើននៅលើសកលលោកនាពេលបច្ចុប្បន្ននេះ បាននឹងកំពុងប្រកាន់យកមកអនុវត្ត។ នៅក្នុងបរិការណ៍បែបនេះ ភាគច្រើននៃបណ្តាប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យសេរីតាមប្រព័ន្ធច្បាប់អង់គ្លូសាក់សុង និងប្រព័ន្ធច្បាប់រ៉ូម៉ាំង បានបង្កើតឲ្យមានស្ថាប័នកំពូលមួយដែលស្ថិតនៅចន្លោះអំណាចរដ្ឋរបស់ពួកគេ ពោលគឺជា ស្ថាប័នឯករាជ្យ អព្យាក្រឹត្យ មិនស្ថិតនៅក្រោមឥទ្ធិពលនយោបាយរបស់អំណាចណាមួយដែលគេប្រសិទ្ធនាមឲ្យថា តុលាការធម្មនុញ្ញ ឬក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចក្នុងការត្រួតពិនិត្យធម្មនុញ្ញភាព និងបកស្រាយច្បាប់នានា ព្រមទាំងសមត្ថកិច្ចដទៃទៀតអាស្រ័យទៅតាមរដ្ឋធម្មនុញ្ញនៃរដ្ឋនីមួយៗ។ ចំណែកឯប្រទេសមួយចំនួនដូចជាៈ នៅសហរដ្ឋអាមេរិក កាណាដា ន័រវេស ឥណ្ឌា ជាដើម ពុំបានបង្កើតឲ្យមានស្ថាប័នដាច់ដោយឡែកនោះទេ ដោយបានធ្វើការប្រគល់សមត្ថកិច្ចនេះទៅកាន់តុលាការកំពូលជាអ្នកទទួលបន្ទុក។

យ៉ាងណាមិញ បើយើងក្រឡេកមកសិក្សាពីប្រទេសកម្ពុជាវិញ យើងអាចកត់សម្គាល់ឃើញថាកម្ពុជាជារដ្ឋមួយដែលមានរដ្ឋធម្មនុញ្ញ និងច្បាប់ផងដែរ ប៉ុន្តែប្រទេសដែលមានទីតាំងស្ថិតក្នុងភូមិភាគអាស៊ីអាគ្នេយ៍មួយនេះ បានឆ្លងកាត់ភ្នក់ភ្លើងសង្គ្រាមយ៉ាងសន្ធោសន្ធៅជាច្រើនអស់រយៈពេលជាច្រើនទសវត្ស ជាពិសេសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានរុញច្រាននាវាកម្ពុជាឲ្យធ្លាក់ក្នុងរណ្តៅនៃភាពខ្មៅងងឹត និងភាពអន្តរាយជាទីបំផុតទៅលើគ្រប់វិស័យទាំងអស់។ ទោះបីជាយ៉ាងណាក៏ដោយ ក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ កម្ពុជាបានរស់រានជាលើកទី២ ហើយក៏បានបន្តកសាង និងអភិវឌ្ឍប្រទេសឡើងវិញ ដោយផ្តោតយកវិស័យច្បាប់ជាអាទិភាពផងដែរ ក្នុងចំណោមវិស័យសំខាន់ៗដទៃទៀត។ ការកសាងប្រទេសជាតិឡើងវិញ គឺជាការលំបាកមួយហើយ ទន្ទឹមនឹងនេះប្រទេសកម្ពុជា ត្រូវស្វែងរកសន្តិភាព និងស្ថិរភាពមួយដ៏ពិតប្រាកដ។ ហេតុនេះហើយ ទើបជាកត្តាបណ្តាលឲ្យមានកិច្ចព្រមព្រៀងនៅទីក្រុងប៉ារីសមួយត្រូវបានបង្កើតឡើង ស្តីពីដំណោះស្រាយនយោបាយនៅកម្ពុជានាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដោយមានការចូលរួមពីភាគីជម្លោះខ្មែរចតុភាគី។ បន្ទាប់មកប្រទេសកម្ពុជា បានរៀបចំការបោះឆ្នោតជាសកលមួយដើម្បីបង្កើតសភាធម្មនុញ្ញ ដែលមានសមត្ថកិច្ចរៀបចំ តាក់តែង និងអនុម័តរដ្ឋធម្មនុញ្ញ។ តួយ៉ាង ព្រះរាជាណាចក្រកម្ពុជាទី២ ត្រូវបានប្រកាសឡើង ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បន្ទាប់ពីសភាធម្មនុញ្ញបានអនុម័តនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៣ និងក្រោយពេលដែលព្រះមហាក្សត្រ ទ្រង់បានឡាយព្រះហស្តលេខាប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ គឺជាវឌ្ឍនភាពថ្មីមួយនៃវិស័យច្បាប់នៅក្នុងប្រទេសកម្ពុជា និងជាសមិទ្ធផលដ៏មានតម្លៃឥតគណនាសម្រាប់ប្រជាជាតិកម្ពុជាទាំងមូល។ ម៉្យាងវិញទៀត នៅក្នុងរដ្ឋធម្មនុញ្ញនេះ ពុំមានចែងអំពីស្ថាប័នឯករាជ្យណាមួយដែលស្ថិតនៅចន្លោះអំណាចទាំងបី និងមានសមត្ថកិច្ចត្រួតពិនិត្យធម្មនុញ្ញភាព បកស្រាយច្បាប់ ព្រមទាំងដោះស្រាយវិវាទកម្មទាក់ទងនឹងការបោះឆ្នោតឡើយ។ មានបញ្ហាជាច្រើនត្រូវបានចោទឡើង ដោយហេតុ

ថាប្រទេសកម្ពុជាទើបតែមានរដ្ឋធម្មនុញ្ញថ្មីមួយដែលប្រកាន់យកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ហើយវិស័យច្បាប់នៅមិនទាន់មានភាពរីកចម្រើនគួរឲ្យកត់សម្គាល់នៅឡើយ។ បញ្ហាទាំងនោះមានដូចជាៈការបកស្រាយច្បាប់នៅមិនទាន់មានភាពផ្លូវការណាមួយដែលអាចទទួលយកបាន ពីព្រោះមានការពន្យល់ខុសប្លែកគ្នាទៅតាមទស្សនៈរៀងៗខ្លួន ដែលជាបច្ច័យនាំឲ្យបាត់បង់ប្រសិទ្ធភាពអនុវត្តន៍។ លើសពីនេះទៅទៀត ច្បាប់ និងសេចក្តីសម្រេចនៃស្ថាប័នរដ្ឋនានាដែលបានតាក់តែងឡើងមកមានចំនួនច្រើនអនេក ហើយគេពុំឃើញមានស្ថាប័នជាក់លាក់ណាមួយមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យទៅលើបទប្បញ្ញត្តិទាំងនោះឲ្យមានភាពច្បាស់លាស់ ត្រឹមត្រូវ យុត្តិធម៌ និងអព្យាក្រឹត្យឡើយ ដែលជាកត្តានាំឲ្យបាត់បង់សណ្តាប់ធ្នាប់គតិយុត្ត និងប្រៀបបីដូចជាបង្អាក់នូវដំណើរការកសាងនីតិរដ្ឋ។ មួយវិញទៀត វិវាទជុំវិញការបោះឆ្នោតនៅតែបន្តកើតមានឡើង ដោយគេសង្កេតឃើញថាពុំមានស្ថាប័នណាមួយមានសមត្ថកិច្ចជាក់លាក់ សម្រាប់ដោះស្រាយ និងចេញសេចក្តីសម្រេច ដែលការណ៍នេះ បានបង្កជាផលប៉ះពាល់ និងជះឥទ្ធិពលដល់ដំណើរការនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា។

ជាការឆ្លើយតបទៅនឹងបញ្ហាទាំងនេះ ក្រោយពេលដែលរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រូវបានធ្វើវិសោធនកម្មព្រះរាជាណាចក្រកម្ពុជាតាមរយៈច្បាប់កំពូលរបស់ជាតិ បានបង្កើតឲ្យមានស្ថាប័នមួយឡើងគឺ ក្រុមប្រឹក្សាធម្មនុញ្ញដែលមានសមត្ថកិច្ចធានាការពារ ការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័តនិងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ព្រមទាំងមានសិទ្ធិពិនិត្យ ហើយសម្រេចអំពីករណីវិវាទកម្ម ទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ ម្យ៉ាងវិញទៀត អង្គការនេះក៏មានសមត្ថកិច្ចពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ាការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃប្រកាសមោឃភាពរាល់ការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យអធិបតេយ្យភាព បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឲ្យប៉ះពាល់ដល់ឯកភាពនយោបាយឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ ជាពិសេសផ្តល់មតិថ្វាយព្រះមហាក្សត្រ នៅពេលដែលទ្រង់ពិគ្រោះយោបល់ជុំវិញសេចក្តីស្នើទាំងឡាយ ដែលស្នើសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ។

ដោយមើលឃើញពីសារៈសំខាន់នៃស្ថាប័ននេះ យើងខ្ញុំបានជ្រើសរើសយកប្រធានបទមួយដោយនឹងធ្វើការលើកយកមួយផ្នែកនៃសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ពោលគឺ យន្តការនៃការបកស្រាយច្បាប់របស់ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញមកធ្វើការបកស្រាយ និងអធិប្បាយដើម្បីជាប្រទីបបំភ្លឺដល់ចម្ងល់របស់អ្នកសិក្សា និងប្រជាពលរដ្ឋទូទៅជុំវិញថា តើក្រុមប្រឹក្សាធម្មនុញ្ញប្រកាន់យករបៀបរបប និងបែបផែនយ៉ាងណាដើម្បីបកស្រាយច្បាប់។ តើក្រុមប្រឹក្សាធម្មនុញ្ញ ទទួលយកសំណើបកស្រាយច្បាប់ដោយផ្អែកទៅលើលក្ខខណ្ឌអ្វីខ្លះ និងឈរលើគោលការណ៍យ៉ាងណាខ្លះសម្រាប់ធ្វើការបកស្រាយ និងពន្យល់ ព្រមទាំងនីតិវិធីអនុវត្តន៍យ៉ាងដូចម្តេចផងដែរ មុននឹងឈានទៅដល់ការចេញសេចក្តីសម្រេចបិទផ្លូវតវ៉ា? ជាពិសេសតើក្រុមប្រឹក្សាធម្មនុញ្ញ បានចូលរួមចំណែកយ៉ាង

ដូចម្តេចខ្លះក្នុងដំណើរការកសាងនីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យសេរី ព្រមទាំងបានសម្រេចសមិទ្ធផលធំៗអ្វីខ្លះ គិតចាប់តាំងពីពេលបង្កើតឡើង រហូតមកដល់ពេលបច្ចុប្បន្ន?

ដូច្នេះ យើងខ្ញុំនឹងលើកយកចំណុចជាសារវន្តមួយចំនួន មកធ្វើការបង្ហាញ និងអធិប្បាយនៅក្នុងសារណាបញ្ចប់ការសិក្សាមួយនេះ ដែលមានដូចខាងក្រោម៖

- **ជំពូកទី១៖ សញ្ញាណទូទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ**
- **ជំពូកទី២៖ សមត្ថកិច្ចក្នុងការបកស្រាយរដ្ឋធម្មនុញ្ញ ច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងព្រឹទ្ធសភា និង**
- **ជំពូកទី៣៖ សមិទ្ធផលសំខាន់ៗ របស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។**

# ជំពូកទី១
# សញ្ញាណទូទៅ
# នៃ
# ក្រុមប្រឹក្សាធម្មនុញ្ញ

# ជំពូកទី១
# សញ្ញាណទូទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

បន្ទាប់ពីមានកិច្ចព្រមព្រៀងមួយនៅទីក្រុងប៉ារីសនាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ រួចមក ប្រទេសកម្ពុជាបានចាប់ផ្តើមរៀបចំការបោះឆ្នោតជាសកលមួយជាផ្លូវការនៅថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៣ ក្រោមការជួយជ្រោមជ្រែងពីអាជ្ញាធរបណ្ដោះអាសន្ននៃអង្គការសហប្រជាជាតិ ដើម្បីបង្កើតសភាធម្មនុញ្ញស្របច្បាប់មួយដែលមានសមត្ថកិច្ចក្នុងការតាក់តែងរដ្ឋធម្មនុញ្ញថ្មីសម្រាប់ប្រជាជាតិកម្ពុជា។ ជាសមិទ្ធផលដ៏ធំធេង រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ត្រូវបានចាប់បដិសន្ធិឡើង និងអនុម័តដោយសភាធម្មនុញ្ញនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ព្រមទាំងត្រូវបានប្រកាសឲ្យប្រើប្រាស់ជាផ្លូវការដោយព្រះមហាក្សត្រ តាមរយៈព្រះរាជក្រមចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

តាមស្មារតីនៃរដ្ឋធម្មនុញ្ញ អំណាចរដ្ឋត្រូវបានបែងចែកជា៣ គឺៈ អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ អំណាចនីតិប្បញ្ញត្តិ ត្រូវបានប្រគល់ជូនស្ថាប័នចំនួន២គឺៈ រដ្ឋសភា និងព្រឹទ្ធសភា សម្រាប់ការតាក់តែង និងអនុម័តច្បាប់។ ចំណែកឯអំណាចនីតិប្រតិបត្តិ ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ដែលរួមមានៈ ក្រសួង ស្ថាប័នរដ្ឋ អង្គភាពសាធារណៈ រដ្ឋលេខាធិការដ្ឋាន និងអង្គភាពនានាចំណុះរាជរដ្ឋាភិបាល ជាសេនាធិការសម្រាប់ធ្វើការអនុវត្ត និងប្រតិបត្តិច្បាប់ ព្រមទាំងកម្មវិធីគោលនយោបាយជាតិ។ ដោយឡែក អំណាចតុលាការ ត្រូវបានប្រគល់ឲ្យទៅតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងគ្រប់ផ្នែក។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីធានាដំណើរការនៃលទ្ធិប្រជាធិបតេយ្យសេរី និងការកសាងនីតិរដ្ឋមួយប្រកបដោយប្រសិទ្ធភាព ការធ្វើការត្រួតពិនិត្យទៅលើច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ ថាតើវាស្របតាមគោលការណ៍ និងខ្លឹមសារនៃរដ្ឋធម្មនុញ្ញដែរឬទេ ជាចំណុចមួយមានសារៈសំខាន់បំផុតក្នុងគោលដៅរក្សាសុវត្ថិភាព និងសណ្ដាប់ធ្នាប់គតិយុត្តឲ្យមានសុក្រឹត្យភាពឡើង។ លើសពីនេះទៅទៀត ការបកស្រាយច្បាប់ និងការដោះស្រាយវិវាទកម្មនានាពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភា ទាមទារឲ្យមានស្ថាប័នដែលមានសមត្ថកិច្ចជាក់លាក់មួយសម្រាប់ទទួលបន្ទុកផងដែរ។

អាស្រ័យហេតុនេះហើយ ទើបស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានបង្កើតឡើង ហើយមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ក្នុងនាមជាស្ថាប័នកំពូលមួយដែលមានភាពឯករាជ្យ និងភាពអព្យាក្រឹត្យ។[1]ច្បាប់រៀបចំអង្គការមួយនឹងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។[2]

[1] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ ជស/រកម/០៤៩៨/០៦, ០៨ មេសា ១៩៩៨, មាត្រា២ វាក្យខណ្ឌទី១។

[2] មាត្រា១៤៥ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

## ផ្នែកទី១៖ សាវតានៃការបង្កើតក្រុមប្រឹក្សាធម្មនុញ្ញ

ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានប្រសូតឡើង និងបានវិវត្តខ្លួនជាយូរណាស់មកហើយនៅតាមបណ្ដាប្រទេសមួយចំនួននៅលើពិភពលោក មុននឹងមានអត្ថិភាពនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះ យើងនឹងសិក្សាអំពីស្ថានភាពគតិយុត្តនៃក្រុមប្រឹក្សាធម្មនុញ្ញ ឬតុលាការធម្មនុញ្ញក្នុងបរិការណ៍សកលលោក(១.១) ការវិវត្តរបស់ក្រុមប្រឹក្សាធម្មនុញ្ញក្នុងបរិបទកម្ពុជា(១.២) និងបុព្វហេតុនៃការកើតស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៨(១.៣)។

### ១.១. ស្ថានភាពគតិយុត្តនៃក្រុមប្រឹក្សាធម្មនុញ្ញ ឬតុលាការធម្មនុញ្ញក្នុងបរិការណ៍សកលលោក

ការបង្កើតក្រុមប្រឹក្សាធម្មនុញ្ញ ឬតុលាការធម្មនុញ្ញនៅតាមបណ្ដាប្រទេសនានា គឺអាស្រ័យទៅលើបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញរបស់រដ្ឋសាមី ដែលជាវិធានគ្រឹះមួយសម្រាប់ឈានទៅដល់ការរៀបចំ និងការប្រព្រឹត្តទៅព្រមទាំងការកំណត់សមត្ថកិច្ចជាក់លាក់នៃស្ថាប័ននោះ។ ចំណែកឯសមត្ថកិច្ចរបស់ស្ថាប័ននេះ ក៏មានភាពខុសប្លែកគ្នាមួយចំនួនផងដែរ ប៉ុន្តែគេបានពិនិត្យឃើញចំណុចរួមមួយគឺ ការត្រួតពិនិត្យធម្មនុញ្ញភាពរបស់ច្បាប់ ដែលស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ ឬតុលាការធម្មនុញ្ញស្ទើរតែទាំងស្រុង នៅតាមបណ្តាប្រទេសនីមួយៗ សុទ្ធតែបានធ្វើការកំណត់យកជាកិច្ចការអាទិភាព ឬការងារស្នូល។ ជាងនេះទៅទៀត ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ អាចត្រូវបានធ្វើឡើងក្នុងទម្រង់ពីរយ៉ាងគឺៈ អង្គការដាច់ដោយឡែក ឬអង្គការពិសេស និងអង្គការទូទៅ ឬតុលាការធម្មតា ដោយផ្អែកទៅលើច្បាប់ជាតិនៃរដ្ឋនីមួយៗ។[3]

- **ការត្រួតពិនិត្យដោយអង្គការដាច់ដោយឡែក ឬអង្គការពិសេស**

ការត្រួតពិនិត្យដោយអង្គការពិសេស គឺជាការត្រួតពិនិត្យដោយអង្គការដាច់ដោយឡែកមួយ ខុសពីតុលាការធម្មតា ដោយអង្គការនេះ មានភារកិច្ចទទួលខុសត្រូវក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពរបស់ច្បាប់នៅក្នុងប្រទេស។ ប្រទេសអាឡឺម៉ង់ ប្រទេសអតីតយូហ្គោស្លាវី សាធារណរដ្ឋឆេក ប្រទេសអេស្ប៉ាញ បានបង្កើតស្ថាប័នតុលាការធម្មនុញ្ញដើម្បីដើរតួនាទីជាអ្នកត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់។ ចំណែកឯប្រទេសបារាំង និងប្រទេសកម្ពុជាវិញ បានបង្កើតក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានសមត្ថកិច្ចចម្បងដូចគ្នាទៅនឹងតុលាការធម្មនុញ្ញផងដែរ ប៉ុន្តែគ្រាន់តែមានការប្រើប្រាស់ឈ្មោះរបស់ស្ថាប័នខុសគ្នាប៉ុណ្ណោះ។ ស្ថាប័ននេះ មានចរិតលក្ខណៈនយោបាយតិច ឬច្រើន អាស្រ័យទៅតាមរដ្ឋនីមួយៗ និងជាពិសេស ដោយផ្អែកទៅលើការវាយតម្លៃចំពោះលក្ខណៈវិនិច្ឆ័យចំនួន៣គឺ[4]៖

[3] ម៉ែន វុធ, *នីតិរដ្ឋធម្មនុញ្ញ និងស្ថាប័ននយោបាយ*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ ២០២០), ៣១។

[4] សុខ ចិន្តា និងសុខ យ៉ាន, *នីតិរដ្ឋធម្មនុញ្ញ*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ Good News Printing House, ២០១៨), ៥១។

- **ការតែងតាំងសមាជិកៈ** ចរិតនយោបាយរបស់ស្ថាប័ននេះ លេចឡើងនៅពេលដែលគ្រប់សមាជិកនៃអង្គការនេះ ត្រូវបានជ្រើសតាំងដោយអាជ្ញាធរនយោបាយដូចជាៈ នៅក្នុងករណីប្រទេសបារាំង ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញបារាំង មានសមាជិកចំនួន៩រូប ដែលមានអាណត្តិ៩ឆ្នាំ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួន១ភាគ ៣ នៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល ត្រូវផ្លាស់ប្តូរជាវៀងរាល់៣ឆ្នាំម្តងយ៉ាងទៀងទាត់។ សមាជិក ៣ រូប ត្រូវតែងតាំងដោយប្រធានាធិបតីនៃសាធារណរដ្ឋ ៣រូប តែងតាំងដោយប្រធានសភាជាតិ និង៣រូបទៀត ត្រូវបានតែងតាំងដោយប្រធានព្រឹទ្ធសភា។[5] យ៉ាងណាមិញ សមាជិកតុលាការធម្មនុញ្ញនៃប្រទេសអ៊ីតាលី និងប្រទេសអេស្ប៉ាញ ត្រូវបានតែងតាំងដោយតុលាការ។
- **លក្ខខណ្ឌដែលអាចតែងតាំងបានៈ** នៅបារាំង អំណាចនយោបាយមានសេរីភាពក្នុងការជ្រើសតាំង ប៉ុន្តែនៅសហព័ន្ធអាឡឺម៉ង់ អេស្ប៉ាញ និងអ៊ីតាលី សមាជិកអាចត្រូវតែងតាំងចំពោះបុគ្គលណាដែលមានសមត្ថភាពខាងផ្លូវច្បាប់ប៉ុណ្ណោះ(ចៅក្រម មេធាវី និងសាស្ត្រាចារ្យច្បាប់)។[6]
- **លក្ខន្តិកៈនៃសមាជិកៈ** អាចមានការប្រែប្រួល អាស្រ័យទៅតាមគោលគំនិតនៃអ្នកតាក់តែងច្បាប់ ដើម្បីធានាឲ្យមានឯករាជ្យភាពរបស់ស្ថាប័ននេះ ចំពោះមុខអំណាចនយោបាយ។ នៅប្រទេសបស្ទឹមលោកមួយចំនួន សមាជិកនៃស្ថាប័ននេះ ត្រូវបានតែងតាំងសម្រាប់រយៈពេលមួយ ប៉ុន្តែអាចត្រូវបានដកចេញមុនផុតអាណត្តិ ប្រសិនបើត្រូវបានគេរកឃើញថាមានសកម្មភាពខុសច្បាប់ណាមួយត្រូវបានប្រព្រឹត្តឡើង ហើយប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើបទប្បញ្ញត្តិនៃការរៀបចំ និងការប្រព្រឹត្តទៅ ឬបទបញ្ជាផ្ទៃក្នុងរបស់ស្ថាប័ននោះ។ តួយ៉ាងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញបារាំងចំនួន១ភាគ៣ នៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល ត្រូវធ្វើការផ្លាស់ប្តូរជាវៀងរាល់៣ឆ្នាំម្តងយ៉ាងទៀងទាត់។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញបារាំង មានវិសមិតភាពនឹងមុខងារជាសមាជិករដ្ឋាភិបាល សមាជិកសភា និងសមាជិកក្រុមប្រឹក្សាសង្គមកិច្ច និងសេដ្ឋកិច្ច ព្រមទាំងប្រធាន អនុប្រធានគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត។[7]

- **ការត្រួតពិនិត្យដោយអង្គការទូទៅ ឬតុលាការធម្មតា**

នៅសហរដ្ឋអាមេរិក ការត្រួតពិនិត្យធម្មនុញ្ញភាពរបស់ច្បាប់ គឺត្រូវធ្វើឡើងដោយតុលាការធម្មតា ដោយពុំមានការបង្កើតឲ្យមានស្ថាប័នដាច់ដោយឡែកនោះទេ។ ការត្រួតពិនិត្យ អាចត្រូវធ្វើឡើងបានក្នុងរបៀបរបបចំនួន២ពោលគឺៈ ការត្រួតពិនិត្យតាមវិធីអញ្ញត្រកម្ម និងការត្រួតពិនិត្យតាមនីតិវិធីបង្គាប់។

- **ការត្រួតពិនិត្យតាមវិធីអញ្ញត្រកម្មៈ** នៅក្នុងរឿងណាមួយមុននឹងឈានចូលដល់ជម្រៅពិតប្រាកដនៃសាច់រឿងវិវាទ ចៅក្រមត្រូវពិនិត្យជាមុនសិនអំពីអត្ថបទដែលគូភាគីណាមួយលើកឡើងថា មានអត្ថ-ន័យមិនស្របទៅតាមរដ្ឋធម្មនុញ្ញ។ បើចៅក្រមប្រកាសថាអត្ថបទច្បាប់នោះ វាមិនអនុលោមទៅតាមរដ្ឋ

[5] មាត្រា៥៦ វាក្យខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋបារាំងទី៥ឆ្នាំ១៩៥៨។

[6] សុខ ចិន្តា និងសុខ យ៉ាន, *នីតិរដ្ឋធម្មនុញ្ញ*, បោះពុម្ពលើកទី១ (ភ្នំពេញៈ Good News Printing House, ២០១៨), ៥២។

[7] មាត្រា៥៧ នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋបារាំងទី៥ឆ្នាំ១៩៥៨។

ធម្មនុញ្ញមែន នាំឲ្យអត្ថបទច្បាប់នោះមិនត្រូវបានយកមកអនុវត្តសម្រាប់ជំនុំជម្រះក្នុងរឿងក្តីនោះទេ។ បើភាគីម្ខាងទៀតមិនសុខចិត្ត គេអាចប្តឹងទៅសាលាឧទ្ធរណ៍រួច រហូតទៅដល់តុលាការកំពូលដែលជាអ្នកសម្រេចចុងក្រោយបង្អស់ និងជាអ្នកកំណត់យុត្តិសាស្ត្រអំពីធម្មនុញ្ញភាព។[8]

- **ការត្រួតពិនិត្យតាមនីតិវិធីបង្គាប់:** នៅពេលបុគ្គលណាម្នាក់ យល់ឃើញថាច្បាប់ណាមួយដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ខ្លួន ហើយផ្ទុយនឹងរដ្ឋធម្មនុញ្ញ បុគ្គលនោះ អាចប្តឹងទៅចៅក្រមឲ្យចេញសេចក្តីបង្គាប់ហាមឃាត់ទៅភ្នាក់ងារ ឬអាជ្ញាធរដែលទទួលបន្ទុកអនុវត្តច្បាប់នោះ។[9]

### ១.២. ការវិវត្តរបស់ក្រុមប្រឹក្សាធម្មនុញ្ញក្នុងបរិបទកម្ពុជា

យោងទៅតាមប្រវត្តិសាស្ត្រ ប្រទេសកម្ពុជា ធ្លាប់មានរដ្ឋធម្មនុញ្ញសម័យទំនើបដែលគេចាត់ទុកជាច្បាប់កំពូលចំនួន៦ រួចមកហើយដោយគិតចាប់ពីឆ្នាំ១៩៤៧ មកទល់នឹងពេលបច្ចុប្បន្ន។ រដ្ឋធម្មនុញ្ញទាំង៦ នេះបានប្រែប្រួលដោយផ្អែកជាពិសេសទៅលើការផ្លាស់ប្តូររបបនយោបាយ ទស្សនៈសង្គម និងឥរិយាបថសេដ្ឋកិច្ច។ ជាងនេះទៅទៀត គេសង្កេតឃើញថា រដ្ឋធម្មនុញ្ញកម្ពុជាទាំង ៦មានរដ្ឋធម្មនុញ្ញមួយចំនួន បានកំណត់អំពីស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ ឬតុលាការធម្មនុញ្ញ ប៉ុន្តែរដ្ឋធម្មនុញ្ញខ្លះទៀត ពុំបានចែងអំពីស្ថាប័ននេះទេ។ ជាកត្តាសត្យានុម័ត កត្តាដែលនាំឲ្យមានស្ថានភាពបែបនេះ អាចបណ្តាលមកពី ចេតនារបស់អ្នកតាក់តែងច្បាប់ តម្រូវការជាក់ស្តែងរបស់សង្គម និងទំនោរនយោបាយផ្សេងៗ។ល។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ជារដ្ឋធម្មនុញ្ញដំបូងសម្រាប់ប្រទេសកម្ពុជា ក្រោយពីត្រូវបានកែប្រែជាបន្តបន្ទាប់ រហូតមកដល់ឆ្នាំ១៩៦៤ ក៏ច្បាប់កំពូលនេះ ពុំបានបញ្ញត្តិអំពីស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពនោះទេ ប៉ុន្តែមានការលើកឡើងអំពីសិទ្ធិបកស្រាយសេចក្តីបទរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់រដ្ឋសភាជាដាច់ខាត។[10] បន្ទាប់មករដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរឆ្នាំ១៩៧២ បានបង្កើតស្ថាប័នមួយដែលមានឈ្មោះថា តុលាការធម្មនុញ្ញ។ តុលាការធម្មនុញ្ញនេះមិនស្ថិតក្នុងឋានានុក្រមនៃតុលាការធម្មតាទេ ដែលមានសមត្ថកិច្ចពិនិត្យអំពីនិយ័តភាព និងប្រកាសពីលទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រធានាធិបតី និងអនុប្រធានាធិបតីនៃសាធារណរដ្ឋ។ លើសពីនេះទៅទៀត ស្ថាប័នតុលាការធម្មនុញ្ញ ក៏មានតួនាទីពិនិត្យ និងដោះស្រាយវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសរើសសមាជិកសភា ព្រមទាំងជាអ្នកបកស្រាយចុងក្រោយនៃបទប្បញ្ញត្តិធម្មនុញ្ញផងដែរ។[11] ទោះបីជាយ៉ាងណាក៏ដោយ រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២ ពុំបានប្រគល់សមត្ថកិច្ចឲ្យទៅតុលាការធម្មនុញ្ញដើម្បីត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ឡើយ។ រីឯ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៦ ពុំបានបញ្ញត្តិអំពីស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពនោះទេ ត្បិតថាសម័យនោះ កម្ពុជាបានកំពុងធ្លាក់ចូលក្នុងរបបដ៏ខ្មៅងងឹត ដែលប្រជាជនខ្មែរគ្រប់រូបបានស្គាល់ថាជា «*របបប្រល័យពូជ*

[8] ម៉ែន វុធ, *នីតិរដ្ឋធម្មនុញ្ញ និងស្ថាប័ននយោបាយ*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ ២០២០), ៣១។

[9] ម៉ែន វុធ, *នីតិរដ្ឋធម្មនុញ្ញ និងស្ថាប័ននយោបាយ*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ ២០២០), ៣១។

[10] មាត្រា១១៩ នៃរដ្ឋធម្មនុញ្ញប្រទេសកម្ពុជាឆ្នាំ១៩៤៧។

[11] មាត្រា៩៥ នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរឆ្នាំ១៩៧២។

*សាសន៍ខ្មែរក្រហម»*។ ក្រោយពីថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ រដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជាឆ្នាំ១៩៨១ ត្រូវបានចាប់បដិសន្ធិឡើង ហើយបានប្រគល់មុខងារបកស្រាយច្បាប់ទៅកាន់ក្រុមប្រឹក្សារដ្ឋ ក្នុងឋានៈជាអង្គការអចិន្ត្រៃយ៍របស់រដ្ឋសភាតាមរយៈមាត្រា ៦០ នៃរដ្ឋធម្មនុញ្ញនេះ។ ទន្ទឹមនឹងនេះ រដ្ឋធម្មនុញ្ញរដ្ឋកម្ពុជាឆ្នាំ១៩៨៩ ក៏បានផ្តល់តួនាទីនៃការបកស្រាយច្បាប់ ទៅឲ្យគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាផងដែរ ដោយសំអាងលើមាត្រា៤៩ (ស្ទួន២ថ្មី)។ យ៉ាងណាមិញ គេបានកត់សម្គាល់ឃើញថា រដ្ឋធម្មនុញ្ញទាំងពីរគឺៈ រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១ និងឆ្នាំ១៩៨៩ ពុំបានកំណត់អំពីស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពណាមួយនោះទេ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះមហាក្សត្រ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ជាវឌ្ឍនភាពថ្មីមួយនៃការរួបរួមរវាងភាគីខ្មែរចតុភាគី ក្រោយពីមានកិច្ចព្រមព្រៀងនៅទីក្រុងប៉ារីស នាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដែលឈានទៅដល់ការបោះឆ្នោតជ្រើសរើសសមាជិកសភាធម្មនុញ្ញ ហើយសភាធម្មនុញ្ញ ជាអ្នកតាក់តែង និងបានអនុម័តរដ្ឋធម្មនុញ្ញនេះឡើង។ បន្ទាប់ពីមានវិសោធនកម្មជំពូកទី១០ នៃរដ្ឋធម្ម-នុញ្ញ (ជំពូកទី១២ថ្មី នៃរដ្ឋធម្មនុញ្ញ ក្រោយពីវិសោធនកម្ម) គេពិនិត្យឃើញថា ច្បាប់កំពូលរបស់ជាតិឆ្នាំ១៩៩៣ បានបង្កើតឲ្យមានស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានសមត្ថកិច្ចធានាការពារ ការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ព្រមទាំងមានសិទ្ធិពិនិត្យ ហើយសម្រេចអំពីករណីវិវាទកម្ម ទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាផងដែរ។[12] បន្ថែមពីលើនេះទៅទៀត ស្ថាប័ននេះក៏មានសមត្ថកិច្ចពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ាការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ប្រកាសមោឃភាពរាល់ការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឲ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ ជាពិសេសផ្តល់មតិថ្វាយព្រះមហាក្សត្រ នៅពេលដែលទ្រង់ពិគ្រោះយោបល់ជុំវិញសេចក្តីស្នើទាំងឡាយ ដែលស្នើសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ។

### ១.៣. បុព្វហេតុនៃការកកើតស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៨

ក្រុមប្រឹក្សាធម្មនុញ្ញ ជាស្ថាប័នកំពូលឯករាជ្យ និងអព្យាក្រឹត្យមួយដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។ ជាទស្សនទានថ្មីមួយ ដែលកម្ពុជាតាមរយៈច្បាប់កំពូលរបស់ជាតិ បានបង្កើតឲ្យមានស្ថាប័ននេះឡើង ដោយបានផ្តល់សមត្ថកិច្ចយ៉ាងជាក់លាក់សម្រាប់អនុញ្ញាតឲ្យក្រុមប្រឹក្សាធម្មនុញ្ញបំពេញតួនាទី និងអនុវត្តភារកិច្ចរបស់ខ្លួនបានយ៉ាងមានប្រសិទ្ធភាព តម្លាភាព និងយុត្តិធម៌។

ទស្សនៈមួយចំនួនត្រូវបានលើកឡើង ជុំវិញបុព្វហេតុដែលនាំឲ្យមានការកកើតស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មានដូចជាៈ

[12] មាត្រា១៣៦ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

- ធានាដំណើរការនៃលទ្ធិប្រជាធិបតេយ្យ តាមរយៈការបង្កើតឲ្យមានស្ថាប័នមួយសម្រាប់ត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ និងបកស្រាយច្បាប់ ក្នុងគោលដៅដើម្បីបញ្ចៀសការប្រមូលផ្តុំអំណាចក្នុងការតាក់តែងច្បាប់តាមតែអំពើចិត្តរបស់អ្នកនយោបាយ ជាពិសេសគណបក្សនយោបាយដែលទទួលបានអាសនៈច្រើនលើសលប់នៅក្នុងរដ្ឋសភា
- រក្សាការពារឆន្ទៈរបស់សភាធម្មនុញ្ញ ក្រោយពេលដែលរដ្ឋធម្មនុញ្ញត្រូវបានអនុម័ត និងប្រកាសឲ្យប្រើ ព្រមទាំងចូលជាធរមាន
- ធានាដំណើរការកសាងនីតិរដ្ឋ ការគោរពសិទ្ធិមនុស្ស និងការអនុវត្តយុទ្ធសាស្ត្រ គោលនយោបាយជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា
- ធានាឧត្តមភាពរបស់រដ្ឋធម្មនុញ្ញ ដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយ ត្រូវតែអនុលោមទៅតាមរដ្ឋធម្មនុញ្ញក្នុងនាមជាច្បាប់កំពូល ឬច្បាប់គ្រឹះជាដាច់ខាត
- រក្សាឲ្យបានសុវត្ថិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់គតិយុត្ត តាមរយៈការអនុវត្តច្បាប់ឲ្យមានការឯកភាពក្នុងក្របខណ្ឌទូទាំងប្រទេស និងតាមគ្រប់បណ្តាស្ថាប័នរដ្ឋ-ឯកជន ស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ
- ធានាការដោះស្រាយ និងសម្រេចអំពីករណីវិវាទកម្ម ទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រព្រមទាំងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ជាពិសេសការដោះស្រាយវិវាទទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី២ ប្រកបដោយតម្លាភាព អព្យាក្រឹត្យភាព និងយុត្តិធម៌។[13]

## ផ្នែកទី២៖ ការរៀបចំ និងដំណើរការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលជាច្បាប់មួយសម្រាប់បញ្ញត្តិអំពីការរៀបចំ(២.១) និងការប្រព្រឹត្តទៅនៃស្ថាប័នកំពូលនេះ(២.២)។

### ២.១. ការរៀបចំនៃក្រុមប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាធម្មនុញ្ញ ជាស្ថាប័នឯករាជ្យ និងអព្យាក្រឹត្យភាពក្នុងការបំពេញសមត្ថកិច្ចរបស់ខ្លួន ដោយមិនស្ថិតនៅក្រោមឋានានុក្រម អំណាច និងការគាបសង្កត់ពីស្ថាប័ន ឬបុគ្គល និងអំណាចដទៃទៀតឡើយ។ ស្ថាប័ននេះ គ្មានខ្សែបណ្តោយ និងខ្សែទទឹងនោះទេ ប៉ុន្តែថវិកាសម្រាប់ដំណើរការ គឺបានមកពីថវិការដ្ឋ។ ក្រុមប្រឹក្សាធម្មនុញ្ញ មានសមាជិក៩រូប ដែលទទួលបានអាណត្តិ៩ឆ្នាំ ហើយត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួន១ភាគ៣ ត្រូវផ្លាស់ថ្មីក្នុងរយៈពេល៣ឆ្នាំម្តងៗ យ៉ាងទៀងទាត់។[14] សមាជិកទាំង៩រូប នៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវ

[13] ជុំ អ៊ីម, *ស្ថាប័ននយោបាយនៃព្រះរាជាណាចក្រកម្ពុជា*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ រោងពុម្ពសុខ ចេង, ២០១២), ៣០៨។

[14] មាត្រា១៣៧ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ជ្រើសរើសក្នុងចំណោមឥស្សរជនដែលមានសញ្ជាតិខ្មែរពីកំណើត មានអាយុយ៉ាងតិច៤៥ឆ្នាំ មានសញ្ញាបត្រចាប់ពីឧត្តមសិក្សាឡើងទៅខាងច្បាប់ ខាងរដ្ឋបាល ខាងការទូត ឬខាងសេដ្ឋកិច្ច ហើយមានបទពិសោធន៍ក្នុងការងារយ៉ាងតិច១៥ឆ្នាំ។[15]

ការតែងតាំង និងជ្រើសតាំងសមាសភាពសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវធ្វើឡើងដោយ ព្រះមហាក្សត្រ (២.១.១) រដ្ឋសភា(២.១.២) និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម(២.១.៣) ដាច់ដោយឡែកពីគ្នា។

- **ករណីអញ្ញត្រកម្ម:** នៅក្នុងអាណត្តិទី១ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវមានសមាជិក ៣រូប ដែលត្រូវបានតែងតាំង និងជ្រើសតាំងសម្រាប់រយៈពេល៣ឆ្នាំ សមាជិក ៣រូប ត្រូវបានតែងតាំង និងជ្រើសតាំងសម្រាប់រយៈពេល ៦ឆ្នាំ ព្រមទាំងសមាជិក ៣រូបទៀត ត្រូវបានតែងតាំង និងជ្រើសតាំងសម្រាប់រយៈពេល៩ឆ្នាំ ក្នុងគោលដៅរក្សាឲ្យបាននិរន្តរភាពការងារ ដោយចៀសវាងកុំឲ្យមានការឈប់ ឬចូលថ្មីទាំងអស់គ្នា ដែលជាបច្ច័យនាំឲ្យរាំងស្ទះដល់ដំណើរការកិច្ចការងារ។

### ២.១.១. ការតែងតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញដោយព្រះមហាក្សត្រ

អនុលោមតាមមាត្រា៧ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ព្រះមហាក្សត្រកម្ពុជា ទ្រង់គ្រងរាជ្យសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួន៣រូប ត្រូវតែងតាំងដោយព្រះមហាក្សត្រ។ ការតែងតាំងរបស់ព្រះមហាក្សត្រ ជាអំណាចរដ្ឋធម្មនុញ្ញប្រទាន ពោលគឺពុំមែនជាការកាន់អំណាចនយោបាយ ដែលសំដៅទៅលើអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការឡើយ។ ក្នុងរយៈពេល៣ឆ្នាំម្តង ព្រះមហាក្សត្រ ត្រូវតែងតាំងជាថ្មីសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន១រូប។[16]

សមាសភាពក្រុមប្រឹក្សាធម្មនុញ្ញ ៣ឆ្នាំ លើកទី១ (១៩៩៨-២០០១) ដែលព្រះមហាក្សត្រ បានតែងតាំងមានដូចជា:

- សម្តេច **ចៅសែនកុសល ឈុំ** សម្រាប់អាណត្តិ ៩ឆ្នាំ
- ឯកឧត្តមបណ្ឌិត **សាយ បូរី** សម្រាប់អាណត្តិ ៦ឆ្នាំ និង
- ឯកឧត្តម **សឺន ស៊ូប៊ែរ្ត៍** សម្រាប់អាណត្តិ ៣ឆ្នាំ។

### ២.១.២. ការជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញដោយរដ្ឋសភា

រដ្ឋសភា ជាស្ថាប័ននីតិប្បញ្ញត្តិមួយ ដែលកើតចេញពីការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋ។ ការជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវធ្វើឡើង តាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ក្នុងរយៈពេល៣ឆ្នាំម្តង រដ្ឋសភា ត្រូវជ្រើសតាំងជាថ្មីសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន១រូប។

---

[15] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ នស/រកម/០១០៧/០០៥, ៣១ មករា ២០០៧, មាត្រា៣ថ្មី វាក្យខណ្ឌទី១។

[16] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ នស/រកម/០១០៧/០០៥, ៣១ មករា ២០០៧, មាត្រា៤ថ្មី វាក្យខណ្ឌទី១។

ការជ្រើសតាំងដោយរដ្ឋសភា អាចធ្វើឡើងជាពីរលើកបាន។[17]

ក្នុងអាណត្តិទី១ បើការបោះឆ្នោតលើកទី១ មិនបានទទួលមតិភាគច្រើនដាច់ខាតនោះទេ ត្រូវបោះឆ្នោតជាលើកទី២ ដោយយកអ្នកដែលទទួលបានសម្លេងច្រើនជាងគេចំនួនយ៉ាងច្រើន៥រូប មកបោះឆ្នោតឡើងវិញ។ ការបោះឆ្នោតលើកទី២ ត្រូវយកតាមមតិភាគច្រើនដោយប្រៀប។ អ្នកដែលទទួលបានសម្លេងច្រើនជាងគេត្រូវតែងតាំងសម្រាប់អាណត្តិ ៩ឆ្នាំ អ្នកដែលទទួលបានសម្លេងបន្ទាប់ត្រូវតែងតាំងសម្រាប់អាណត្តិ៦ឆ្នាំ និងអ្នកដែលទទួលបានសម្លេងបន្ទាប់មកទៀតត្រូវតែងតាំងសម្រាប់អាណត្តិ ៣ឆ្នាំ។

ក្នុងអាណត្តិបន្តបន្ទាប់ បើការបោះឆ្នោតលើកទី១ មិនបានទទួលមតិភាគច្រើនដាច់ខាតនោះ ត្រូវបោះឆ្នោតលើកទី២ ដោយយកអ្នកដែលទទួលបានសម្លេងច្រើនជាងគេ២នាក់នោះទៅបោះឆ្នោតឡើងវិញ។ ការបោះឆ្នោតលើកទី២ ត្រូវយកតាមសម្លេងមតិភាគច្រើនដោយប្រៀប។

ក្នុងករណីដែលបេក្ខជនទទួលបានសម្លេងស្មើគ្នា នោះត្រូវយកអ្នកដែលមានអាយុច្រើនជាងគេ។

បេក្ខជនម្នាក់ៗ ដែលនឹងត្រូវជ្រើសតាំងដោយរដ្ឋសភា ត្រូវមានហត្ថលេខាគាំទ្រជាមុនពីសមាជិករដ្ឋសភាចំនួនមួយភាគដប់ នៃចំនួនសមាជិករដ្ឋសភាទាំងមូល។ សមាជិករដ្ឋសភា ១រូប មានសិទ្ធិគាំទ្របានតែបេក្ខជន១រូបតែប៉ុណ្ណោះ។[18]

សមាសភាពក្រុមប្រឹក្សាធម្មនុញ្ញ ៣ឆ្នាំ លើកទី១ (១៩៩៨-២០០១) ដែលរដ្ឋសភា បានជ្រើសតាំងមានដូចខាងក្រោម:

- ឯកឧត្តម **ប៊ិន ឈិន** ដោយទទួលបានសម្លេងគាំទ្រ ៧១/៨៨ សម្រាប់អាណត្តិ ៩ឆ្នាំ
- ឯកឧត្តម **យ៉ង់ សែម** ដោយទទួលបានសម្លេងគាំទ្រ ៦៨/៨៨ សម្រាប់អាណត្តិ ៦ឆ្នាំ និង
- ឯកឧត្តម **តុប សំ** ដោយទទួលបានសម្លេងគាំទ្រចំនួន ៦១/៨៨ សម្រាប់អាណត្តិ ៣ឆ្នាំ។

### ២.១.៣. ការតែងតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាស្ថាប័នកំពូលមួយ ដែលមានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។[19] ស្ថាប័ននេះ ត្រូវបានបង្កើតដោយច្បាប់រៀបចំអង្គការមួយ ដែលកំណត់ពីសមាសភាព និងមុខងារ រួមទាំងសមត្ថកិច្ច ហើយត្រូវបានគេស្គាល់ថាជា « ***ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុម***

[17] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ នស/រកម/០១០៧/០០៥, ៣១ មករា ២០០៧, មាត្រា៣ថ្មី វាក្យខណ្ឌទី៣។

[18] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ នស/រកម/០១០៧/០០៥, ៣១ មករា ២០០៧, មាត្រា៣ថ្មី វាក្យខណ្ឌទី៧។

[19] មាត្រា១៣៤ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

*ប្រឹក្សានៃអង្គចៅក្រម* »ដែលប្រកាសឲ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រមលេខ០៩/នស/៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួន៣ រូប ត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

ក្នុងរយៈពេល៣ឆ្នាំម្តងៗ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវតែងតាំងជាថ្មីសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន១រូប។

សមាសភាពក្រុមប្រឹក្សាធម្មនុញ្ញ ៣ឆ្នាំ លើកទី១ (១៩៩៨-២០០១) ដែលឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានតែងតាំង មានដូចខាងក្រោមៈ

- ឯកឧត្តម **ចាន់ សុក** ដោយទទួលបានសម្លេងគាំទ្រចំនួន ៧/៩ សម្រាប់អាណត្តិ ៩ឆ្នាំ
- ឯកឧត្តម **ថោ ប៉េងលាត** ដោយទទួលបានសម្លេងគាំទ្រចំនួន ៦/៩ សម្រាប់អាណត្តិ ៦ឆ្នាំ និង
- ឯកឧត្តម **ប្រាក់ សុខ** ដោយពុំមានបញ្ជាក់ពីចំនួនសម្លេងគាំទ្រ សម្រាប់អាណត្តិ ៣ឆ្នាំ។

### ២.២. ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ បានកំណត់យកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៨ ជាថ្ងៃខួបប្រសូតឡើងនៃស្ថាប័ន ហើយបានចាប់ផ្តើមក្នុងការបំពេញសកម្មភាពរបស់ខ្លួនជាផ្លូវការ នៅ អាគារ ស ដែលស្ថិតក្នុងបរិវេណនៃវិមានរដ្ឋចំ-ការមន។ ជារៀងរាល់ឆ្នាំ គេសង្កេតឃើញថា ឲ្យតែដល់ថ្ងៃទី១៥ ខែមិថុនា (អាចមុន ឬក្រោយថ្ងៃទី១៥ ខែមិថុនា ដោយមូលហេតុថ្ងៃទី១៥ ជាថ្ងៃបុណ្យជាតិ ឬថ្ងៃឈប់សម្រាក) អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ តែងតែរៀបចំពិធីសំណេះសំណាលរវាងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជាមួយនឹងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាន ព្រមទាំងមន្ត្រីរាជការដែលបម្រើការងារនៅក្នុងនាយកដ្ឋាន និងការិយាល័យចំណុះអគ្គលេខាធិការដ្ឋាន។[20]

ដើម្បីធានាដំណើរការនៃការប្រព្រឹត្តទៅរបស់ស្ថាប័ន ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវរៀបចំ តាក់តែង និងអនុម័តសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុង ព្រមទាំង សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ។ តួយ៉ាង នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៨ ក្រុមប្រឹក្សាធម្មនុញ្ញបានអនុម័តទៅលើសេចក្តីព្រាងទាំងពីរខាងលើនេះ ក្រោមអធិបតីភាពរបស់ ឯកឧត្តម **ចាន់ សុក** ដែលជាប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ៣ឆ្នាំ លើកទី១។[21]

ដូច្នេះ ក្នុងគោលដៅរក្សាឲ្យបានប្រក្រតីភាព នៃដំណើរការសកម្មភាពរបស់ក្រុមប្រឹក្សាធម្មនុញ្ញ យើងនឹងសិក្សាអំពីការចូលកាន់តំណែង(២.២.១) ការលាឈប់ និងការដកចេញពីតំណែងនៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ (២.២.២) និងការតែងតាំង ឬជ្រើសតាំងថ្មី ឬជំនួស(២.២.៣)។

[20] ឈុន ណារ៉េត, *សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ*, បោះពុម្ពលើកទី២ (ភ្នំពេញ៖ ផាងពុម្ពដារ៉ា, ២០១៦), ៦៣។

[21] ឈុន ណារ៉េត, *សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ*, បោះពុម្ពលើកទី២ (ភ្នំពេញ៖ ផាងពុម្ពដារ៉ា, ២០១៦), ៦៤។

### ២.២.១. ការចូលកាន់តំណែង

មុននឹងចូលកាន់តំណែង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវធ្វើសច្ចាប្រណិធានជាមុនសិន ដូចមានចែងក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលមិនបានធ្វើសច្ចាប្រណិធាន ដោយគ្មានមូលហេតុត្រឹមត្រូវក្នុងរយៈពេល៧ ថ្ងៃក្រោយពីថ្ងៃដែលបានចេញព្រះរាជក្រឹត្យតែងតាំងចុងក្រោយ អាចនឹងត្រូវទទួលទណ្ឌកម្មខាងវិន័យ ដោយការដកចេញពីមុខតំណែង។

ជាទូទៅមុននឹងចូលកាន់តំណែង អ្នកដែលត្រូវបានតែងតាំង ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសុំលាឈប់ជាបណ្តោះអាសន្នពីតំណែងនានា ឬមុខរបរផ្សេងៗទាំងអស់ ដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសមាជិក ដែលស្ថិតក្នុងមុខតំណែង និងមុខរបរខាងលើឲ្យសុំលាឈប់ពីមុខតំណែង ឬមុខរបរនោះជាបន្ទាន់។[22]

### ២.២.២. ការលាឈប់ និងការដកចេញពីតំណែងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញម្នាក់ៗ អាចសុំលាឈប់ពីតំណែងបាន ដោយគ្រាន់តែធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ។ ការលាឈប់របស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ អាចប្រព្រឹត្តទៅបានលុះត្រាតែសមាជិកនោះបានជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រុមប្រឹក្សាធម្មនុញ្ញ និង ក្រោយពីស្ថាប័នដែលមានសមត្ថកិច្ចតែងតាំង ឬជ្រើសតាំង(ព្រះមហាក្សត្រ រដ្ឋសភា និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម) បានតែងតាំង ឬ ជ្រើសតាំងសមាជិកថ្មីមកជំនួស។ ចំណែកឯការដក ឬបណ្តេញចេញសមាជិកក្រុមប្រឹក្សាធម្មនុញ្ញពីមុខតំណែងត្រូវធ្វើឡើងចំពោះ៖

- សមាជិករូបណា ដែលមានមុខងារវិសមិភាពជាមួយមុខងារនៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ
- សមាជិករូបណា ដែលបានបំពេញមុខតំណែង និងមុខរបរផ្សេងទៀត ក្នុងអាណត្តិដែលខ្លួនកំពុងមានមុខតំណែងជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដោយគ្មានការសុំលាឈប់ជាបណ្តោះអាសន្ន
- សមាជិករូបណា ដែលមិនបានធ្វើសច្ចាប្រណិធាន មុននឹងចូលកាន់តំណែងជា សមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ
- សមាជិករូបណា ដែលមិនបានមកប្រជុំលើសពី ៣ដងជួនៗគ្នា ដោយឥតមានការជូនដំណឹងជាមុន
- សមាជិករូបណា ដែលមិនអាចបំពេញមុខងារជារៀងរហូតបានដោយសារ ការបាត់បង់សមត្ថភាពខាងបញ្ញា ឬរូបកាយជាអចិន្ត្រៃយ៍។

ការសម្រេចដកសមាជិករូបណាមួយចេញពីតំណែង តម្រូវឲ្យមានការយល់ព្រមពីសមាជិកចំនួន២ភាគ៣នៃចំនួនសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល (៦ សម្លេងយ៉ាងតិច)។[23]

---

[22] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ នស/រកម/០១០៧/០០៥, ៣១ មករា ២០០៧, មាត្រា៤ថ្មី វាក្យខណ្ឌទី៣ និងទី៤។

[23] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ ជស/រកម/០៤៩៨/០៦, ០៨ មេសា ១៩៩៨, មាត្រា១០ វាក្យខណ្ឌទី២។

ការដកសមាជិកណាមួយពីក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម:

១-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវជូនដំណឹងទៅសមាជិកដែលត្រូវដកចេញថាគេមានពេលវេលា ១៤ ថ្ងៃ ចាប់ពីថ្ងៃដែលបានទទួលលិខិតជូនដំណឹង ដើម្បីផ្ញើសារណាការពារខ្លួន។

២-ផុតពេលនេះទោះបីសាមីខ្លួន មិនបានផ្ញើសារណាការពារខ្លួនមកក្រុមប្រឹក្សាធម្មនុញ្ញក៏ដោយ ក្រុមប្រឹក្សាធម្មនុញ្ញ អាចបើកសវនាការសម្រេចលើករណីនេះបាន។

ក្នុងពេលសវនាការ សាមីខ្លួនអាចអញ្ជើញមកការពារខ្លួនមុខក្រុមប្រឹក្សាធម្មនុញ្ញ ឬ ចាត់តាំងតំណាង ឬមេធាវី មកការពារខ្លួនក៏បាន។[24]

ក្នុងករណីដែលសមាជិកក្រុមប្រឹក្សាធម្មនុញ្ញរូបណា ដែលត្រូវបានតុលាការកាត់ទោសដាក់ពន្ធនាគារពីបទល្មើសព្រហ្មទណ្ឌដូចជា៖ បទមជ្ឈឹម ឬបទឧក្រិដ្ឋ សមាជិកនោះនឹងត្រូវដកចេញពីមុខតំណែងជាស្វ័យប្រវត្តិ។[25]

### ២.២.៣. ការតែងតាំង ឬជ្រើសតាំងថ្មី ឬជំនួស

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ នឹងត្រូវតែងតាំងជំនួសយ៉ាងយូរ ៣០ថ្ងៃ មុនចប់អាណត្តិរបស់សមាជិកដែលត្រូវចេញពីតំណែង។[26]

ក្នុងករណីដែលមានការសុំលាឈប់ ឬ ការដកចេញពីតំណែង ឬ មរណភាព សមាជិកថ្មីដែលនឹងមកជំនួសត្រូវតែងតាំងដូចដែលមានចែងក្នុងមាត្រា៤ ក្នុងរយៈពេល៣០ថ្ងៃ។ ប្រសិនបើសមាជិកដែលសុំលាឈប់ ឬត្រូវបានដកចេញពីតំណែង ឬទទួលអនិច្ចកម្ម ត្រូវបានតែងតាំង ឬជ្រើសតាំងពីស្ថាប័នមានសមត្ថកិច្ចណាមួយ (ព្រះមហាក្សត្រ រដ្ឋសភា និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម) នាំឲ្យសមាជិកថ្មីដែលមកជំនួស នឹងត្រូវបានតែងតាំង ឬជ្រើសតាំងពីស្ថាប័នមានសមត្ថកិច្ចនោះវិញ ក្នុងរយៈពេល៣០ ថ្ងៃ។

សមាជិកថ្មីនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលត្រូវបានតែងតាំងជំនួសសមាជិក ដែលត្រូវចេញពីមុខតំណែងមុនចប់អាណត្តិធម្មតារបស់ខ្លួន សមាជិកថ្មីនោះមានអាណត្តិត្រឹមថិរវេលាដែលនៅសល់ប៉ុណ្ណោះ។[27]

ប៉ុន្តែបើថិរវេលានេះតិចជាង ៣ឆ្នាំ ឬ ស្មើនឹង ៣ឆ្នាំ នៅពេលចប់ថិរវេលានេះ សមាជិកនោះ អាចត្រូវបានស្ថាប័នមានសមត្ថកិច្ចតែងតាំង ឬជ្រើសតាំង សម្រាប់អាណត្តិថ្មីមួយអាណត្តិទៀត។[28]

**ឧទាហរណ៍:**

សមាសភាពក្រុមប្រឹក្សាធម្មនុញ្ញ ៣ឆ្នាំ លើកទី៧ (២០១៦-២០១៩) ត្រូវបានផ្លាស់ប្តូរ ឬកែប្រែដោយៈ

---

[24] បទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ, ២៨ កក្កដា ១៩៩៨, ប្រការ២៧ស្ទួន។

[25] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ ជស/រកម/០៤៩៨/០៦, ០៨ មេសា ១៩៩៨, មាត្រា១០ វាក្យខណ្ឌទី៣។

[26] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ ជស/រកម/០៤៩៨/០៦, ០៨ មេសា ១៩៩៨, មាត្រា៦ វាក្យខណ្ឌទី១។

[27] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ ជស/រកម/០៤៩៨/០៦, ០៨ មេសា ១៩៩៨, មាត្រា៨ វាក្យខណ្ឌទី១។

[28] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ ជស/រកម/០៤៩៨/០៦, ០៨ មេសា ១៩៩៨, មាត្រា៨ វាក្យខណ្ឌទី២។

- ឯកឧត្តម **អ៊ឹម សួស្ដី** បានចូលកាន់តំណែងជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ នៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០១៧ ជំនួសឯកឧត្តម **ពិត តាំងសាន** ដែលបានទទួលមរណភាព។
- ឯកឧត្តម **ហ៊ី សោភា** បានចូលកាន់តំណែងជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ នៅថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ ២០១៧ ជំនួសលោកជំទាវ **ចែម វេយ្យរិទ្ធ** ដែលបានសុំលាឈប់ពីតំណែង។

## ផ្នែកទី៣៖ លក្ខណៈពិសេសរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលទទួលបានការតែងតាំងដោយព្រះរាជក្រឹត្យ និងបានធ្វើសច្ចាប្រណិធាន ត្រឹមត្រូវតាមច្បាប់ចប់សព្វគ្រប់ហើយ មានបុគ្គលភាពគតិយុត្ត និងសមត្ថភាពគតិយុត្តពេញសិទ្ធិជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញជាផ្លូវការ។ ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈនិងបុព្វសិទ្ធិ ស្មើនឹងប្រធានរដ្ឋសភា និង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈនិងបុព្វសិទ្ធិស្មើនឹងអនុប្រធានរដ្ឋសភា។ ទន្ទឹមនឹងនេះ ក្នុងមុខតំណែងរបស់ខ្លួន សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានលក្ខណៈពិសេសដូចជាៈ អភ័យឯកសិទ្ធិ(៣.១) វិសមិតភាព(៣.២) វិន័យ និង ចរិយាសម្បត្តិនៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ(៣.៣) និងការឈប់សម្រាក និងការអនុញ្ញាតច្បាប់ឈប់(៣.៤)។

### ៣.១. អភ័យឯកសិទ្ធិ

នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ គេសង្កេតឃើញថាតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភា មានអភ័យឯកសិទ្ធិសភា បានន័យថាច្បាប់បានផ្ដល់ការការពារដល់តំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភា។ អភ័យឯកសិទ្ធិនេះ ជាសិទ្ធិពិសេសរបស់សភា ពុំមែនជារបស់តំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភារូបណាមួយផ្ដាច់មុខទេ។

យ៉ាងណាមិញ ច្បាប់កំពូលរបស់ជាតិឆ្នាំ១៩៩៣ ពុំបានចែងអំពីអភ័យឯកសិទ្ធិរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។ ប៉ុន្តែក្នុងច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ គេសង្កេតឃើញមាន បទប្បញ្ញត្តិមួយចែងថា ***«សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មិនត្រូវទទួលខុសត្រូវខាងបទព្រហ្មទណ្ឌ ឬ បទរដ្ឋប្បវេណីណាមួយចំពោះការសម្រេចដែលបានធ្វើនៅពេលដែលគេបំពេញភារកិច្ចជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញឡើយ»***[29] ហេតុនេះហើយបានជាមានការបកស្រាយផ្សេងៗគ្នា ពីសំណាក់អ្នកច្បាប់ និងអ្នកជំនាញនានាជុំវិញបញ្ហាអភ័យឯកសិទ្ធិរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។

ដូច្នេះ ចំពោះករណីនេះ គេអាចកត់សម្គាល់ និងសន្និដ្ឋានបានថាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ហាក់ដូចជាទទួលបាន និងមានអភ័យឯកសិទ្ធិមួយចំនួនផងដែរ ដែលច្បាប់បានការពារ។

### ៣.២. វិសមិតភាព

វិសមិតភាព មានន័យថាភាពដែលមិនអាចមាន ឬមិនអាចធ្វើការចូលគ្នាបាន ឬអលទ្ធភាពដែលមិនអាចឲ្យបុគ្គលណាម្នាក់បំពេញមុខងារពីរបាន។ វិសមិតភាពនេះត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ

[29] ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ ជស/រកម/០៤៩៨/០៦, ០៨ មេសា ១៩៩៨, មាត្រា១១។

កម្ពុជាឆ្នាំ១៩៩៣ ដែលអនុវត្តចំពោះមុខងារសមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា សមាជិករាជរដ្ឋាភិបាល និង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។ល។

មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានវិសមិតភាពនឹងមុខងារជា សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល ចៅក្រមក្នុងមុខតំណែង ការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ប្រធាន ឬអនុប្រធានគណបក្សនយោបាយ ប្រធាន ឬអនុប្រធានសហជីព។[30] ដូចនេះ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មិនអាចបំពេញមុខងារត្រួតគ្នាបាននោះទេ ដោយតម្រូវឲ្យសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសុំលាឈប់ជាបណ្ដោះអាសន្នពីមុខតំណែង ឬមុខរបរនោះជាមុនសិន ក្នុងគោលដៅដើម្បីធានា ក៏ដូចជារក្សាឲ្យបានប្រសិទ្ធភាពការងារប្រកាន់យកគោលការណ៍អព្យាក្រឹត្យភាព ព្រមទាំងឯករាជ្យភាពនៃស្ថាប័ន ស្របតាមស្មារតីនៃការបង្កើតក្រុមប្រឹក្សាធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

### ៣.៣. វិន័យ និងចរិយាសម្បត្តិនៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាធម្មនុញ្ញ ជាស្ថាប័នឯករាជ្យ និងអព្យាក្រឹត្យ ក្នុងការបំពេញសមត្ថកិច្ចរបស់ខ្លួន។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មិនត្រូវប្រព្រឹត្តអំពើណាដែលនាំឲ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរ ឯករាជ្យភាព ឬ អព្យាក្រឹត្យភាព នៃមុខតំណែងរបស់ខ្លួនឡើយ។[31]

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងមុខតំណែងរបស់ខ្លួនមិនត្រូវៈ

- កាន់កាប់ជាប្រធាន អនុប្រធានគណបក្សនយោបាយ ប្រធាន អនុប្រធានសហជីព ហើយជាទូទៅបំពេញសកម្មភាព ដែលមិនអាចស្រុះស្រួលគ្នាបានជាមួយបទប្បញ្ញត្តិ នៃប្រការ៣ខាងលើ។
- បណ្ដោយឲ្យធ្វើនិទ្ទេសអំពីតួនាទីរបស់ខ្លួន ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញក្នុងឯកសារដែល អាចយកទៅបោះពុម្ពផ្សាយ និងទាក់ទងទៅនឹងគ្រប់សកម្មភាពសាធារណៈ ឬឯកជន។[32]

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាធម្មនុញ្ញនឹងវាយតម្លៃទៅលើសមាជិករបស់ខ្លួនរូបណា ដែលខ្វះខាតមិនបានបំពេញកាតព្វកិច្ចជាទូទៅ ជាពិសេសកាតព្វកិច្ចដែលមានចែងក្នុងប្រការ ៣ និងប្រការ ៤ថ្មី នៃបទបញ្ជាផ្ទៃក្នុងនេះ។ ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសម្រេចដោយបោះឆ្នោតជាសម្ងាត់ យកតាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូលចំពោះបញ្ហាខាងលើនេះ (៥សម្លេងយ៉ាងតិច)។[33]

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលមិនគោរពបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវផ្ដន្ទាទោសខាងបទវិន័យ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។[34]

[30] មាត្រា១៣៩ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[31] បទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ, ២៦ មិថុនា ១៩៩៨, ប្រការ៣។

[32] សេចក្ដីសម្រេចស្ដីពីវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ,លេខ៣៨/២០១៧ កបធ.សសរ, ៣០ សីហា ២០១៧, ប្រការ៤ថ្មី។

[33] សេចក្ដីសម្រេចស្ដីពីវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ,លេខ៣៨/២០១៧ កបធ.សសរ, ៣០ សីហា ២០១៧, ប្រការ៨ថ្មី។

[34] បទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ, ២៦ មិថុនា ១៩៩៨, ប្រការ២២ វាក្យខណ្ឌទី១។

សមាជិកដែលមិនគោរពបទបញ្ជាផ្ទៃក្នុង ត្រូវផ្តន្ទាទោសខាងបទវិន័យ។

ទណ្ឌកម្មខាងវិន័យចំពោះក្រុមប្រឹក្សាធម្មនុញ្ញមានៈ

១-ក្រើនរំឮកដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

២-ក្រើនរំឮកដោយចុះកំណត់ហេតុនៅលើកទី២ ដោយប្រធាន

៣-ស្តីបន្ទោសដោយធ្វើជាលាយលក្ខណ៍អក្សរ។[35]

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវក្រើនរំឭកសមាជិករូបណាដែលធ្វើខុសដដែលក្នុងរយៈពេល៣០ ថ្ងៃ ឬធ្វើឲ្យខូចខាតដល់សណ្តាប់ធ្នាប់ដោយ ល្មើសនឹងប្រការ១៥ នៃបទបញ្ជាផ្ទៃក្នុងនេះ។ សមាជិកណាដែលត្រូវក្រើនរំ-ឮក ៣ដងហើយនៅតែប្រព្រឹត្តខុស ត្រូវក្រើនរំឮកដោយមានចុះក្នុងកំណត់ហេតុ។ វិន័យនេះ នាំឲ្យមានការកាត់ប្រាក់បំណាច់ប្រចាំខែរបស់សមាជិករូបនោះចំនួន១ភាគ៤។[36]

ត្រូវទទួលទណ្ឌកម្មវិន័យស្តីបន្ទោស ចំពោះសមាជិកណាដែលៈ

- នាំឲ្យជ្រួលច្របល់ក្នុងសាលប្រជុំ ឬក្រៅសាលប្រជុំ ឬនាំអាទិ៍ឲ្យសមាជិកច្រើននាក់មិនចូលរួមធ្វើការក្នុងក្រុមប្រឹក្សាធម្មនុញ្ញ
- ប្រមាថមើលងាយ ឬ បង្កជម្លោះ ឬ គំរាមកំហែងសមាជិកដទៃទៀត ឬ ញុះញង់សមាជិកឯទៀតឲ្យប្រើប្រាស់ហិង្សា
- មើលងាយក្រុមប្រឹក្សាធម្មនុញ្ញ ឬប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
- ប្រមាថមើលងាយព្រះមហាក្សត្រ

វិន័យស្តីបន្ទោស នាំឲ្យកាត់ប្រាក់បំណាច់ប្រចាំខែរបស់សមាជិកនោះចំនួន ៥០ ភាគរយ ក្នុងរយៈពេលចំនួន ២ខែ។[37]

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលត្រូវទទួលវិន័យតាមប្រការ២៣ ប្រការ២៤ និងប្រការ២៥ នៃបទបញ្ជាផ្ទៃក្នុងនេះ ក្រោយពីបានទទួលដឹងសំណុំរឿងផ្ទាល់ខ្លួន ត្រូវធ្វើការដោះសារក្នុងរយៈពេល៥ថ្ងៃ។ ផុតកំណត់នេះទោះសាមីខ្លួនបានធ្វើការដោះសារ ឬមិនដោះសារក្តី ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចដាក់វិន័យតាមមតិភាគច្រើនដូចដែលមានចែងក្នុងប្រការ១៨ថ្មី និងប្រការ១៩ នៃបទបញ្ជាផ្ទៃក្នុងនេះ។[38] ក្នុងការអនុម័តតាមមតិភាគច្រើនដាច់ខាត នៃសមាជិកទាំងមូល បើចំនួនមតិយល់ព្រម និងមតិមិនយល់ព្រមស្មើគ្នា (ក្នុងករណីបែកសម្លេងជាពីរស្មើគ្នា) សម្លេងរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានឧត្តមានុភាព។

[35] បទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ, ២៦ មិថុនា ១៩៩៨, ប្រការ២២ វាក្យខណ្ឌទី៣។

[36] បទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ, ២៦ មិថុនា ១៩៩៨, ប្រការ២៤។

[37] បទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ, ២៦ មិថុនា ១៩៩៨, ប្រការ២៥។

[38] វិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ ២៤/២០០៧ កបធ.សសរ, ០៧ សីហា ២០០៧, ប្រការ២៦ថ្មី។

ដូចនេះ ក្នុងនាមជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែគោរពទៅតាមវិន័យ និងអនុវត្តតួនាទីរបស់ខ្លួនឲ្យបានត្រឹមត្រូវ និងទទួលខុសត្រូវខ្ពស់ជាទីបំផុត ដើម្បីរក្សាឲ្យបានកិត្យានុភាពស្ថាប័ន សេចក្ដីថ្លៃថ្នូររបស់ខ្លួន និងចៀសផុតពីការទទួលទោសខាងវិន័យ និងទណ្ឌកម្មផ្សេងៗទៀត ដូចមានចែងក្នុងច្បាប់ និងបទបញ្ជាផ្ទៃក្នុងរបស់ស្ថាប័ន។

### ៣.៤. ការឈប់សម្រាក និងការអនុញ្ញាតច្បាប់ឈប់

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានបំណងសុំឈរឈ្មោះ ជាបេក្ខជនតំណាងរាស្ត្រ ឬជាបេក្ខជនសមាជិកព្រឹទ្ធសភា ត្រូវសុំច្បាប់ឈប់ពិសេស ៧ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត។ ការសុំនេះត្រូវទទួលបានការអនុញ្ញាត។[39]

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មិនអាចអវត្តមានដោយគ្មានការអនុញ្ញាតពីប្រធានបានឡើយ។ ប្រធានមានសិទ្ធិអនុញ្ញាតឲ្យឈប់សម្រាកយ៉ាងយូរ១៥ថ្ងៃ។ ការឈប់លើសពី១៥ថ្ងៃ ត្រូវសុំឲ្យអង្គប្រជុំក្រុមប្រឹក្សាធម្មនុញ្ញយល់ព្រម។ សមាជិក ដែលមានជម្ងឺរយៈពេល ៥ថ្ងៃជាប់ៗគ្នា ត្រូវមានសំបុត្រពេទ្យជាសំអាង។[40]

មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាន ត្រូវបំពេញការងារស្របតាមច្បាប់ស្ដីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ និងត្រូវបានឈប់សម្រាកការងារប្រចាំឆ្នាំតាមការកំណត់របស់រដ្ឋ លើកលែងតែក្នុងករណីចាំបាច់ដូចមានចែងក្នុងច្បាប់ដោយឡែក។[41]

[39] វិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ ២៤/២០០៧ កបធ.សសរ, ០៧ សីហា ២០០៧, ប្រការ៦ថ្មី។

[40] បទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ, ២៦ មិថុនា ១៩៩៨, ប្រការ២១។

[41] វិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ,លេខ ២៤/២០០៧ កបធ.សសរ, ០៧ សីហា ២០០៧, ប្រការ៩ថ្មី(ពីរ)។

# ជំពូកទី២

# សមត្ថកិច្ច

# ក្នុងការបកស្រាយ

# រដ្ឋធម្មនុញ្ញ ច្បាប់

# បទបញ្ជាផ្ទៃក្នុងរដ្ឋសភា

# និងព្រឹទ្ធសភា

# ជំពូកទី២
# សមត្ថកិច្ចក្នុងការបកស្រាយរដ្ឋធម្មនុញ្ញ ច្បាប់ បទបញ្ញាផ្ទៃក្នុងរដ្ឋសភា និង ព្រឹទ្ធសភា

ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មានសមត្ថកិច្ចធានាការពារ ការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញនិងច្បាប់ដែលរដ្ឋសភា និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ព្រមទាំងមានសិទ្ធិពិនិត្យ ហើយសម្រេចអំពីករណីវិវាទកម្មនានាទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាផងដែរ។ សមត្ថកិច្ចក្នុងការបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ត្រូវបានគេមើលឃើញថា ជាសមត្ថ-កិច្ចចម្បងមួយដែលមិនអាចអវត្តមានបាន ក្នុងសង្គមនីតិរដ្ឋ។ ការបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ផ្សាភ្ជាប់យ៉ាងសំខាន់ទៅនឹងការធានាការពារការគោរពរដ្ឋធម្មនុញ្ញ។ តួយ៉ាង ការធានាការពារការគោរពរដ្ឋធម្មនុញ្ញ សំដៅដល់ការការពារ និងទប់ស្កាត់ជាដាច់ខាតកុំឲ្យច្បាប់ ដែលអនុម័តដោយអង្គការនីតិប្បញ្ញត្តិ និងសេចក្តីសម្រេចរបស់អង្គការរដ្ឋនានាមិនស្រប ឬផ្ទុយនឹងខ្លឹមសារ និងគោលការណ៍នៃរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ជាតិ។ យ៉ាងណាមិញ ប្រសិនបើអនុញ្ញាតឲ្យមានការបំពាន ឬរំលោភលើរដ្ឋធម្មនុញ្ញ វានឹងធ្វើឲ្យច្បាប់គ្រឹះរបស់រដ្ឋបាត់បង់ឧត្តមភាព មានតែឈ្មោះ និងប្រៀបបានដូចជា ការផ្តួលរំលំ ឬបំផ្លិចបំផ្លាញរដ្ឋធម្មនុញ្ញរួចបាត់ទៅហើយ។ ហេតុនេះហើយ ជាការចាំបាច់ណាស់ដែល តម្រូវឲ្យមានការបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដើម្បីធានាថាការអនុវត្តរដ្ឋធម្មនុញ្ញ និងច្បាប់មានភាពត្រឹមត្រូវ ច្បាស់លាស់ និងមានឯកភាពនៅទូទាំងប្រទេស ក្នុងគោលដៅបញ្ចៀសនូវភាពអនាធិបតេយ្យ និងអស្ថិរភាពគតិយុត្ត ដែលជាគុណវិបត្តិដ៏អាក្រក់ចំពោះការជះឥទ្ធិពលទៅលើប្រសិទ្ធភាពនៃដំណើរការកសាងនីតិរដ្ឋ និងសង្គមប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា។

ម្យ៉ាងវិញទៀត មានការលើកឡើងគំនិត ក៏ដូចជាមតិផ្សេងៗគ្នាជុំវិញការពិចារណា ថាតើស្ថាប័នតុលាការមានសិទ្ធិបកស្រាយច្បាប់ដែរឬយ៉ាងណានៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អំណាចតុលាការ ជាអំណាចឯករាជ្យ ដែលធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។[42] អំណាចតុលាការ ដែលត្រូវបានប្រគល់ទៅឲ្យសាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ មានអំណាចកាត់ក្តី និងស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋគ្រប់រូប តាមរយៈការសម្រេចសេចក្តីរបស់ចៅក្រម ដែលបំពេញភារកិច្ចរបស់ខ្លួនដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ អស់ពីដួងចិត្ត ព្រមទាំងសតិសម្បជញ្ញៈរបស់ខ្លួន។ ការណ៍នេះហើយ បណ្តាលឲ្យមានទស្សនៈពីរផ្ទុយគ្នាត្រូវបានលើកឡើងថា **«តុលាការមានសិទ្ធិបកស្រាយច្បាប់»** និង ទស្សនៈមួយទៀត ត្រូវបានលើកឡើងថា **«តុលាការ ពុំមានសិទ្ធិបកស្រាយច្បាប់»**។

[42] មាត្រា១២៨ថ្មី វាក្យខណ្ឌទី១ និងទី២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

តុលាការ មានសិទ្ធិបកស្រាយច្បាប់ ដើម្បីឈានទៅដល់ការជំនុំជម្រះរឿងក្តី ក្នុងគោលដៅចេញសេចក្តីសម្រេច(សាលក្រម ឬសាលដីកា) ដែលគេចាត់ទុកជា យុត្តិសាស្ត្ររបស់តុលាការ។ យុត្តិសាស្ត្ររបស់តុលាការបានបញ្ជាក់ឲ្យឃើញថា តុលាការមានសិទ្ធិបកស្រាយច្បាប់។ ប៉ុន្តែការបកស្រាយ និងចេញសេចក្តីសម្រេចរបស់តុលាការ អាចមានផ្លូវតវ៉ា និងមានអានុភាពអនុវត្តចំពោះតែគូភាគី និងជនដែលមានផលប្រយោជន៍ពាក់ព័ន្ធតែប៉ុណ្ណោះ។ ផ្ទុយទៅវិញ តុលាការ ពុំមានសិទ្ធិបកស្រាយច្បាប់ទេ ដោយសារតែចៅក្រមមានសិទ្ធិថ្លឹងថ្លែង និងជំនុំជម្រះក្តីតែប៉ុណ្ណោះ។ ការពិចារណា និងវិនិច្ឆ័យក្តីអាចប្រព្រឹត្តទៅបាន លុះត្រាដែលច្បាប់ដែលចែងមកសម្រាប់អនុវត្តនោះ មានលក្ខណៈច្បាស់លាស់។ ការសម្រេចសេចក្តី និងការយល់ឃើញរបស់ចៅក្រម សំដៅដល់ការកំណត់ឈ្មោះបទល្មើស និងទំហំទណ្ឌកម្ម ដែលមានចែងក្នុងច្បាប់។ ចៅក្រមត្រូវកាត់ក្តីទៅតាមច្បាប់ និងអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ហើយមិនអាចបោះបង់សំណុំរឿងណាមួយបានឡើយ។

ដូច្នេះ ចៅក្រមមានសិទ្ធិ ឬសមត្ថភាពក្នុងការបកស្រាយច្បាប់ ក្នុងក្របខណ្ឌសម្រាប់ធ្វើការវិនិច្ឆ័យក្តីទៅលើតែអង្គហេតុរបស់គូភាគីតែប៉ុណ្ណោះ(ឈ្មោះបទល្មើស និងកម្រិតទណ្ឌកម្ម)។ អាស្រ័យហេតុនេះ មានតែក្រុមប្រឹក្សាធម្មនុញ្ញមួយគត់ ដែលមានសមត្ថកិច្ចបកស្រាយច្បាប់ និងចេញសេចក្តីសម្រេចមួយបិទផ្លូវតវ៉ា ឬសេចក្តីសម្រេចអធិបតេយ្យ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។[43] គួរបញ្ជាក់ផងដែរថា ក្រុមប្រឹក្សាធម្មនុញ្ញ ធ្វើការបកស្រាយចំពោះច្បាប់ណាដែលត្រូវបានប្រកាសឲ្យប្រើរួចហើយតែប៉ុណ្ណោះ។

## ផ្នែកទី១៖ អង្គភាពជាសេនាធិការរៀបចំក្នុងការបកស្រាយ

ក្រុមប្រឹក្សាធម្មនុញ្ញ ជាស្ថាប័នកំពូលមួយ ដូចទៅនឹងស្ថាប័នកំពូលដទៃទៀតដែលមានចែងក្នុងរដ្ឋធម្មនុញ្ញផងដែរ ដោយមានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការសម្រាប់ទទួលបន្ទុកការងារមួយចំនួន ដើម្បីអនុវត្តសកម្មភាពការងាររបស់ស្ថាប័នប្រកបដោយនិរន្តរភាព និងប្រក្រតីភាព។ យើងនឹងធ្វើការសិក្សាទៅលើអគ្គលេខាធិការដ្ឋាន(១.១) និងនាយកដ្ឋានសេវាច្បាប់ និងវិវាទកម្ម(១.២) អំពីភារកិច្ចរៀបចំក្នុងការបកស្រាយច្បាប់។

### ១.១. អគ្គលេខាធិការដ្ឋាន

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៨។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ដឹកនាំដោយអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយចំនួនជាជំនួយការ ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។ ជាងនេះទៅទៀតអគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីជាន់ខ្ពស់មានបទពិសោធន៍ក្នុងកិច្ចការរដ្ឋបាលយ៉ាងតិចចំនួន១០ឆ្នាំ ហើយដែលមិនមែនជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និងមិនមែនជាអ្នកដឹកនាំក្នុងគណបក្សនយោបាយ។[44]

---

[43] មាត្រា១៤២ថ្មី វាក្យខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[44] អនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤២ អនក្រ.បកស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ១៣៨ អនក្រ.បក, ០៧ កក្កដា ២០១៦, មាត្រា២ថ្មី។

អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសេចក្ដីស្នើសុំរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ក្រោយពីបានពិគ្រោះយោបល់ជាមួយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានវត្តមាន។[45]

អគ្គលេខាធិការមានតួនាទី និងភារកិច្ចដូចតទៅ:

- ដឹកនាំបញ្ជាការងាររដ្ឋបាលរបស់ក្រុមប្រឹក្សាធម្មនុញ្ញ
- ទទួលសិទ្ធិពីប្រធានក្រុមប្រឹក្សាធម្មនុញ្ញដើម្បីចុះហត្ថលេខាលើលិខិត ឬ សេចក្ដីសម្រេចរដ្ឋបាលនានា
- ទទួលចុះបញ្ជី និងពិនិត្យមើលសំណុំរឿង ឬសំណើសុំបកស្រាយរដ្ឋធម្មនុញ្ញ ច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងព្រឹទ្ធសភា
- រៀបចំ ធ្វើកំណត់ហេតុសម្រាប់ការប្រជុំ (ពិនិត្យ និងសម្រេចពាក់ព័ន្ធនឹងសំណើសុំបកស្រាយច្បាប់ ឬសំណុំរឿងដទៃទៀត)
- រៀបចំ និងរក្សាកំណត់ហេតុ រួមទាំងឯកសារផ្សេងៗ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ហើយធានាមិនឲ្យមានការបែកខ្ចរខ្ចាយទៅក្រៅដោយគ្មានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាធម្មនុញ្ញឡើយ។

### ១.២. នាយកដ្ឋានសេវាច្បាប់ និងវិវាទកម្ម

នាយកដ្ឋានសេវាច្បាប់ និងវិវាទកម្ម ស្ថិតនៅក្រោមឱវាទរបស់អគ្គនាយកដ្ឋានសេវាច្បាប់ និងបច្ចេកទេស ដែលត្រូវគ្រប់គ្រងដោយ ប្រធាននាយកដ្ឋានមួយរូប និងអនុប្រធាននាយកដ្ឋានមួយចំនួនសមស្រប។ នាយកដ្ឋាននេះត្រូវបែងចែកជាការិយាល័យចំនួន៣ ដែលស្ថិតនៅក្រោមបង្គាប់គឺ: ការិយាល័យទី១ ការិយាល័យទី២ និងការិយាល័យទី៣។[46] ការិយាល័យនីមួយៗ មានប្រធានការិយាល័យមួយរូប និងអនុប្រធានការិយាល័យមួយចំនួនសមស្រប។

នាយកដ្ឋានសេវាច្បាប់ និងវិវាទកម្ម មានតួនាទី និងភារកិច្ចដូចខាងក្រោម:

- ទទួលពាក្យបណ្ដឹង ឬសំណើ និងចុះបញ្ជីក្នុងសៀវភៅទទួលសំណុំរឿង
- ទទួលលិខិតជូនដំណឹងពីស្ថាប័នពាក់ព័ន្ធ និងកត់ត្រាចូលក្នុងសៀវភៅលិខិតចូល
- ធ្វើកំណត់ហេតុបង្ហាញរឿងជូនថ្នាក់ដឹកនាំ
- ធ្វើជាជំនួយការសមាជិករាយការណ៍របស់ក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងការស្រាវជ្រាវច្បាប់ និងលិខិតបទដ្ឋានទាំងឡាយដែលពាក់ព័ន្ធនឹងបណ្ដឹង ឬសំណើសុំបកស្រាយរដ្ឋធម្មនុញ្ញ ច្បាប់ ព្រមទាំងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងព្រឹទ្ធសភា

---

[45] អនុក្រឹត្យស្ដីពីការកែសម្រួលអនុក្រឹត្យលេខ៤២ អនក្រ.បកស្ដីពីការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ៤៣ អនក្រ.បក , ០៧ មីនា ២០០៥, មាត្រា៣ថ្មី។

[46] អនុក្រឹត្យស្ដីពីការកែសម្រួលអនុក្រឹត្យលេខ៤២ អនក្រ.បកស្ដីពីការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ៤៣ អនក្រ.បក , ០៧ មីនា ២០០៥, មាត្រា៤ថ្មី។

- ស្រាវជ្រាវរកឯកសារទាំងឡាយ សម្រាប់ជាបច្ច័យឈានទៅដល់ការដោះស្រាយបណ្តឹង និងសំណើសុំបកស្រាយរដ្ឋធម្មនុញ្ញ ច្បាប់ ព្រមទាំងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងព្រឹទ្ធសភា ស្របតាមសំណើយ៉ាងហ្មត់ចត់
- អនុវត្តការងារផ្សេងៗតាមការប្រគល់ជូនពីថ្នាក់ដឹកនាំ។

## ផ្នែកទី២៖ លក្ខខណ្ឌ និងគោលការណ៍ជាមូលដ្ឋាននៃការបកស្រាយ

ក្រុមប្រឹក្សាធម្មនុញ្ញ ជាអង្គការនិយ័តករផ្ទៃក្នុងដែលដើរតួនាទី ជាអ្នកធ្វើឲ្យមានរបៀបរៀបរយ នៃអំណាចរដ្ឋទាំងបី។ អង្គការនេះ ជាស្ថាប័នតែមួយគត់ដែលមានសមត្ថកិច្ចបកស្រាយរដ្ឋធម្មនុញ្ញ ច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងព្រឹទ្ធសភា ព្រមទាំងចេញសេចក្តីសម្រេចមួយបិទផ្លូវតវ៉ា ដែលត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។ មុននឹងឈានទៅដល់ការបកស្រាយចំពោះសំណើនានា ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវគោរពទៅលើលក្ខខណ្ឌដែលជាចំណុចសារវន្ត ក្នុងការត្រួសត្រាយផ្លូវសម្រាប់ការបកស្រាយ។ បន្ទាប់មកទៀតក្រុមប្រឹក្សាធម្មនុញ្ញ នឹងធ្វើការស្រាយបំភ្លឺ ស្របទៅតាមគោលការណ៍នានាដែលស្ថាប័ននេះប្រកាន់យក ក្នុងគោលដៅដើម្បីចេញសេចក្តីសម្រេចមួយដែលអាចទទួលយកបាន ប្រកបដោយសុចរិតភាព ឯករាជ្យភាព អព្យាក្រឹត្យភាព តម្លាភាព និងផ្អែកលើឧត្តមប្រយោជន៍ជាតិជាធំ។

### ២.១. លក្ខខណ្ឌនៃការស្នើសុំបកស្រាយ

ក្រុមប្រឹក្សាធម្មនុញ្ញ មិនអាចធ្វើស្វ័យសំណើ ឬបណ្តឹងដោយខ្លួនឯងបានទេ ពោលគឺពុំអាចយករឿង ឬបញ្ហាណាមួយមកពិនិត្យ និងវិនិច្ឆ័យដោយខ្លួនឯង ប្រសិនបើគ្មានអ្នកមានសមត្ថកិច្ចស្នើសុំ ឬប្តឹងបានឡើយ ដែលមានន័យថា ស្ថាប័ននេះធ្វើការពិនិត្យ និងសម្រេចទៅបាន លុះត្រាតែមានការស្នើពីខាងក្រៅ សំដៅលើបុគ្គលដែលមានសមត្ថកិច្ចស្នើសុំដែលច្បាប់បានចែង និងបានទទួលស្គាល់។[47] អ្នកដែលមានសិទ្ធិក្នុងការលើកសំណើ ឬធ្វើបណ្តឹង ត្រូវបានបែងចែកដាច់ដោយឡែក ពីករណីមួយទៅករណីមួយទៀត ដោយយោងទៅតាមប្រភេទ និងកម្មវត្ថុនៃបណ្តឹង ឬសំណើ។ មុននឹងឈានទៅដល់ដំណាក់កាលនៃការបកស្រាយរដ្ឋធម្មនុញ្ញ ច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងព្រឹទ្ធសភា យើងនឹងសិក្សាទៅលើលក្ខខណ្ឌនៃការស្នើសុំបកស្រាយ មានដូចជា៖ សមត្ថភាពបុគ្គលដែលមានសិទ្ធិស្នើសុំ(២.១.១) ការពិនិត្យលើទម្រង់ ឬបែបបទ(២.១.២) និងគោលបំណងនៃសំណើសុំបកស្រាយ(២.១.៣)។

#### ២.១.១. សមត្ថភាពបុគ្គលដែលមានសិទ្ធិស្នើសុំ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានចែងអំពី ការបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។ ប៉ុន្តែតាមរយៈបទប្បញ្ញត្តិនេះ គេសង្កេតឃើញថា ច្បាប់កំពូលរបស់ជាតិឆ្នាំ១៩៩៣ នេះពុំមានចែងអំពីបុគ្គល ឬឥស្សរជនណាដែលមានសិទ្ធិស្នើសុំបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ឲ្យមានភាពជាក់លាក់ឡើយ។ ភាពស្រពិចស្រពិលនេះ

[47] ឈុន ណារ៉េត, *សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ*, បោះពុម្ពលើកទី២ (ភ្នំពេញ៖ ផាងពុម្ពដារ៉ា, ២០១៦), ៧០។

បានធ្វើឲ្យមានទស្សនៈមួយចំនួនត្រូវបានលើកឡើងថា បុគ្គលគ្រប់រូបមានសិទ្ធិស្នើសុំទៅកាន់ក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងគោលដៅដើម្បីឲ្យស្ថាប័ននេះធ្វើការបកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ។

ដូចគ្នានេះដែរ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក៏ពុំមានបញ្ញត្តិអំពីបុគ្គល ឬឥស្សរជនណាដែលមានសិទ្ធិស្នើសុំបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ឲ្យមានភាពច្បាស់លាស់ឡើយ។ ការណ៍នេះវាហាក់ដូចជា មានឧបសគ្គក្នុងការបកស្រាយ ដោយហេតុថា គ្មានច្បាប់ណាមួយកម្រិតជាក់លាក់ពីបញ្ហានេះ។ យ៉ាងណាមិញ គេប្រទះឃើញមាត្រា១៥ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា ***«ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញនិងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ក្នុងក្របខណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់»។*** ទោះបីជាច្បាប់ពុំបានធ្វើការបញ្ញត្តិឲ្យចំតែម្តងអំពីសមាសភាពបុគ្គល ឬឥស្សរជនណាដែលមានសិទ្ធិស្នើសុំបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ក៏ដោយ ប៉ុន្តែយើងអាចសន្និដ្ឋាន និងកំណត់បានតាមរយៈមាត្រាខាងលើនេះ។ ខ្លឹមសារនៃ ការបកស្រាយរដ្ឋធម្មនុញ្ញនិងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ក្នុងក្របខណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ បានបង្កប់អត្ថន័យដោយចង្អុលបង្ហាញពីបុគ្គល ឬឥស្សរជន ដែលមានសិទ្ធិស្នើសុំដូចដែលមានចែងនៅក្នុងមាត្រា១៤០ថ្មី និងមាត្រា១៤១ថ្មីនៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ព្រមទាំងមាត្រា១៦ថ្មី មាត្រា១៧ថ្មី និងមាត្រា១៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

ដូចនេះ បុគ្គល ឬឥស្សរជន ដែលមានសិទ្ធិស្នើសុំបកស្រាយរដ្ឋធម្មនុញ្ញ ឬច្បាប់មានដូចជាៈ

- ព្រះមហាក្សត្រ
- ប្រធានព្រឹទ្ធសភា
- ប្រធានរដ្ឋសភា
- នាយករដ្ឋមន្ត្រី
- សមាជិកព្រឹទ្ធសភា ចំនួនមួយភាគបួន
- តំណាងរាស្ត្រ ចំនួនមួយភាគដប់
- តុលាការ ករណីរឿងបន្ទាន់បង្វំ
- ប្រជារាស្ត្រ តាមរយៈប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន និងអ្នកតំណាងរាស្ត្រមួយភាគដប់។[48]

[48] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ នស/រកម/០១០៧/០០៥, ៣១ មករា ២០០៧, មាត្រា១៨ថ្មី។

### ២.១.២. ការពិនិត្យលើទម្រង់ ឬបែបបទ

ការពិនិត្យលើទម្រង់ ឬបែបបទនៃសំណើមានសារៈសំខាន់ ដើម្បីជាកិច្ចបើកផ្លូវសម្រាប់ឈានចូលទៅដល់ការចុះបញ្ជីនៅក្នុងអគ្គលេខាធិការដ្ឋាន និងការប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិភាក្សា ព្រមទាំងចេញសេចក្តីសម្រេចបកស្រាយ។ ដោយឡែក ទម្រង់ ឬបែបបទនៅក្នុងបរិបទសារណានេះ សំដៅដល់ ការអនុវត្តត្រឹមត្រូវតាមនីតិវិធីច្បាប់ ដោយមិនសំដៅលើការតាក់តែង ឬការសរសេរ ដែលជាទម្រង់នៃលិខិតរដ្ឋបាលឡើយ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ បានផ្តល់អំណាចជូនទៅកាន់ព្រះមហាក្សត្រ ដែលទ្រង់ជាអ្នកឡាយព្រះហស្ថលេខាលើព្រះរាជក្រមប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ និងទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រឹត្យតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី។ ក្នុងខណៈពេលដែលព្រះមហាក្សត្រប្រឈួន ហើយត្រូវព្យាបាលព្រះរោគនៅបរទេស អំឡុងពេលនោះព្រះមហាក្សត្រមានសិទ្ធិផ្ទេរអំណាចឡាយព្រះហស្ថលេខាលើព្រះរាជក្រម ឬព្រះរាជក្រឹត្យខាងលើនេះទៅប្រមុខរដ្ឋស្តីទីចុះហត្ថ-លេខាជំនួស តាមរយៈព្រះរាជសារប្រគល់សិទ្ធិ។[49]

ដូច្នេះ ការប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ត្រូវប្រើក្នុងទម្រង់ជា **ព្រះរាជក្រម** ដោយមានព្រះហស្ថលេខារបស់ព្រះមហាក្សត្រ ឬហត្ថលេខារបស់ប្រមុខរដ្ឋស្តីទី តាមរយៈព្រះរាជសារប្រគល់សិទ្ធិ ក្នុងករណីដែលព្រះមហាក្សត្រប្រឈួន ឬ អវត្តមានដោយទ្រង់ទៅព្យាបាលព្រះរោគនៅឯបរទេស។ ការប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញ និងច្បាប់ដែលផ្ទុយនឹងការរៀបរាប់ខាងលើ ជាការបំពាន ឬដើរផ្ទុយពីរដ្ឋធម្មនុញ្ញទាំងស្រុង។ អាស្រ័យហេតុនេះហើយ ប្រសិនបើមានការស្នើសុំបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ពីបុគ្គល ឬតស្សរជនណាមួយដែលមានសិទ្ធិស្នើសុំ ក្រុមប្រឹក្សាធម្មនុញ្ញនឹងពិនិត្យលើកម្មវត្ថុនៃសំណើសុំបកស្រាយ ថាតើវាត្រឹមត្រូវ ឬផ្ទុយនឹងករណីខាងលើដែរឬទេ។ ក្នុងស្ថានភាពច្បាប់ដែលត្រូវបានអាជ្ញាធរមានសមត្ថ-កិច្ច ស្នើសុំបកស្រាយនោះ មិនត្រឹមត្រូវទៅតាមទម្រង់ ឬបែបបទ នាំឲ្យស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ ពុំចាំបាច់ធ្វើការបកស្រាយនោះទេ ក្រោមហេតុផលថាកម្មវត្ថុនៃសំណើបានប្រាសចាកពីគន្លងច្បាប់រួចបាត់ទៅហើយ។

### ២.១.៣. គោលបំណងនៃសំណើសុំបកស្រាយ

មុននឹងទទួលពិនិត្យ និងពិភាក្សាលើសំណើសុំបកស្រាយ ក្រុមប្រឹក្សាធម្មនុញ្ញ ក៏ធ្វើការត្រួតពិនិត្យផងដែរថា តើក្នុងករណីស្នើសុំបកស្រាយមាត្រាណាមួយនៃរដ្ឋធម្មនុញ្ញ ឬច្បាប់នានា មានបញ្ជាក់អំពីបញ្ហាដែលកើតមានឡើងដែរឬទេ។ បុគ្គល ឬតស្សរជនដែលមានសិទ្ធិស្នើសុំ មិនអាចស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញធ្វើបទឧទ្ទេសនាមអំពីមាត្រាណាមួយនៃរដ្ឋធម្មនុញ្ញ ឬច្បាប់ឡើយ។[50] នេះសរបញ្ជាក់ឲ្យឃើញថា ការស្នើសុំបកស្រាយមាត្រាណាមួយនៃរដ្ឋធម្មនុញ្ញ ឬច្បាប់ តម្រូវឲ្យមានការបញ្ជាក់ពីបញ្ហាដែលកើតមានឡើងជាក់ស្តែងក្នុងការអនុវត្ត ឬ

[49] មាត្រា២៨ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[50] ណើ ណារី, *សមត្ថកិច្ចក្រុមប្រឹក្សាធម្មនុញ្ញ*, (សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១២), ២៧។

មូលហេតុត្រឹមត្រូវ និងប្រាកដប្រជា ឬភាពចាំបាច់ណាមួយ ដែលនាំឲ្យមានការស្នើសុំបកស្រាយនោះ។ ការទាមទារឲ្យបញ្ជាក់បែបនេះ ដោយសារតែក្នុងមាត្រានីមួយៗ ពិតជាមានរឿងច្រើនដែលត្រូវរែកញែក និងពិភាក្សា ហើយការបកស្រាយអាចប្រព្រឹត្តទៅបានលុះត្រាតែមានកម្មវត្ថុច្បាស់លាស់។

ជាគោលការណ៍ ដើម្បីអាចបកស្រាយមាត្រាណាមួយនៃរដ្ឋធម្មនុញ្ញ ឬច្បាប់ បុគ្គល ឬតស្សរជនដែលជាម្ចាស់សំណើ ត្រូវតែធ្វើការបញ្ជាក់អំពីមូលហេតុជាដាច់ខាត ក្នុងគោលដៅដើម្បីឲ្យក្រុមប្រឹក្សាធម្មនុញ្ញអាចដឹងថា តើគេចង់បានអ្វី ទើបក្រុមប្រឹក្សាធម្មនុញ្ញអាចបកស្រាយបានស្របទៅតាមទិសដៅនោះ។ ក្នុងករណីនេះ ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យឃើញថា បុគ្គល ឬតស្សរជនដែលមានសិទ្ធិស្នើសុំបកស្រាយ បានបង្ហាញអំពីមូលហេតុ ឬគោលបំណងត្រឹមត្រូវដែលអនុញ្ញាតឲ្យក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកមកពិនិត្យបាន ទើបក្រុមប្រឹក្សាធម្មនុញ្ញទទួលយកមកពិនិត្យ និងពិភាក្សា ពីព្រោះស្ថាប័ននេះបកស្រាយច្បាប់ក្នុងក្របខណ្ឌត្រួតពិនិត្យធម្មនុញ្ញភាព។ អាស្រ័យហេតុនេះ ក្នុងករណីមានបុគ្គល ឬតស្សរជនដែលមានសិទ្ធិស្នើសុំ បានធ្វើសំណើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវធ្វើការត្រួតពិនិត្យធម្មនុញ្ញភាពជាមុនសិន។ លើសពីនេះទៅទៀត ក្នុងករណីដែលច្បាប់នោះ ស្របតាមរដ្ឋធម្មនុញ្ញ បានសេចក្តីថាអនុលោមតាមគោលការណ៍ និងខ្លឹមសារនៃច្បាប់កំពូលរបស់ជាតិ ទើបនាំឲ្យស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញអាចបកស្រាយបាន។ ដោយឡែក ក្រុមប្រឹក្សាធម្មនុញ្ញ មិនអាចបកស្រាយច្បាប់ណាដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញបានឡើយ។

ដូច្នេះ គេអាចសន្និដ្ឋានបានថា ការបញ្ជាក់អំពីមូលហេតុ និងគោលបំណងនៃសំណើសុំបកស្រាយមាត្រាណាមួយនៃរដ្ឋធម្មនុញ្ញ ឬច្បាប់ ពិតជាមានសារៈសំខាន់ណាស់ ពីព្រោះវាប្រៀបបានជារង្វាស់ ឬខ្នាតមួយដ៏ជាក់លាក់សម្រាប់អនុញ្ញាតឲ្យក្រុមប្រឹក្សាធម្មនុញ្ញអាចបកស្រាយបានប្រកបដោយសុក្រឹត្យភាព និងចំទិសដៅ។

## ២.២. គោលការណ៍វិនិច្ឆ័យជាសារវន្តនៃការបកស្រាយ

ការបកស្រាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ សំដៅលើការបំភ្លឺ ពន្យល់ និងបញ្ជាក់អំពីអត្ថន័យ ខ្លឹមសារ រួមទាំងភាពច្បាស់លាស់នៃមាត្រា ឬបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ និងច្បាប់តបទៅនឹងកម្មវត្ថុ ព្រមទាំងគោលបំណងនៃសំណើសុំបកស្រាយពីសំណាក់បុគ្គល ឬតស្សរជនដែលមានសិទ្ធិស្នើសុំឲ្យបកស្រាយ។ ម៉្យាងវិញទៀត រាល់ការបកស្រាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែស្របតាមរដ្ឋធម្មនុញ្ញជាដាច់ខាត។ ស្ថាប័ននេះ បកស្រាយទៅតាមរបៀបរបបមួយ ដែលគោរពទៅតាមស្តង់ដារអន្តរជាតិដែលជាគោលការណ៍របស់ប្រទេសធំៗ ឬប្រទេសដែលមានទំនើបកម្មផ្នែកច្បាប់ ជាពិសេសក្នុងប្រព័ន្ធច្បាប់អង់គ្លូសាក់សុង និងប្រព័ន្ធច្បាប់រ៉ូម៉ាំង។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដោយផ្អែកទៅលើគោលការណ៍វិនិច្ឆ័យមួយចំនួន ដូចជាៈ គោលការណ៍ឆន្ទៈសភាធម្ម-នុញ្ញ(២.២.១) គោលការណ៍មូលហេតុនៃច្បាប់(២.២.២) និងគោលការណ៍ទ្រឹស្តី និងស្មារតីនៃច្បាប់(២.២.៣)។[51]

[51] ណើ ណារី, *សមត្ថកិច្ចក្រុមប្រឹក្សាធម្មនុញ្ញ*, (សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១២), ២៨។

### ២.២.១. គោលការណ៍ឆន្ទៈសភាធម្មនុញ្ញ

សភាធម្មនុញ្ញ ជាអ្នកតាក់តែង ពិភាក្សា និងអនុម័តរដ្ឋធម្មនុញ្ញ។ វត្តមានរបស់សភាធម្មនុញ្ញ បានធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាទទួលបានរដ្ឋធម្មនុញ្ញមួយដ៏ពិតប្រាកដ ក្នុងការបន្តដំណើរកសាងនីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ ប្រសិនបើមានការស្នើសុំបកស្រាយមាត្រា ឬបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែធ្វើការសិក្សាស្រាវជ្រាវ ជាបឋមទៅលើការពិភាក្សារបស់សភាធម្មនុញ្ញ នៅពេលដែលសភាធម្មនុញ្ញបានអនុម័តមាត្រា ឬបទប្បញ្ញត្តិនោះ ក្នុងគោលដៅដើម្បីធ្វើការបញ្ជាក់ថា តើស្មារតីដើមរបស់សភាធម្មនុញ្ញមានន័យយ៉ាងដូចម្តេចចំពោះមាត្រា ឬបទប្បញ្ញត្តិដែលជាកម្មវត្ថុនៃសំណើសុំបកស្រាយ។

ដូចនេះ ការបកស្រាយច្បាប់ដោយយោងទៅតាមឆន្ទៈរបស់សភាធម្មនុញ្ញ ជាគោលការណ៍ទី១ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលត្រូវបានប្រកាន់យកមកអនុវត្ត។

**ឧទាហរណ៍:**

តាមរយៈលិខិតចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៤ របស់ក្រុមតំណាងរាស្ត្រចំនួន១៦រូប បានស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយ មាត្រា៧ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដោយចោទជាបញ្ហាក្នុងករណីដែលព្រះមហាក្សត្រដាក់រាជសម្បត្តិ ក្រោយពីមានព្រះរាជសាររបស់ព្រះមហាក្សត្រ ស្តីពីព្រះរាជហឫទ័យចង់ដាក់រាជសម្បត្តិជាញឹកញាប់នោះមក មានការបកស្រាយខុសៗគ្នា រវាងនាយករដ្ឋមន្ត្រី និងក្រុមអ្នកច្បាប់មួយចំនួនពីការដាក់រាជសម្បត្តិនេះ។

**ក្រុមប្រឹក្សាធម្មនុញ្ញ បានធ្វើការបកស្រាយមាត្រាខាងលើ ដោយលើកហេតុផលថា:**

ពាក់ព័ន្ធនឹងបញ្ហានៃការខ្វែងមតិគ្នាខាងលើនេះ ក្រុមប្រឹក្សាធម្មនុញ្ញនឹងបកស្រាយទៅលើវាក្យខណ្ឌទី២នៃមាត្រា៧ នៃរដ្ឋធម្មនុញ្ញដែលចែងថា « ***ព្រះមហាក្សត្រ ទ្រង់ជាព្រះប្រមុខរដ្ឋអស់មួយជីវិត*** »ជាមូលដ្ឋាន។ ត្រង់នេះ មានន័យថា ព្រះមហាក្សត្រ ទ្រង់គ្រងរាជសម្បត្តិ និងទ្រង់ជាព្រះប្រមុខរដ្ឋអស់មួយជីវិត។ ព្រះរាជតួនាទី ក្នុងការគ្រងរាជសម្បត្តិ ជាប់ជាមួយព្រះរាជតួនាទី ជាព្រះប្រមុខរដ្ឋ ដោយមិនអាចផ្តាច់ចេញពីគ្នាបានទេ។ ដូច្នេះ ព្រះមហាក្សត្រ ទ្រង់គ្រងរាជសម្បត្តិ និងទ្រង់ជាព្រះប្រមុខរដ្ឋអស់មួយជីវិត គឺរជ្ជកាលរបស់ព្រះមហាក្សត្រ ត្រូវបានកំណត់ចាប់ពីពេលដែលព្រះអង្គឡើងគ្រងរាជសម្បត្តិ រហូតដល់ព្រះអង្គចូលទិវង្គត។

ក្រុមប្រឹក្សាធម្មនុញ្ញ បានពិភាក្សាលើឆន្ទៈរបស់សភាធម្មនុញ្ញ ដោយយល់ឃើញថាសភាធម្មនុញ្ញ បានធ្វើការអនុម័តតែមាត្រា១២ និង មាត្រា១៣នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឲ្យមានការជ្រើសតាំងព្រះមហាក្សត្រថ្មីក្នុងករណីដែលទ្រង់សោយទិវង្គតតែប៉ុណ្ណោះ ហើយការដាក់រាជសម្បត្តិនេះទៀតសោត ក៏មិនមានចែងនៅក្នុងរដ្ឋធម្មនុញ្ញផងដែរ។[52]

[52] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញស្តីពីការបកស្រាយមាត្រា៧ នៃរដ្ឋធម្មនុញ្ញ, លេខ០៦១/០០៣/២០០៤ កបធ.ច, ០៧ កញ្ញា ២០០៤។

### ២.២.២. គោលការណ៍មូលហេតុនៃច្បាប់

បន្ទាប់ពីក្រុមប្រឹក្សាធម្មនុញ្ញ បានព្យាយាមស្វែងរកប្រភពនៃការពិភាក្សារបស់សភាធម្មនុញ្ញ ទៅលើការតាក់តែងមាត្រាណាមួយ ឬបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញអស់ហើយ ប៉ុន្តែពុំទទួលបានលទ្ធផល ធ្វើឲ្យក្រុមប្រឹក្សាធម្មនុញ្ញ នឹងបកស្រាយដោយប្រកាន់យកគោលការណ៍ទី២គឺ« ***គោលការណ៍មូលហេតុនៃច្បាប់*** »។ការបកស្រាយប្រភេទនេះ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាធម្មនុញ្ញ តាមរយៈការពន្យល់ទៅលើខ្លឹមសារនៃមាត្រា ឬបទប្បញ្ញត្តិណាមួយទាំងស្រុងតែម្តង ដោយបកស្រាយលម្អិតគ្រប់ចំណុច និងគ្រប់ជ្រុងជ្រោយ ក្នុងគោលដៅធ្វើយ៉ាងណាឲ្យអស់សេចក្តី និងអត្ថន័យនៃមាត្រា ឬបទប្បញ្ញត្តិនោះ។ ក្នុងករណីដែលក្រុមប្រឹក្សាធម្មនុញ្ញ បានបកស្រាយស៊ីជម្រៅរួចអស់ហើយ បានសេចក្តីថាមាត្រា ឬបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញនោះ មានភាពច្បាស់លាស់ត្រឹមត្រូវហើយ។ ការណ៍នេះ ក្រុមប្រឹក្សាធម្មនុញ្ញមិនធ្វើការបកស្រាយទៀតទេ ក្រោមហេតុផលថាអស់មូលហេតុនៃច្បាប់។[53]

### ២.២.៣. គោលការណ៍ទ្រឹស្តី និងស្មារតីនៃច្បាប់

គោលការណ៍ទ្រឹស្តី និងស្មារតីនៃច្បាប់ ជាមូលដ្ឋាននៃការវិនិច្ឆ័យក្នុងការបកស្រាយ ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញ មិនអាចអនុវត្តតាមគោលការណ៍ទាំងពីរខាងលើបាន។ នេះសរបញ្ជាក់ឲ្យឃើញថា គោលការណ៍នេះ ជាគោលការណ៍ទី៣ ដោយក្រុមប្រឹក្សាធម្មនុញ្ញនឹងត្រូវយកមកប្រើប្រាស់ក្នុងការពន្យល់ ឬស្រាយបំភ្លឺទៅលើមាត្រា ឬបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ និងច្បាប់។ ការពិភាក្សាគ្នានេះ ក្រុមប្រឹក្សាធម្មនុញ្ញសាកល្បងរបៀបបកស្រាយណាមួយ ដោយត្រូវពិនិត្យមើលទៅទៀតលទ្ធផលដែលកើតចេញពីការបកស្រាយតាមរបៀបនោះ ដើម្បីឲ្យដឹងថាក្រុមប្រឹក្សាធម្មនុញ្ញ នឹងទទួលបានលទ្ធផលសមទំនង ឬមិនសមទំនងដល់ការអនុ-វត្ត បន្ទាប់ពីសេចក្តីសម្រេចរបស់ខ្លួនបានចេញជាស្ថាពរហើយ។ ជាស្មារតី ក្រុមប្រឹក្សាធម្មនុញ្ញ នឹងបោះបង់ចោលរបៀបបកស្រាយណាមួយដែលបណ្តាលឲ្យរាំងស្ទះ ឬមានគ្រោះថ្នាក់ដល់ផលប្រយោជន៍ជាតិ។ ដោយឡែក ក្រុមប្រឹក្សាធម្មនុញ្ញ ធ្វើការស្រាវជ្រាវ ដោយត្រូវចាប់ផ្តើមពិនិត្យមើលសេចក្តីព្រាងដើម សេចក្តីថ្លែងហេតុ កំណត់ហេតុពិស្តារនៃកិច្ចប្រជុំរបស់រដ្ឋសភា និងឯកសារផ្សេងៗទៀត តាមបែបបណ្ឌិតសភា។[54]

ដោយផ្អែកទៅលើគោលការណ៍ទ្រឹស្តី និងស្មារតីនៃច្បាប់ យើងនឹងសិក្សាទៅលើមូលដ្ឋាននៃការបកស្រាយដូចជា៖ គោលការណ៍អនុលោមភាព ឬ ស្រប(២.២.៣.១) គោលការណ៍បដិលោមភាព ឬ ផ្ទុយ(២.២.៣.២) គោលការណ៍ប្រៀបធៀប(២.២.៣.៣) គោលការណ៍ពាក្យពេចន៍ក្នុងអត្ថបទច្បាប់(២.២.៣.៤) និងគោលការណ៍ចេតនារបស់អ្នកតាក់តែងច្បាប់(២.២.៣.៥)។

---

[53] ណើ ណារី, *សមត្ថកិច្ចក្រុមប្រឹក្សាធម្មនុញ្ញ*, (សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១២), ២៨។

[54] អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, *កម្រងឯកសារសំណួរចម្លើយទាក់ទងនឹងរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, ២០១១), ៦២។

### ២.២.៣.១. គោលការណ៍អនុលោមភាព ឬ ស្រប

ក្រុមប្រឹក្សាធម្មនុញ្ញ អាចធ្វើការបកស្រាយមាត្រា ឬបទបញ្ញត្តិណាមួយនៃច្បាប់ ដោយឈរលើគោលការណ៍អនុលោមភាព ឬស្រប។ គោលការណ៍នេះ សំដៅឲ្យក្រុមប្រឹក្សាធម្មនុញ្ញ ធ្វើការពន្យល់ ឬស្រាយបំភ្លឺទៅតាមមាត្រានៃច្បាប់នោះត្រង់តែម្តង ដោយគ្មានការបញ្ចិតបញ្ចៀង និងធ្វើការអធិប្បាយលម្អិតទៅតាមខ្លឹមសារនៃមាត្រាដែលជាកម្មវត្ថុនៃសំណើសុំបកស្រាយ។ ការបកស្រាយបែបនេះ មានលក្ខណៈងាយស្រួល បើប្រៀបធៀបទៅនឹងមូលដ្ឋាននៃការបកស្រាយដទៃទៀត ដែលក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាន់យក។

**ឧទាហរណ៍ទី១:**

តាមរយៈសំណើចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១៥ របស់ សម្តេច វិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា បានស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា៩១ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំបកស្រាយមាត្រានេះ មកពិនិត្យបាន ដោយសារតែសំណើនេះ បានធ្វើឡើងស្របនឹងរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

**ក្រុមប្រឹក្សាធម្មនុញ្ញ បានធ្វើការបកស្រាយមាត្រាខាងលើ ដោយលើកហេតុផលថា:**

មាត្រា៩១ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មានចំនួន ២វាក្យខណ្ឌ ដែលចែងថា:

*« សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ »។*

*« តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះសំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ »។*

វាក្យខណ្ឌទី១ នៃមាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញ បានកំណត់អំពីសិទ្ធិរបស់សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី ក្នុងការផ្តួចផ្តើមគំនិតធ្វើច្បាប់។ វាក្យខណ្ឌទី១នេះ មានន័យថា:

- សមាជិកព្រឹទ្ធសភា ១រូប ឬច្រើនរូប មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ និងមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន។
- សមាជិករដ្ឋសភា ១រូប ឬច្រើនរូប មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ និងមានសិទ្ធិផ្តួចផ្តើមគំនិតក្នុងការធ្វើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន។
- សមាជិកព្រឹទ្ធសភានិងសមាជិករដ្ឋសភា មានសិទ្ធិរួមគ្នាផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ ឬ មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន។

ការផ្តួចផ្តើមគំនិតធ្វើច្បាប់ និងការផ្តួចផ្តើមគំនិតធ្វើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយ ដែលកំពុងនៅជាធរមាន ពីសំណាក់សមាជិកព្រឹទ្ធសភា ឬពីសមាជិករដ្ឋសភា ឬពីសមាជិកព្រឹទ្ធសភា និងសមាជិករដ្ឋសភារួមគ្នាជាហត្ថលេខី ត្រូវធ្វើជាសេចក្តីស្នើច្បាប់ និងត្រូវបំពេញទម្រង់បែបបទទៅតាមនីតិវិធីនៃការធ្វើច្បាប់។

- នាយករដ្ឋមន្ត្រី មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីព្រាងច្បាប់ និងមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន។ នាយករដ្ឋមន្ត្រី ត្រូវធ្វើជាសេចក្តីព្រាងច្បាប់ និងត្រូវបំពេញទម្រង់បែបបទទៅតាមនីតិវិធីនៃការធ្វើច្បាប់។

ចំណែកឯ វាក្យខណ្ឌទី២ នៃមាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញ មានន័យថា ជាការបញ្ជាក់បន្ថែមទៅលើខ្លឹមសារនៃវាក្យខណ្ឌទី១ ដោយហាមតំណាងរាស្ត្រមិនឲ្យធ្វើវិសោធនកម្មច្បាប់ដែលសំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ។

ដូច្នេះ តាមរយៈការបកស្រាយខាងលើ សមាជិកព្រឹទ្ធសភាមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់បាន។[55]

**ឧទាហរណ៍ទី២:**

តាមរយៈលិខិតលេខ ១៦៨លស ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ១៧ និងមាត្រា១៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ។

ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំបកស្រាយនេះ មកពិនិត្យបាន ដោយសារតែសំណើនេះបានធ្វើឡើងស្របនឹងរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

**ក្រុមប្រឹក្សាធម្មនុញ្ញ បានធ្វើការបកស្រាយតបនឹងសំណើខាងលើ ដូចខាងក្រោមៈ**

- បទប្បញ្ញត្តិនៃមាត្រា១៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ ត្រូវបានបកស្រាយថា ទាំងមន្ត្រីរាជការស៊ីវិល ទាំងយោធា ដែលកំពុងបំពេញមុខងារជាសកម្ម គ្មានសិទ្ធិជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាបានទេ មានន័យម្យ៉ាងទៀតថា មន្ត្រីរាជការស៊ីវិល និងយោធា មិនអាចធ្វើការងាររបស់ខ្លួនផង និងជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាផងក្នុងពេលតែមួយ។ យ៉ាងណាមិញ ច្បាប់នេះ ពុំបានហាមឃាត់ដាច់ខាតមិនឲ្យឈរឈ្មោះឲ្យគេបោះឆ្នោតនោះទេ។ ប្រសិនបើមន្ត្រីរាជការស៊ីវិល និងយោធាទាំងនោះ មានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា សាមីខ្លួនត្រូវបំពេញលក្ខខណ្ឌដូចដែលមានចែងក្នុងបទប្បញ្ញត្តិនៃមាត្រា១៨ នៃច្បាប់នេះ។
- បទប្បញ្ញត្តិនៃមាត្រា១៨ ដែលចែកជា៣ វាក្យខណ្ឌត្រូវបានបកស្រាយដូចខាងក្រោមនេះៈ

  ក/ បទប្បញ្ញត្តិនៃវាក្យខណ្ឌទី១ មានន័យថា ទាំងមន្ត្រីរាជការស៊ីវិល និងយោធា ដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិច ៧

[55] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញស្តីពីការបកស្រាយមាត្រា៩១ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, លេខ១៥៥/០០៣/២០១៥ កបធ.ច, ២៧ កក្កដា ២០១៥។

ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ។ បានសេចក្តីថា ការដាក់ពាក្យសុំឈប់សម្រាកពីការងារតែប៉ុណ្ណោះ មិនមែនជាការដាក់ពាក្យសុំលាលែងពីមុខងារ ឬមុខតំណែងឡើយ។ បទប្បញ្ញត្តិនេះ មានអត្ថន័យម្យ៉ាងទៀតថា មន្ត្រីរាជការស៊ីវិល និងយោធាដែលចង់ស្នើជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវសុំការអនុញ្ញាតអវត្តមានពីការងារ ក្នុងរយៈពេលដូចបានកំណត់ខាងលើ។

ខ/ បទប្បញ្ញត្តិនៃវាក្យខណ្ឌទី២ មានន័យថា សាមីខ្លួនជាប់ឆ្នោត ត្រូវធ្វើពាក្យទៅក្រសួង ឬស្ថាប័នរបស់ខ្លួន សុំទៅបម្រើការងារក្រៅក្របខណ្ឌដើម ក្នុងរយៈពេលនៃអាណត្តិរបស់ក្រុមប្រឹក្សាតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ក្នុងរយៈពេលនៃអាណត្តិនោះ សាមីខ្លួនមានសិទ្ធិឡើងថ្នាក់ ឬឋានន្តរសក្តិ និងរក្សាអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍ទៀតផង។

ប្រសិនបើបេក្ខជនជាប់ឆ្នោតហើយ បន្ទាប់មកគ្មានបំណងចង់ទៅបម្រើការងារជាសមាជិកក្រុមប្រឹក្សាទេនោះ សាមីខ្លួនត្រូវធ្វើពាក្យទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីសុំដកបេក្ខភាពរបស់ខ្លួនចេញពីបញ្ជីឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។ ក្នុងករណីនេះ សាមីខ្លួនអាចត្រឡប់មកបម្រើការ ឬកាន់ការងារដើមរបស់ខ្លួនវិញបាន។

គ/ បទប្បញ្ញត្តិនៃវាក្យខណ្ឌទី៣ សំដៅដល់ នៅពេលចប់អាណត្តិជាសមាជិកក្រុមប្រឹក្សា សាមីខ្លួនអាចធ្វើការត្រឡប់មកបម្រើការងារនៅក្រសួង ឬស្ថាប័នដើមរបស់ខ្លួនវិញបាន ប៉ុន្តែសាមីខ្លួននឹងអាចបានទទួលមុខងារ ឬមុខតំណែងដើមរបស់ខ្លួនវិញបាននោះ អាស្រ័យដោយក្រសួង ឬស្ថាប័ន ជាអ្នកសម្រេច មិនមែនសាមីខ្លួនអាចទទួលបានមុខងារ ឬ មុខតំណែងរបស់ខ្លួនវិញ ដោយស្វ័យប្រវត្តិនោះឡើយ។[56]

### ២.២.៣.២. គោលការណ៍បដិលោមភាព ឬ ផ្ទុយ

ក្រុមប្រឹក្សាធម្មនុញ្ញ អាចសាកល្បងក្នុងការបកស្រាយមាត្រា ឬបទប្បញ្ញត្តិណាមួយនៃច្បាប់ ដោយសម្អាងទៅលើគោលការណ៍បដិលោមភាព ឬផ្ទុយ។ ការបកស្រាយបែបនេះ មានលក្ខណៈផ្ទុយពីគោលការណ៍អនុលោមភាព ឬស្រប ប៉ុន្តែមានគោលដៅដូចគ្នា ពោលគឺស្វែងរកភាពច្បាស់លាស់ទៅលើខ្លឹមសារ និងគោលការណ៍នៃច្បាប់សម្រាប់យកទៅអនុវត្តឲ្យបានត្រឹមត្រូវ និងមានឯកភាពទូទាំងប្រទេស។

មូលដ្ឋាននៃការពន្យល់ និងស្រាយបំភ្លឺនៃគោលការណ៍នេះ គឺធ្វើការបកស្រាយបែបបញ្ច្រាសទៅលើមាត្រា ឬបទប្បញ្ញត្តិណាមួយនៃច្បាប់ ដើម្បីទាញរកអត្ថន័យ និងខ្លឹមសារច្បាស់លាស់វិញ។ វាអាចជាគោលការណ៍ មួយដែលមានសារៈសំខាន់ ដោយហេតុថាការបកស្រាយតាមរបៀបនេះ មិនបង្កជាការលំបាកនិងស្មុគស្មាញណាមួយគួរឲ្យកត់សម្គាល់ដល់ក្រុមប្រឹក្សាធម្មនុញ្ញនោះឡើយ។

[56] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញស្តីពីការបកស្រាយមាត្រា១៧ និង១៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ, លេខ១០៥/០០១/២០០៩ កបធ.ច, ២៥ កុម្ភៈ ២០០៩។

**ឧទាហរណ៍:**

យោងតាមលិខិតគ្មានលេខ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ របស់ក្រុមអ្នកតំណាងរាស្ត្រចំនួន១៥រូប បានស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយ និងពិនិត្យធម្មនុញ្ញភាពមាត្រា២៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ។

ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំបកស្រាយ និងពិនិត្យធម្មនុញ្ញភាពនៃមាត្រានេះ មកពិនិត្យបាន ដោយហេតុថាសំណើនេះ បានធ្វើឡើងស្របនឹងរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

**ឆ្លើយតបទៅនឹងសំណើនេះ ក្រុមប្រឹក្សាធម្មនុញ្ញបានធ្វើការបកស្រាយដូចខាងក្រោម:**

បទប្បញ្ញត្តិនៃមាត្រា២៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ ពាក់ព័ន្ធតែនឹងបញ្ជីបោះឆ្នោត ពោលគឺបញ្ជីអ្នកបោះឆ្នោតដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងតែប៉ុណ្ណោះ។ មាត្រានេះ ចែកជា ៣ វាក្យខណ្ឌ ដូចជា៖

- វាក្យខណ្ឌទី១ បានចែងថា «*គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវផ្តល់សុពលភាពបញ្ជីបោះឆ្នោតក្នុងរយៈពេលយ៉ាងតិចសាមសិបប្រាំ (៣៥)ថ្ងៃ មុនថ្ងៃបោះឆ្នោត*»។ បទប្បញ្ញត្តិនៃវាក្យខណ្ឌនេះមានន័យថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពុំអាចផ្តល់សុពលភាពបញ្ជីបោះឆ្នោត ក្រោយសាបសិបប្រាំ (៣៥) ថ្ងៃ មុនថ្ងៃបោះឆ្នោតបានទេ។
- វាក្យខណ្ឌទី២ បានចែងថា «*បញ្ជីបោះឆ្នោត ដែលត្រូវបានផ្តល់សុពលភាពរួចហើយ គឺជាបញ្ជីបោះឆ្នោតជាលក្ខណៈផ្លូវការ មិនអាចកែប្រែបានឡើយ លើកលែងតែមានអ្នកបោះឆ្នោតណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទទួលមរណភាព*»។ បទប្បញ្ញត្តិនៃវាក្យខណ្ឌនេះ បានសេចក្តីថា ក្នុងពេលដែលបញ្ជីបោះឆ្នោតត្រូវបានផ្តល់សុពលភាពរួចហើយ បញ្ជីនោះក្លាយជាបញ្ជីបោះឆ្នោតផ្លូវការដែលមិនអាចកែប្រែបានឡើយ លើកលែងតែករណីមានអ្នកបោះឆ្នោតណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការរួចហើយ បានទទួលមរណភាព។
- វាក្យខណ្ឌទី៣ បានចែងថា «*ក្នុងករណីមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទទួលមរណភាព ក្រសួងមហាផ្ទៃត្រូវបំពេញបែបបទ ផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នោះ ក្នុងរយៈពេលប្រាំពីរ (០៧) ថ្ងៃ យ៉ាងតិចមុនថ្ងៃបោះឆ្នោត ដើម្បីឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជំនួសក្នុងបញ្ជីបោះឆ្នោត*»។ បទប្បញ្ញត្តិនៃវាក្យខណ្ឌនេះ មានន័យថា ក្នុងករណីដែលមានសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ណាម្នាក់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតជាផ្លូវការហើយ ក្រោយមកសមាជិកនោះបានទទួលមរណភាព ក្រសួងមហាផ្ទៃត្រូវ មិនត្រូវបំពេញបែបបទធ្វើការ

ផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់នោះ ក្រោយប្រាំពីរ (០៧)ថ្ងៃ មុនថ្ងៃបោះឆ្នោតឡើយ ដើម្បីឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជំនួសក្នុងបញ្ជីបោះឆ្នោតបានទេ។[57]

### ២.២.៣.៣. គោលការណ៍ប្រៀបធៀប

នៅក្នុងគោលការណ៍ទ្រឹស្តី និងស្មារតីនៃច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញ អាចបកស្រាយមាត្រា ឬបទប្បញ្ញត្តិណាមួយនៃច្បាប់ ដោយផ្អែកលើគោលការណ៍ប្រៀបធៀប។ គេសង្កេតឃើញថា ការបកស្រាយរបៀបនេះ មានភាពខុសប្លែកគ្នា ពីការបកស្រាយបែបស្រប និងបែបផ្ទុយ។ ក្រុមប្រឹក្សាធម្មនុញ្ញ ធ្វើការពន្យល់ និងស្រាយបំភ្លឺទៅលើមាត្រា ឬបទប្បញ្ញត្តិណាមួយនៃច្បាប់ ដោយធ្វើការប្រៀបធៀបរវាងមាត្រាមួយទៅនឹងមាត្រាមួយទៀត ក្នុងគោលដៅដើម្បីបញ្ជាក់បន្ថែមអត្ថន័យ និងទាញយកសេចក្តីសន្និដ្ឋានមួយចំពោះមាត្រា ឬបទប្បញ្ញត្តិដែលត្រូវបានបកស្រាយ។

ដូច្នេះ មូលដ្ឋាននៃការបកស្រាយប្រភេទនេះ ទាមទារឲ្យក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសិក្សាលម្អិតទៅលើមាត្រា ឬបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធទៅនឹងមាត្រា ឬបទប្បញ្ញត្តិដែលជាកម្មវត្ថុនៃសំណើសុំបកស្រាយ។

**ឧទាហរណ៍:**

ផ្អែកតាមលិខិត របស់ក្រុមអ្នកតំណាងរាស្ត្រចំនួន ១៨រូប ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៣ បានស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយបំភ្លឺលើខ្លឹមសារវាក្យខណ្ឌទី១ មាត្រា៧៦ ជំពូកទី៧ នៃរដ្ឋធម្មនុញ្ញថាចំពោះមុខស្ថានភាពនេះ តើការប្រជុំពេញអង្គជាសាមញ្ញ ឬ ជាវិសាមញ្ញរបស់រដ្ឋសភានឹងអាចប្រព្រឹត្តទៅបានរហូតដល់រដ្ឋសភាថ្មីចូលកាន់តំណែង ស្របតាមរដ្ឋធម្មនុញ្ញដែរឬទេ?

ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំបកស្រាយនេះ មកពិនិត្យបាន ដោយហេតុថាសំណើនេះបានធ្វើឡើងស្របនឹងរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

**ក្រុមប្រឹក្សាធម្មនុញ្ញ បានធ្វើការបកស្រាយតបទៅនឹងសំណើខាងលើ ដោយអះអាងដូចខាងក្រោម:**

ឆ្លើយតបនឹងសំណើខាងលើ ក្រុមប្រឹក្សាធម្មនុញ្ញ យល់ថា បញ្ហានឹងកើតមានឡើងតែក្នុងករណីដែលគ្មានការជ្រើសតាំង អ្នកតំណាងរាស្ត្រថ្មីជំនួសអ្នកតំណាងរាស្ត្រដែលទទួលអនិច្ចកម្ម លាលែង ឬប្រាសចាកពីសមាជិកភាពរដ្ឋសភា ហើយដែលចំនួនតំណាងរាស្ត្ររដ្ឋសភាទាំងអស់ ត្រូវចុះថយនៅសល់តិចជាង១២០រូបប៉ុណ្ណោះ។ ក្នុងបរិបទនេះ ក្រុមប្រឹក្សាធម្មនុញ្ញ បានធ្វើការបកស្រាយដូចតទៅ:

វាក្យខណ្ឌទី១ នៃមាត្រា៧៦ នៃរដ្ឋធម្មនុញ្ញ ចែងថា:« *រដ្ឋសភា មានសមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០រូប* »។ ត្រង់នេះមានន័យថា យ៉ាងតិចណាស់ត្រូវមានតំណាងរាស្ត្រ១២០រូប ទើបអាចបង្កើតរដ្ឋសភាបានក្នុងនីតិកាលនីមួយៗ។ ច្បាប់បោះឆ្នោត មិនអាចកំណត់ចំនួនតំណាងរាស្ត្រតិចជាង១២០ រូបបានទេ។ វាក្យខណ្ឌទី ១ នេះជាលក្ខខណ្ឌចាំបាច់សម្រាប់បង្កើតរដ្ឋសភា ប៉ុន្តែមិនមែនសម្រាប់ដំណើរការនៃរដ្ឋសភាទេ។

---

[57] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញស្តីពីការបកស្រាយ និងត្រួតពិនិត្យធម្មនុញ្ញភាពនៃមាត្រា២៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ, លេខ១០៦/០០២/២០០៩ កបធ.ច, ១៦ មីនា ២០០៩។

នៅពេលបោះឆ្នោតចប់ហើយ លទ្ធផលត្រូវឲ្យបានតំណាងរាស្ត្រចាប់ពី ១២០រូប ឡើងទៅ ស្របតាមការកំណត់នៃច្បាប់បោះឆ្នោត ទើបអាចបង្កើតរដ្ឋសភានីតិកាលថ្មីមួយបាន ដោយគោរពទៅតាមនីតិវិធីដែលមានចែងក្នុងមាត្រា៨២ នៃរដ្ឋធម្មនុញ្ញ និងប្រការ ៣ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។ គឺថារដ្ឋសភាដែលកើតចេញពីការបោះឆ្នោត ត្រូវចូលកាន់តំណែងជាផ្លូវការនៅពេលសម័យប្រជុំដំបូងតាមការកោះហៅរបស់ព្រះមហាក្សត្រ ហើយនឹងមានការប្រកាសសម្រេចអំពីសុពលភាពឈ្មោះតំណាងរាស្ត្របិទផ្សាយក្នុងមន្ទីររដ្ឋសភា និងជាសាធារណៈ។ ចាប់ពីពេលនេះមក រដ្ឋសភានឹងមានសុពលភាពរហូតដល់ចប់អាណត្តិរបស់ខ្លួនក្នុងករណីធម្មតា លើកលែងតែក្នុងករណីពិសេសនៃការរំលាយរដ្ឋសភាដោយមកពីមានការទម្លាក់រាជរដ្ឋាភិបាលពីរដងក្នុងរយៈពេល១២ ខែដូចដែលមានចែងក្នុងមាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញ។ ហេតុដូច្នេះហើយ ទើបមាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញបានចែងថា ***«រដ្ឋសភាមិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ វៀរលែងតែក្នុងករណីដែលរាជរដ្ឋាភិបាល ត្រូវបានទម្លាក់ពីរដងក្នុងរយៈពេល១២ខែ »*** ។នេះសរបញ្ជាក់ឲ្យឃើញថា ការប្រែប្រួលនៃចំនួនតំណាងរាស្ត្រ ក្នុងរយៈពេលនៃការប្រព្រឹត្តទៅនៃនីតិកាល មិនអាចធ្វើឲ្យប៉ះពាល់ដល់សុពលភាពរដ្ឋសភាទាំងមូលបានឡើយ។

ដូចនេះ ទោះបីជាមានតំណាងរាស្ត្រប្រែប្រួលចុះថយក្រោម ១២០រូប យ៉ាងណាក៏ដោយ កុំឲ្យតែទាបជាងចំនួនកូរ៉ុមប្រាំពីរភាគដប់នៃសមាជិករដ្ឋសភាទាំងមូល ក៏រដ្ឋសភាអាចដំណើរការបានដូចធម្មតា ហើយជាពិសេសការប្រជុំពេញអង្គជាសាមញ្ញ ឬជាវិសាមញ្ញ ក៏អាចនឹងប្រព្រឹត្តទៅបានរហូតដល់រដ្ឋសភាថ្មីចូលកាន់តំណែង ដោយពុំមានអ្វីខុស ឬប្រាសចាកពីរដ្ឋធម្មនុញ្ញឡើយ។[58]

### ២.២.៣.៤. គោលការណ៍ពាក្យពេចន៍ក្នុងអត្ថបទច្បាប់

ក្នុងកាលៈទេសៈមួយចំនួន គេសង្កេតឃើញថាមាត្រា ឬបទប្បញ្ញត្តិខ្លះនៃច្បាប់ ត្រូវបានចែងមកមានលក្ខណៈមិនសូវជាច្បាស់លាស់ ឬពិបាកយល់ ត្រង់ឃ្លា ឬវាក្យសព្ទគតិយុត្តដែលជាមូលហេតុចាំបាច់ដែលទាមទារឲ្យមានការបកស្រាយឲ្យបានត្រឹមត្រូវ និងជាក់លាក់ ក្នុងគោលដៅដើម្បីបញ្ចៀសការអនុវត្តដែលផ្ទុយពីអត្ថន័យដើមនៃពាក្យ ឬឃ្លានោះ។

ក្រុមប្រឹក្សាធម្មនុញ្ញ បានប្រកាន់យកគោលការណ៍នៃការបកស្រាយមាត្រា ឬបទប្បញ្ញត្តិណាមួយនៃច្បាប់ដោយផ្តោតទៅលើការបំភ្លឺចំពោះពាក្យ ឬឃ្លាដែលមានលក្ខណៈសាំញ៉ាំនោះ។ មូលដ្ឋាននៃការបកស្រាយប្រភេទនេះមានន័យថាក្រុមប្រឹក្សាធម្មនុញ្ញព្យាយាម ពន្យល់ បកស្រាយ និងបញ្ជាក់អំពីពាក្យពេចន៍ ឬឃ្លា ក្នុងមាត្រា ឬបទប្បញ្ញត្តិណាមួយនៃអត្ថបទច្បាប់នោះ ដោយធ្វើយ៉ាងណាឲ្យមានភាពច្បាស់លាស់ និងត្រឹមត្រូវស្របទៅតាមខ្លឹមសារ ឬអត្ថន័យដើមរបស់ពាក្យដែលបានតាក់តែងមក។[59]

[58] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញស្តីពីការបកស្រាយមាត្រា៧៦ វាក្យខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, លេខ០៥៤/០០៥/២០០៣ កបធ.ច, ២២ កក្កដា ២០០៣។

[59] មាស បូរ៉ា, *ចំណេះដឹងទូទៅស្តីពីច្បាប់*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ ២០២០), ៥៤។

**ឧទាហរណ៍:**

តាមរយៈលិខិត ០០២/១០ រ.ស.គសរ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ របស់ឯកឧត្តម លោកជំទាវ អ្នកតំណាងរាស្ត្រ ១៥ រូប ជូនមកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ស្នើសុំឲ្យបកស្រាយមាត្រា១៦ វាក្យខណ្ឌទី៤ នៃច្បាប់ភូមិបាល។

ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំបកស្រាយមាត្រានេះ មកពិនិត្យបាន ដោយហេតុថាសំណើនេះ បានធ្វើឡើងស្របនឹងរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

**ឆ្លើយតបទៅនឹងសំណើខាងលើ ក្រុមប្រឹក្សាធម្មនុញ្ញ បានធ្វើការបកស្រាយដូចតទៅ:**

វាក្យខណ្ឌទី៤ មាត្រា១៦ នៃច្បាប់ភូមិបាល បានចែងថា« ***ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ នៅពេលបាត់បង់ប្រយោជន៍សាធារណៈ អាចត្រូវចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ តាមរយៈច្បាប់អនុបយោគ***» ។ បទប្បញ្ញត្តិនៃវាក្យខណ្ឌនេះ មានន័យថា កាលណាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋណាមួយ ត្រូវបានឈប់ប្រើប្រាស់ជាផលប្រយោជន៍សាធារណៈតទៅទៀតហើយ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនោះ អាចត្រូវចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋបាន តាមរយៈច្បាប់អនុបយោគ។

ដូចនេះ ពាក្យថា **«*ច្បាប់អនុបយោគ*»** សំដៅលើច្បាប់ដែលរំសាយពីប្រភេទទ្រព្យសម្បត្តិមួយទៅប្រភេទទ្រព្យសម្បត្តិមួយទៀត ដូចជារំសាយពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ជាដើម។[60]

### ២.២.៣.៥. គោលការណ៍ចេតនារបស់អ្នកតាក់តែងច្បាប់

ការតាក់តែងច្បាប់ ណាមួយឡើងប្រាកដជាមានមូលហេតុ និងគោលបំណងដ៏ជាក់លាក់ ដោយហេតុថាច្បាប់ជាវិធានសម្រាប់គ្រប់គ្រងទំនាក់ទំនងបុគ្គលនៅក្នុងសង្គម ជាពិសេសប្រទេសដែលប្រកាន់យកគោលការណ៍នីតិរដ្ឋ។ ផ្អែកតាមគោលគំនិតនេះ អត្ថបទច្បាប់ណាមួយ មុននឹងឈានទៅដល់ការអនុម័ត សុទ្ធតែត្រូវបានឆ្លងកាត់ដំណាក់កាលនៃការធ្វើសេចក្តីព្រាង ឬសេចក្តីស្នើពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច។ បន្ទាប់មកប្រសិនបើសេចក្តីព្រាង ឬសេចក្តីស្នើនៃច្បាប់ត្រូវបានគាំទ្រហើយ អង្គការនីតិប្បញ្ញត្តិ នឹងដើរតួនាទីជាអ្នកពិភាក្សា និងអនុម័ត។

ហេតុនេះហើយ ទើបការបកស្រាយមាត្រា ឬបទប្បញ្ញត្តិណាមួយនៃច្បាប់ ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ តែងតែតាមដាន ស្រាវជ្រាវ និងពិនិត្យមើលទៅលើចេតនារបស់នីតិករជានិច្ចកាល។ លើសពីនេះទៅទៀត ស្ថាប័ននេះក៏ធ្វើការសិក្សាទៅលើសេចក្តីព្រាង ឬសេចក្តីស្នើដើមរបស់អាជ្ញាធរមានសមត្ថកិច្ច សេចក្តីថ្លែងហេតុ និងការពិភាក្សាសម្រេចនៅឯស្ថាប័នរដ្ឋសភា។ ការបកស្រាយដោយឈរលើមូលដ្ឋាននេះ សរបញ្ជាក់ឲ្យឃើញថាមាត្រា ឬបទ-

[60] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញស្តីពីការបកស្រាយមាត្រា១៦ វាក្យខណ្ឌទី៤ នៃច្បាប់ភូមិបាល, លេខ១០៩/០០២/២០១០ កបធ.ច, ១២ មីនា ២០១០។

ប្បញ្ញត្តិដែលត្រូវបានស្រាយបំភ្លឺ ក៏ដូចជាពន្យល់ មានខ្លឹមសារច្បាស់លាស់ និងអព្យាក្រឹត្យ ព្រមទាំងមិនប្រាសចាកពីឆន្ទៈដើមនៃអ្នកតាក់តែងច្បាប់។[61]

**ឧទាហរណ៍:**

តាមរយៈលិខិតលេខ ៤២៧ រស ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៣ របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភាបញ្ជូនលិខិតលោក **គល់ បញ្ញា** នាយកប្រតិបត្តិរបស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា មកក្រុមប្រឹក្សាធម្មនុញ្ញសុំឲ្យធ្វើការបកស្រាយមាត្រា ១២៤ថ្មី វាក្យខណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ តាមពាក្យបណ្តឹងលេខ ២៨៧/គ.ប.ស.យ ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០០៣ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញទទួលបាននៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៣។

ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំបកស្រាយមាត្រានេះ មកពិនិត្យបាន ដោយហេតុថាសំណើនេះ បានធ្វើឡើងស្របនឹងរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

**ឆ្លើយតបទៅនឹងសំណើខាងលើ ក្រុមប្រឹក្សាធម្មនុញ្ញ បានធ្វើការបកស្រាយដូចខាងក្រោម:**

- មាត្រា ៧៦ វាក្យខណ្ឌទី៥ នៃរដ្ឋធម្មនុញ្ញ បានបញ្ញត្តិឲ្យច្បាប់បោះឆ្នោតកំណត់អំពី អង្គការរៀបចំការបោះឆ្នោត បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោត។
- តាមការបញ្ជាក់របស់ក្រសួងមហាផ្ទៃ ដែលជាអ្នកតាក់តែងសេចក្តីព្រាងដើមនៃច្បាប់បោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ គំនិតគឺឲ្យ គ.ជ.ប ជាអ្នកធ្វើការពិន័យ។
- តាមកំណត់ហេតុនៃការពិភាក្សានៅរដ្ឋសភា នាឆ្នាំ២០០២ និងឆ្នាំ១៩៩៧ ពុំមានយោបល់សុំកែប្រែគំនិតដើមរបស់សេចក្តីព្រាងមាត្រា ១២៤ថ្មី និងមាត្រា១២៤ចាស់ លើចំណុចខាងលើនេះទេ។
- មាត្រា ១២៤ថ្មី វាក្យខណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានចែងថា ***«ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតលុបបេក្ខភាពរបស់សាមីខ្លួន ឬលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការរៀបចំការបោះឆ្នោត ឬ/និង ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀល ទៅម្ភៃប្រាំលាន (២៥.០០០.០០០) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត...»*** ។ ក្នុងឃ្លានេះ យោងតាមទទ្បីករណ៍ខាងលើ ការពិន័យជាប្រាក់ ក៏ស្ថិតនៅក្នុងសមត្ថកិច្ចរបស់ គ.ជ.ប ដែរ។[62]

---

[61] មាស ប៉ូរ៉ា, *ចំណេះដឹងទូទៅស្តីពីច្បាប់*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ ២០២០), ៥៨។

[62] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញស្តីពីការបកស្រាយមាត្រា១២៤ថ្មី វាក្យខណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ, លេខ០៥៨/០០៩/២០០៣ កបធ.ច, ១៦ តុលា ២០០៣។

## ផ្នែកទី៣៖ នីតិវិធីដែលត្រូវអនុវត្តក្នុងការបកស្រាយ

ក្នុងដំណើរការនៃការបកស្រាយរដ្ឋធម្មនុញ្ញ ច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវអនុវត្តទៅតាមនីតិវិធី របៀបរបប និងបែបផែន ដែលត្រូវបានកំណត់ទៅតាមដំណាក់កាលនីមួយៗនៅក្នុងបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ នីតិវិធីដែលត្រូវអនុវត្តក្នុងការបកស្រាយ នៅមុខក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានបែងចែកជា ៣ដំណាក់កាលគឺៈ ការចុះបញ្ជីនៅអគ្គ-លេខាធិការដ្ឋាន(៣.១) ការបែងចែកក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ(៣.២) និងការចេញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ(៣.៣)។

### ៣.១. ការចុះបញ្ជីនៅអគ្គលេខាធិការដ្ឋាន

អគ្គលេខាធិការដ្ឋាន ជាសេនាធិការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានភារកិច្ចទទួលបន្ទុកការងាររដ្ឋបាល ទទួលចុះបញ្ជីសំណុំរឿង រក្សាកំណត់ហេតុ និងភារកិច្ចផ្សេងៗទៀតតាមការប្រគល់របស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដូចមានចែងក្នុងអនុក្រឹត្យលេខ៤២ ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ។

អនុលោមតាមមាត្រា ១៥ថ្មី មាត្រា១៦ថ្មី មាត្រា១៧ថ្មី មាត្រា១៨ថ្មី និងមាត្រា១៩ ថ្មីនៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក្រោយពីបានទទួលសំណើពីព្រះមហាក្សត្រ ពីប្រធានព្រឹទ្ធសភា ពីប្រធានរដ្ឋសភា ពីនាយករដ្ឋមន្ត្រី ពីសមាជិកព្រឹទ្ធសភាមួយភាគបួន ពីសមាជិករដ្ឋសភាចំនួនមួយភាគដប់ ពីតុលាការ ពីប្រជារាស្ត្រតាមរយៈប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា សមាជិកព្រឹទ្ធសភាមួយភាគបួន សមាជិករដ្ឋសភាចំនួនមួយភាគដប់ ឬពីតុលាការកំពូល ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវចាត់ឲ្យចុះបញ្ជីនៅអគ្គលេខាធិការដ្ឋាន។[63]

រយៈពេលដោះស្រាយ ត្រូវចាប់រាប់តាំងពីថ្ងៃចុះបញ្ជីរួចនេះ ហើយពេលវេលាដោះស្រាយត្រូវធ្វើតាមការកំណត់ក្នុងច្បាប់។

ក្រោយពីចុះបញ្ជីរួច ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវបញ្ជូនសំណើទាំងនោះ ទៅសមាជិករាយការណ៍ក្នុងក្រុមណាមួយនៃក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិនិត្យ។ របាយការណ៍របស់ក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវដាក់ជូនអង្គប្រជុំបឋមដើម្បីពិភាក្សា។

### ៣.២. ការបែងចែកក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ

ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ អនុវត្តការងារតាមរយៈការបែងចែកជាក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ ពិចារណា និងវិនិច្ឆ័យលើបញ្ហាណាមួយ ដោយផ្អែកទៅលើសេចក្តីរាយការណ៍របស់សមាជិករាយការណ៍ក្នុងក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ក្រុមនីមួយៗនៃក្រុមប្រឹក្សាធម្មនុញ្ញ មានសមាជិក ៣រូប ដែលមួយរូបជា

[63] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញស្តីពីវិសោធនកម្មបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ, លេខ២៥/២០០៧ កបធ.សសរ, ០៩ មីនា ២០០៧, ប្រការ១ថ្មី។

សមាជិកតែងតាំងដោយព្រះមហាក្សត្រ មួយរូបជាសមាជិកជ្រើសតាំងដោយរដ្ឋសភា និងមួយរូបទៀត ជាសមាជិកជ្រើសតាំងពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។[64]

សមាជិកក្នុងក្រុមទាំង៣ នេះ ត្រូវជ្រើសតាំងតាមវិធីចាប់ឆ្នោត ក្រោមអធិបតីភាពនៃប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។ ជាបឋមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ បានសរសេរឈ្មោះសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំង៩ រូបក្នុងប្រអប់ចំនួន៣គឺៈ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួន៣ រូបដែលតែងតាំងដោយព្រះមហាក្សត្រ ដាក់ក្នុងមួយប្រអប់ សមាជិកសមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួន៣ រូបដែលជ្រើសតាំងដោយរដ្ឋសភា ដាក់ក្នុងមួយប្រអប់ និងមួយប្រអប់ទៀត ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួន៣រូប ដែលជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ បន្ទាប់មក ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ លូកដៃចាប់យកឈ្មោះពីក្នុងប្រអប់នីមួយៗដាច់ដោយឡែកពីគ្នា ដើម្បីសម្រេចពីការបែងចែកក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញជាផ្លូវការ។ បន្ទាប់មកទៀត ប្រធានក្រុមប្រឹក្សាធម្មនុញ្ញតែងតាំងសមាជិករាយការណ៍ ដែលអាចប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាធម្មនុញ្ញក្នុងពេលប្រតិបត្តិការងារ ដោយគ្រាន់តែជូនព័ត៌មានទៅកាន់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។

ទោះបីក្នុងករណីណាក៏ដោយ សមាជិករាយការណ៍ត្រូវតែរាយការណ៍ជូនអង្គប្រជុំបឋម។ របាយការណ៍នេះ ត្រូវដាក់ជូនអង្គប្រជុំពេញអង្គដើម្បីពិភាក្សា និងសម្រេចជាស្ថាពរ។ ចំពោះគ្រប់សំណើឲ្យពិនិត្យទាំងអស់ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចក្នុងពេលវេលាមួយ ដែលមានកំណត់នៅក្នុងច្បាប់ និងតាមមតិភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល (៥ សម្លេងយ៉ាងតិច)។[65]

## ៣.៣. ការចេញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាធម្មនុញ្ញ មានសិទ្ធិអញ្ជើញជនណាម្នាក់ ឬច្រើននាក់ មកបំភ្លឺ ដល់ឯកសារដែលពាក់ព័ន្ធបាន។ បុគ្គលគ្រប់រូបដែលរួមមានៈ គ្រប់ស្ថាប័នរដ្ឋ ស្ថាប័នឯកជន ឬអង្គភាពនានាផ្សេងទៀត ត្រូវគោរពនិងប្រតិបត្តិតាមការអញ្ជើញ និងស្នើសុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសម្រេចសេចក្តីជាលាយលក្ខណ៍អក្សរលើគ្រប់ករណីដែលត្រូវបានដាក់ជូននៅក្នុងរយៈពេល៣០ថ្ងៃ។ ប្រសិនបើជាការប្រញាប់រយៈពេលនេះ ត្រូវបន្ថយមកត្រឹម៨ថ្ងៃ។[66] ក្រុមប្រឹក្សាធម្មនុញ្ញពិចារណាលើសំណើសុំបកស្រាយច្បាប់ ដោយផ្អែកលើសេចក្តីរាយការណ៍របស់សមាជិកដែលប្រធានក្រុមប្រឹក្សាធម្មនុញ្ញបានប្រគល់ភារកិច្ចឲ្យពិនិត្យរាយការណ៍។ ក្រុមប្រឹក្សាធម្មនុញ្ញ សម្រេចសេចក្តីតាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល។ ក្នុងករណីដែលបែងចែកសម្លេងជាពីរស្មើគ្នា សម្លេងរបស់ប្រធានក្រុមប្រឹក្សា-ធម្មនុញ្ញជាសម្លេងដែលមានឧត្តមានុភាព។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបញ្ជាក់អំពីហេតុផល

[64] បទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តមុខក្រុមប្រឹក្សាធម្មនុញ្ញ, លេខ២២៤ កបធ, ០៨ កក្កដា ១៩៩៨, ប្រការ៤។

[65] បទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តមុខក្រុមប្រឹក្សាធម្មនុញ្ញ, លេខ២២៤ កបធ, ០៨ កក្កដា ១៩៩៨, ប្រការ៧។

[66] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ នស/រកម/០១០៧/០០៥, ៣១ មករា ២០០៧, មាត្រា២២ថ្មី វាក្យខណ្ឌទី១។

ឲ្យបានច្បាស់លាស់។[67] ប្រភេទនៃសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ មានលក្ខណៈពិសេសត្រង់ថាគឺជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា ដែលពុំអាចធ្វើការប្ដឹងឧបាស្រ័យតទៀតបានឡើយ ព្រមទាំងមានអានុភាពអនុវត្តទៅលើគ្រប់អំណាចទាំងអស់(អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ) ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ។

សេចក្ដីសម្រេចនេះ ត្រូវផ្ញើថ្វាយព្រះមហាក្សត្រ ជូនប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និងប្រធានតុលាការកំពូល ព្រមទាំងចុះផ្សាយក្នុងរាជកិច្ច។ ក្រោយពីទទួលបានសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ អាជ្ញាធរមានសមត្ថកិច្ចមួយចំនួនត្រូវៈ

- ប្រធានព្រឹទ្ធសភា ត្រូវជូនដំណឹងអំពីសេចក្ដីសម្រេចនេះដល់សមាជិកព្រឹទ្ធសភាទាំងអស់។
- ប្រធានរដ្ឋសភា ត្រូវជូនដំណឹងអំពីសេចក្ដីសម្រេចនេះដល់សមាជិករដ្ឋសភាទាំងអស់។
- នាយករដ្ឋមន្ត្រី ត្រូវជូនដំណឹងអំពីសេចក្ដីសម្រេចនេះដល់សមាជិករាជរដ្ឋាភិបាលទាំងអស់។
- ប្រធានតុលាការកំពូល ត្រូវជូនដំណឹងអំពីសេចក្ដីសម្រេចនេះដល់តុលាការសាមី។[68]

[67] ច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ នស/រកម/០១០៧/០០៥, ៣១ មករា ២០០៧, មាត្រា២២ថ្មី វាក្យខណ្ឌទី៤។

[68] ច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ នស/រកម/០១០៧/០០៥, ៣១ មករា ២០០៧, មាត្រា២៤ថ្មី។

# ជំពូកទី៣
# សមិទ្ធផលសំខាន់ៗរបស់
# ក្រុមប្រឹក្សាធម្មនុញ្ញ
# នៃព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី៣
# សមិទ្ធផលសំខាន់ៗរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

ចាប់តាំងពីក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានបង្កើតឡើងជាផ្លូវការនៅឆ្នាំ១៩៩៨ មក ស្ថាប័ននេះបាននឹងកំពុងដើរតួនាទី និងបំពេញភារកិច្ចយ៉ាងខ្ជាប់ខ្ជួន ស្របទៅតាមចក្ខុវិស័យរបស់ស្ថាប័ន ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធ។ ក្នុងនាមជាស្ថាប័នកំពូលមួយរបស់ជាតិ ដែលមានឯករាជ្យភាព និងអព្យាក្រឹត្យភាពជានិច្ចកាលក្រុមប្រឹក្សាធម្មនុញ្ញ តែងតែអនុវត្តសកម្មភាពការងារ និងបេសកកម្មរបស់ខ្លួន ប្រកបដោយសុចរិតភាព ប្រសិទ្ធភាព យុត្តិធម៌ និង គិតគូរអំពីឧត្តមប្រយោជន៍ជាតិជាធំ។

តួយ៉ាង ក្រុមប្រឹក្សាធម្មនុញ្ញ ទទួលសំណើសុំបកស្រាយមាត្រា ឬបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ និងច្បាប់ ដែលត្រូវបានប្រកាសឲ្យប្រើរួចហើយ និងពីសំណាក់បុគ្គល ឬឥស្សរជនដែលមានសិទ្ធិស្នើសុំ ដើម្បីធ្វើការពន្យល់ ព្រមទាំងស្រាយបំភ្លឺតបទៅនឹងសំណើនោះ។ ជាងនេះទៅទៀត ស្ថាប័ននេះ ក៏ទទួលសំណើសុំធ្វើការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ពីអ្នកដែលមានសិទ្ធិស្នើសុំស្របតាមច្បាប់ ដោយការត្រួតពិនិត្យធម្មនុញ្ញភាពនោះ ត្រូវបានបែងចែកជា២ ប្រភេទគឺៈ ការត្រួតពិនិត្យបែបអាទិ-កាល(មុនប្រកាសឲ្យប្រើច្បាប់) និង ការត្រួតពិនិត្យបែបបច្ឆាកាល(ក្រោយច្បាប់ត្រូវបានប្រកាសឲ្យប្រើ)។ ម្យ៉ាងវិញទៀត ក្រុមប្រឹក្សាធម្មនុញ្ញ ជាស្ថាប័នមានសមត្ថកិច្ចទទួលសំណុំរឿងនៃបណ្ដឹងនានាជុំវិញវិវាទទាក់ទងនឹងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភាពីបុគ្គលដែលមានសមត្ថកិច្ច រួមមានបណ្ដឹងមួយចំនួនដូចជាៈ បណ្ដឹងតវ៉ានឹងសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បណ្ដឹងតវ៉ានឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត និងបណ្ដឹងទាមទារឲ្យលុបឈ្មោះអ្នកបោះឆ្នោតចេញពីបញ្ជីបោះឆ្នោត។

ដូច្នេះ គេអាចសន្និដ្ឋានបានថា ក្រុមប្រឹក្សាធម្មនុញ្ញបានចូលរួមបំពេញភារកិច្ច និងអនុវត្តតួនាទីយ៉ាងសកម្មក្នុងការដោះស្រាយបញ្ហានានាដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន។ ជាលទ្ធផលដែលទទួលបាន ស្ថាប័នកំពូលរបស់ជាតិមួយនេះ បានសម្រេចសមិទ្ធផលប្រកបដោយគុណតម្លៃមួយចំនួន[69]ដូចជាៈ

- ពិគ្រោះមតិយោបល់ និងសំណើផ្សេងៗ ចំនួន១៣ សំណើ
- ធ្វើការដោះស្រាយវិវាទបោះឆ្នោត ចំនួន១៤៣ សំណុំរឿង
- ចេញសេចក្ដីសម្រេចតបនឹងសំណើសុំបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ចំនួន២១ សំណើ
- ត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ព្រមទាំងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងព្រឹទ្ធសភា ចំនួន៩៥ សំណើ
- ពិចារណាលើសំណើមិនចូលសមត្ថកិច្ច ឬខុសទម្រង់ ចំនួន៥២ សំណើ។

[69] ក្រុមប្រឹក្សាធម្មនុញ្ញ, *លទ្ធផលដែលសម្រេចបាន* (ភ្នំពេញៈ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, ២០២០), https://www.ccc.gov.kh/whatisccc_kh.php (ចូលទស្សនាថ្ងៃទី១៣ ឧសភា ២០២១)។

## ផ្នែកទី១៖ សមិទ្ធផលទាក់ទងនឹងការបកស្រាយច្បាប់

ក្រុមប្រឹក្សាធម្មនុញ្ញ បានសម្រេចលទ្ធផលវិជ្ជមានជាច្រើនជុំវិញការបកស្រាយមាត្រា ឬបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ និងច្បាប់ដែលត្រូវបានស្នើឡើងពីសំណាក់បុគ្គល ឬឥស្សរជនដែលមានសិទ្ធិលើកសំណើ។ ទន្ទឹមនឹងនេះ ការបកស្រាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ នឹងក្លាយទៅជាឧបករណ៍គតិយុត្តមួយសម្រាប់យកទៅអនុវត្តចំពោះស្ថាប័នកំពូលៗរបស់ជាតិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។ អាស្រ័យហេតុនេះហើយ យើងនឹងធ្វើការសិក្សាទៅលើសមិទ្ធផលរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ទាក់ទងនឹងការបកស្រាយរដ្ឋធម្មនុញ្ញ(១.១) និងការបកស្រាយច្បាប់(១.២)។

### ១.១. ការបកស្រាយរដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញ ជាច្បាប់កំពូលរបស់ជាតិ ឬលក្ខន្តិកៈនៃរដ្ឋ ដែលបង្កើតឡើងដើម្បីផ្តល់អំណាចឲ្យស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័នតុលាការ បង្ហាញអំពីការរៀបចំអង្គការរដ្ឋនានា ដើរតួនាទីជាប្រភពនៃច្បាប់ និងលិខិតបទដ្ឋានដទៃទៀត ការកំណត់អំពីរបបនយោបាយ ប្រព័ន្ធសេដ្ឋកិច្ច ការបែងចែកអំណាចសាធារណៈ ព្រមទាំងបញ្ញត្តិអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋគ្រប់រូប។

ការបកស្រាយមាត្រា ឬបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ប្រៀបដូចជាការកំណត់នូវក្រឹត្យក្រមរួមមួយសម្រាប់ការប្រតិបត្តិ ឬអនុវត្តឲ្យមានភាពត្រឹមត្រូវ និងច្បាស់លាស់ក្នុងករណីដែលមានភាពស្រពិចស្រពិល ឬមានមន្ទិលសង្ស័យត្រង់ចំណុចណាមួយ ក្នុងគោលដៅឲ្យស្របទៅតាមស្មារតី និងមិនប្រាសចាកពីក្របខណ្ឌ ឬគន្លងនៃរដ្ឋធម្មនុញ្ញ។

តួយ៉ាងក្រុមប្រឹក្សាធម្មនុញ្ញ បានសម្រេចលទ្ធផលជាផ្លែផ្កាមួយចំនួន ដែលជាបច្ច័យនៃការបកស្រាយរដ្ឋធម្មនុញ្ញចាប់តាំងពីឆ្នាំ១៩៩៨ មកទល់នឹងពេលបច្ចុប្បន្ន មានចំនួន១១ សេចក្តីសម្រេច ដែលស្មើនឹង១១ សំណើ។

ក្រុមប្រឹក្សាធម្មនុញ្ញ បានសម្រេចសមិទ្ធផលជាវិជ្ជមានដូចខាងក្រោមៈ

- ឆ្នាំ១៩៩៩ សម្រេចបានចំនួន ០២ សំណើ
- ឆ្នាំ២០០០ សម្រេចបានចំនួន ០២ សំណើ
- ឆ្នាំ២០០២ សម្រេចបានចំនួន ០២ សំណើ
- ឆ្នាំ២០០៣ សម្រេចបានចំនួន ០១ សំណើ
- ឆ្នាំ២០០៤ សម្រេចបានចំនួន ០១ សំណើ
- ឆ្នាំ២០០៩ សម្រេចបានចំនួន ០១ សំណើ
- ឆ្នាំ២០១០ សម្រេចបានចំនួន ០១ សំណើ និង

- ឆ្នាំ២០១៥ សម្រេចបានចំនួន ០១ សំណើ។[70]

ដូចនេះ សមិទ្ធផលទាំងអស់ខាងលើនេះ ជាវឌ្ឍនភាពការងារនៃក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងការបំពេញតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួន ក្នុងនាមជាស្ថាប័នកំពូលមួយរបស់ជាតិ ដែលមានឯករាជ្យភាព និងអព្យាក្រឹត្យភាព។

### ១.២. ការបកស្រាយច្បាប់

ច្បាប់ ជាវិធានប្រើសម្រាប់គ្រប់គ្រងទំនាក់ទំនងបុគ្គលនៅក្នុងសង្គម ឬជាអត្ថបទសរសេរដែលត្រូវបានឆ្លងកាត់ការអនុម័តរបស់រដ្ឋសភា និងពិនិត្យចប់សព្វគ្រប់ដោយព្រឹទ្ធសភា ព្រមទាំងប្រកាសឲ្យប្រើដោយព្រះមហាក្សត្រ(បរិបទកម្ពុជា)។ ដូច្នេះ ច្បាប់ដែលត្រូវបានតាក់តែងឡើងមក ត្រូវកំណត់អំពីៈ បទប្បញ្ញត្តិទូទៅ គោលបំណង គោលដៅ វិសាលភាព សមត្ថកិច្ច អន្តរប្បញ្ញត្តិ អវសានប្បញ្ញត្តិ និងទោសប្បញ្ញត្តិ(បើមាន) សម្រាប់អនុវត្តឲ្យបានត្រឹមត្រូវ និងច្បាស់លាស់ដោយស្របទៅតាមគតិច្បាប់ ឬមានទម្រង់ជាការបង្កើត ការរៀបចំ ព្រមទាំងការប្រព្រឹត្តទៅនៃស្ថាប័នណាមួយជាដើម។

ការបកស្រាយមាត្រា ឬបទប្បញ្ញត្តិណាមួយនៃច្បាប់ ហាក់ដូចជាការស្វែងរកផ្លូវមួយដែលមានភាពត្រឹមត្រូវសម្រាប់យកទៅអនុវត្តឲ្យមានប្រសិទ្ធភាព ដោយស្របតាមឆន្ទៈរបស់អ្នកតាក់តែងច្បាប់ និងគោលបំណងដើមនៃច្បាប់។ មូលហេតុដែលជាកាតាលីករជម្រុញឲ្យ មានការបកស្រាយច្បាប់ គឺបណ្តាលមកពីភាពមិនច្បាស់លាស់នៃពាក្យពេចន៍ ឬខ្លឹមសារណាមួយក្នុងមាត្រា ឬបទប្បញ្ញត្តិណាមួយនៃអត្ថបទច្បាប់នោះ និងដោយសារមានការលើកឡើងជាទស្សនៈខុសៗគ្នាដោយគ្មានមូលដ្ឋានជាក់លាក់ រួមទាំងការខ្វែងគំនិតគ្នាមួយចំនួនជុំវិញការបកស្រាយផងដែរ។ កត្តាទាំងនេះហើយ ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាស្ថាប័នមានសមត្ថកិច្ចតែមួយគត់ក្នុងការចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងការពន្យល់ បកស្រាយខ្លឹមសារ និងអត្ថន័យនៃមាត្រា ឬបទប្បញ្ញត្តិណាមួយនៃច្បាប់ ជាលក្ខណៈផ្លូវការតាមសំណើសុំបកស្រាយពីសំណាក់បុគ្គល ឬតស្សរជនដែលមានសិទ្ធិស្នើសុំ។

យ៉ាងណាមិញ គេសង្កេតឃើញថាក្រុមប្រឹក្សាធម្មនុញ្ញ បានសម្រេចសមិទ្ធផលដែលគួរឲ្យកត់សម្គាល់មួយចំនួន ដែលទាក់ទងទៅនឹងការបកស្រាយច្បាប់ ចាប់តាំងពីឆ្នាំ១៩៩៨ មកទល់នឹងពេលបច្ចុប្បន្ន មានចំនួន ១០ សេចក្តីសម្រេច ដែលត្រូវនឹង១០ សំណើ។

ជាលទ្ធផល ក្រុមប្រឹក្សាធម្មនុញ្ញ បានសម្រេចស្នាដៃមួយចំនួនដូចជាៈ

- ឆ្នាំ២០០១ សម្រេចបានចំនួន ០២ សំណើ
- ឆ្នាំ២០០២ សម្រេចបានចំនួន ០២ សំណើ
- ឆ្នាំ២០០៣ សម្រេចបានចំនួន ០២ សំណើ

[70] ក្រុមប្រឹក្សាធម្មនុញ្ញ, *លទ្ធផលដែលសម្រេចបានទាក់ទងនឹងការបកស្រាយរដ្ឋធម្មនុញ្ញ* (ភ្នំពេញៈ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, ២០២០), https://www.ccc.gov.kh/whatisccc_kh.php (ចូលទស្សនាថ្ងៃទី១៣ ឧសភា ២០២១)។

- ឆ្នាំ២០០៩ សម្រេចបានចំនួន ០២ សំណើ និង
- ឆ្នាំ២០១០ សម្រេចបានចំនួន ០២ សំណើ។[71]

ជារួមមក គិតចាប់តាំងពីឆ្នាំ២០០៣ មកទល់ពេលបច្ចុប្បន្ន គេបានប្រទះឃើញមានសំណើសុំបកស្រាយមាត្រា ឬបទប្បញ្ញត្តិណាមួយនៃច្បាប់មួយចំនួនត្រូវបានស្នើសុំមកកាន់ក្រុមប្រឹក្សាធម្មនុញ្ញដើម្បីស្រាយបំភ្លឺ និងពន្យល់ ដែលមានដូចជាៈ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ(មាត្រា១២៤ថ្មី វាក្យខណ្ឌទី១) ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(មាត្រា១៦ និងមាត្រា៣០) ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ(មាត្រា១៧ មាត្រា១៨ និងមាត្រា២៩) និងច្បាប់ភូមិបាល(មាត្រា១៦ វាក្យខណ្ឌទី៤)។

## ផ្នែកទី២៖ សមិទ្ធផលពាក់ព័ន្ធនឹងការត្រួតពិនិត្យធម្មនុញ្ញភាព

បន្ថែមពីលើការបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញ ក៏មានសមត្ថកិច្ចសំខាន់មួយទៀតពោលគឺ ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់។ ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ សំដៅដល់ការពិនិត្យមើលថា តើច្បាប់នោះស្របទៅនឹងគោលការណ៍ និងខ្លឹមសារនៃរដ្ឋធម្មនុញ្ញដែរឬយ៉ាងណា។ ម៉្យាងវិញទៀត ការត្រួតពិនិត្យធម្មនុញ្ញភាព អាចធ្វើការត្រួតពិនិត្យទៅលើច្បាប់ទាំងមូល ឬត្រួតពិនិត្យទៅលើមាត្រា ឬបទប្បញ្ញត្តិណាមួយនៃច្បាប់ ដោយផ្អែកទៅតាមសំណើសុំត្រួតពិនិត្យរបស់អាជ្ញាធរមានសមត្ថកិច្ចលើកសំណើ។ ជាងនេះទៅទៀត គិតចាប់តាំងពីក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានបង្កើតឡើងជាផ្លូវការមក ស្ថាប័ននេះ បានសម្រេចលទ្ធផលគួរឲ្យកត់សម្គាល់ជាច្រើនពាក់ព័ន្ធនឹងការត្រួតពិនិត្យធម្មនុញ្ញភាព ដែលត្រូវបានស្នើឡើងពីសំណាក់បុគ្គល ឬតស្សូរជនដែលមានសិទ្ធិលើកសំណើ។ ហេតុនេះហើយ យើងនឹងសិក្សាអំពីសមិទ្ធផលនៃក្រុមប្រឹក្សាធម្មនុញ្ញជុំវិញ ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការ(២.១) ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ធម្មតា(២.២) និងការត្រួតពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងព្រឹទ្ធសភា(២.៣)។

### ២.១. ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការ

ច្បាប់រៀបចំអង្គការ ឬច្បាប់អង្គិន សំដៅលើច្បាប់ដែលកំណត់អំពីការបង្កើតក្រសួង ស្ថាប័ន ការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័ន ឬអង្គការណាមួយ ព្រមទាំងមានបញ្ញត្តិអំពីសមត្ថកិច្ចរបស់ស្ថាប័ននោះផងដែរ។ ការត្រួតពិនិត្យទៅលើធម្មនុញ្ញភាពនៃច្បាប់នេះ គឺត្រូវតែធ្វើឡើងជាអាទិកាល បានសេចក្តីថា ត្រូវតែត្រួតពិនិត្យជាមុនដាច់ខាតពីសំណាក់ក្រុមប្រឹក្សាធម្មនុញ្ញ មុននឹងប្រកាសឲ្យប្រើដោយព្រះរាជក្រមរបស់ព្រះមហាក្សត្រ។ ប៉ុន្តែក្រុមប្រឹក្សាធម្មនុញ្ញ មិនត្រូវអនុញ្ញាតឲ្យធ្វើការត្រួតពិនិត្យដោយខ្លួនឯង ដោយគ្មានសំណើពីបុគ្គល ឬតស្សូរជនដែលមានសមត្ថកិច្ចនោះទេ។ ដោយអនុលោមតាមស្មារតីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បុគ្គល ឬ

[71] ក្រុមប្រឹក្សាធម្មនុញ្ញ, *លទ្ធផលដែលសម្រេចបានពាក់ព័ន្ធនឹងការបកស្រាយច្បាប់* (ភ្នំពេញ៖ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, ២០២០), https://www.ccc.gov.kh/whatisccc_kh.php (ចូលទស្សនាថ្ងៃទី១៣ ឧសភា ២០២១)។

ឥស្សរជនដែលមានសិទ្ធិលើកសំណើសុំត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការ និងវិសោធនកម្មនៃច្បាប់រៀបចំអង្គការ ទៅកាន់ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យមុននឹងច្បាប់នោះ ត្រូវប្រកាសឲ្យប្រើ មានដូចជាៈ ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា តំណាងរាស្ត្រចំនួនមួយភាគដប់ ឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន។[72]

ក្រុមប្រឹក្សាធម្មនុញ្ញ បានសម្រេចលទ្ធផលស្តីពីការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការ បានចំនួន ៥៧ សេចក្តីសម្រេច ស្មើនឹង ៥៧ សំណើ ដែលក្នុងនោះយើងនឹងលើកយកសំណើសំខាន់ៗ[73] មកធ្វើការបង្ហាញដូចខាងក្រោមៈ

- នៅក្នុងឆ្នាំ ១៩៩៩ ប្រធានរដ្ឋសភា បានស្នើសុំត្រួតពិនិត្យធម្មនុញ្ញភាពនៃៈ
  ១-ច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
  ២-ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
  ៣-ច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
  ៤-ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន
  ៥-ច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និង
  ៦-ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។[74]
- នៅក្នុងឆ្នាំ ២០០៤ ប្រធានរដ្ឋសភា បានស្នើសុំត្រួតពិនិត្យធម្មនុញ្ញភាពនៃៈ
  ១-ច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
  ២-ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
  ៣-ច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
  ៤-ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ និង
  ៥-ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ។
- នៅក្នុងឆ្នាំ ២០១៣ ប្រធានរដ្ឋសភា បានស្នើសុំត្រួតពិនិត្យធម្មនុញ្ញភាពនៃៈ
  ១-ច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
  ២-ច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ

---

[72] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ នស/រកម/០១០៧/០០៥, ៣១ មករា ២០០៧, មាត្រា១៧ថ្មី។

[73] ក្រុមប្រឹក្សាធម្មនុញ្ញ, *កម្រងសេចក្តីសម្រេចពីឆ្នាំ២០០៣ ដល់ឆ្នាំ២០២១* (ភ្នំពេញៈ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, ២០២១), https://www.ccc.gov.kh/decision_kh.php (ចូលទស្សនាថ្ងៃទី១៧ ឧសភា ២០២១)។

[74] ឈុន ណារ៉េត, *សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ*, បោះពុម្ពលើកទី២ (ភ្នំពេញៈ ផាងពុម្ពដារ៉ា, ២០១៦), ៧៩-៨០។

៣-ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម

៤-ច្បាប់ស្តីពីវិសោធនកម្មច្បាប់ មាត្រា២៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី និង

៥-ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាការពារជាតិ។

- នៅក្នុងឆ្នាំ ២០១៤ ប្រធានរដ្ឋសភា បានស្នើសុំត្រួតពិនិត្យធម្មនុញ្ញភាពនៃ:

១-ច្បាប់ស្តីការរៀបចំអង្គតុលាការ និង

២-ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

- នៅក្នុងឆ្នាំ ២០១៨ ប្រធានរដ្ឋសភា បានស្នើសុំត្រួតពិនិត្យធម្មនុញ្ញភាពនៃ:

១-ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី និង

២-ច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

- នៅក្នុងឆ្នាំ ២០២០ ប្រធានរដ្ឋសភា បានស្នើសុំត្រួតពិនិត្យធម្មនុញ្ញភាពនៃ:

១-ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និង

២-ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍។

ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញ បានពិនិត្យធម្មនុញ្ញភាពតបទៅនឹងសំណើខាងលើ និងសំណើដទៃទៀត ដោយបានចេញសេចក្តីសម្រេចផ្លូវការដែលជាសេចក្តីសម្រេចបិទផ្លូវតវ៉ា សម្រាប់យកទៅអនុវត្តឲ្យស្របទៅតាមស្មារតីនៃរដ្ឋធម្មនុញ្ញ។

### ២.២. ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ធម្មតា

ច្បាប់ធម្មតា ជាច្បាប់ទាំងឡាយណាដែលមិនមែនជាច្បាប់រៀបចំអង្គការ។ ច្បាប់ធម្មតា សំដៅលើច្បាប់ដែលចែងមកសម្រាប់អនុវត្តក្នុងវិស័យណាមួយ ឬមានលក្ខណៈជាទូទៅ។ ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះអាចធ្វើឡើងជាអាទិកាល ឬបច្ឆាកាល ដោយផ្អែកទៅលើភាពចាំបាច់ និងអាស្រ័យទៅតាមឆន្ទៈរបស់បុគ្គល ឬអាជ្ញាធរដែលមានសិទ្ធិស្នើសុំ។

ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា តំណាងរាស្ត្រចំនួនមួយភាគដប់ ឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន អាចមានសិទ្ធិលើកសំណើសុំត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ធម្មតា ទៅកាន់ក្រុមប្រឹក្សាធម្មនុញ្ញ មុននឹងច្បាប់នោះ ត្រូវប្រកាសឲ្យប្រើ។ ផ្ទុយទៅវិញ ការត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិ-កាល ចំពោះច្បាប់ធម្មតា មិនមែនជាលក្ខខណ្ឌដាច់ខាតឡើយ។

ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ប្រភេទនេះ ក៏អាចត្រូវធ្វើឡើងក្នុងទម្រង់ជាបច្ឆាកាល(ក្រោយពីច្បាប់ត្រូវបានប្រកាសឲ្យប្រើ) ផងដែរ ដោយព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា តំណាងរាស្ត្រចំនួនមួយភាគដប់ ឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន តុលាការ ឬប្រជារាស្ត្រ(តាមរយៈប្រធានព្រឹទ្ធសភា

ប្រធានរដ្ឋសភា សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន និងតំណាងរាស្ត្រមួយភាគដប់)បានស្នើសុំឡើង ទៅកាន់ក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យអំពីភាពស្រប ឬមិនស្របនៃច្បាប់ទៅនឹងរដ្ឋធម្មនុញ្ញ។[75]

ក្រុមប្រឹក្សាធម្មនុញ្ញ បានសម្រេចសមិទ្ធផលចម្បងៗ ជាច្រើនជុំវិញការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ធម្មតា បានចំនួន ១៩ សេចក្តីសម្រេច ត្រូវនឹង ១៩ សំណើ ដែលក្នុងនោះយើងនឹងលើកយកសំណើសំខាន់[76]មកបង្ហាញដូចខាងក្រោមៈ

- នៅក្នុងឆ្នាំ ២០០៤ ក្រុមប្រឹក្សាធម្មនុញ្ញ បានពិនិត្យធម្មនុញ្ញភាពនៃៈ
  ១-មាត្រា៦៣ នៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល
  ២-ច្បាប់ស្តីពីបាតុកម្ម និង
  ៣-ច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការប្រក្រតីនៃស្ថាប័នជាតិ។
- នៅក្នុងឆ្នាំ ២០០៦ ក្រុមប្រឹក្សាធម្មនុញ្ញ បានពិនិត្យធម្មនុញ្ញភាពនៃៈ
  ១-មាត្រា៤ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ និង
  ២-មាត្រា៥ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ។
- នៅក្នុងឆ្នាំ ២០១០ ក្រុមប្រឹក្សាធម្មនុញ្ញ បានពិនិត្យធម្មនុញ្ញភាពនៃៈ
  ១-ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និង
  ២-ច្បាប់ស្តីពីអស្សាមិករណ៍។
- នៅក្នុងឆ្នាំ ២០១៨ ក្រុមប្រឹក្សាធម្មនុញ្ញ បានពិនិត្យធម្មនុញ្ញភាពនៃៈ
  ១-ច្បាប់ស្តីពីវិសោធនកម្ម មាត្រា ៤៥ថ្មី(ស្ទួន) នៃច្បាប់ស្តីពីគណបក្សនយោបាយ និង
  ២-ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា។
- នៅក្នុងឆ្នាំ ២០២០ ក្រុមប្រឹក្សាធម្មនុញ្ញ បានពិនិត្យធម្មនុញ្ញភាពនៃ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន។

ដូចនេះ រាល់សំណើខាងលើនេះ សុទ្ធតែត្រូវបានត្រួតពិនិត្យធម្មនុញ្ញភាពនិងសម្រេចពីសំណាក់ក្រុម-ប្រឹក្សាធម្មនុញ្ញ ក្នុងឋានៈជាស្ថាប័នកំពូលតែមួយគត់ ដែលរដ្ឋធម្មនុញ្ញបានប្រគល់សមត្ថកិច្ចទៅឲ្យ។

[75] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ នស/រកម/០១០៧/០០៥, ៣១ មករា ២០០៧, មាត្រា១៨ថ្មី។

[76] ក្រុមប្រឹក្សាធម្មនុញ្ញ, *កម្រងសេចក្តីសម្រេចពីឆ្នាំ២០០៣ ដល់ឆ្នាំ២០២១* (ភ្នំពេញៈ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, ២០២១), https://www.ccc.gov.kh/decision_kh.php (ចូលទស្សនាថ្ងៃទី១៧ ឧសភា ២០២១)។

## ២.៣. ការត្រួតពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងព្រឹទ្ធសភា

តាមស្មារតីនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលបានធ្វើវិសោធនកម្មនៅឆ្នាំ១៩៩៩ រួចមក ប្រទេសកម្ពុជាប្រកាន់យករបបទ្វិកសភា ដែលអំណាចនីតិប្បញ្ញត្តិ ត្រូវបានប្រគល់ទៅឲ្យរដ្ឋសភា និងព្រឹទ្ធសភា។ ក្នុងនាមជាស្ថាប័នកំពូលរបស់ជាតិ រដ្ឋសភា និងព្រឹទ្ធសភា ត្រូវតែមានវិធានសម្រាប់គ្រប់គ្រងឲ្យបានត្រឹមត្រូវ ច្បាស់លាស់ និងប្រកបដោយប្រសិទ្ធភាព។ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងព្រឹទ្ធសភា ជាលក្ខន្តិកៈ ឬវិធានអនុវត្តន៍ផ្ទៃក្នុងសម្រាប់រៀបចំ និងបញ្ញត្តិអំពីដំណើរការប្រព្រឹត្តទៅជាប្រក្រតីនៃស្ថាប័នរដ្ឋសភា និងព្រឹទ្ធសភា។

ការត្រួតពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងព្រឹទ្ធសភា ឬវិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងព្រឹទ្ធសភា គឺត្រូវតែធ្វើឡើងជាអាទិកាល បានសេចក្តីថា ក្រោយពេលដែលរដ្ឋសភា និងព្រឹទ្ធសភាបានអនុម័តទៅលើបទបញ្ជាផ្ទៃក្នុង ឬវិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងរបស់ស្ថាប័នខ្លួនរួចហើយ វាជាកាតព្វកិច្ចដែលត្រូវបញ្ជូនទៅកាន់ក្រុមប្រឹក្សាធម្មនុញ្ញ ពីសំណាក់ប្រធានរដ្ឋសភា ឬប្រធានព្រឹទ្ធសភា ដើម្បីត្រួតពិនិត្យអំពីភាពស្រប ឬមិនស្របនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងព្រឹទ្ធសភាទៅនឹងរដ្ឋធម្មនុញ្ញ មុននឹងប្រកាសឲ្យប្រើ។[77] ការត្រួតពិនិត្យជាលក្ខណៈដាច់ខាតនេះ មានគោលដៅទប់ស្កាត់ កុំឲ្យការតាក់តែងទាំងឡាយណារបស់ស្ថាប័ននីតិប្បញ្ញត្តិ មានចេតនាបំពានទៅដល់អំណាចដទៃទៀត និងមានភាពអនាធិបតេយ្យ ជាពិសេសបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងព្រឹទ្ធសភាតែម្តង។

តួយ៉ាង ក្រុមប្រឹក្សាធម្មនុញ្ញ បានសម្រេចលទ្ធផលស្តីពីការត្រួតពិនិត្យធម្មនុញ្ញភាព នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងព្រឹទ្ធសភា បានចំនួន ១៨ សេចក្តីសម្រេច ស្មើនឹង១៨ សំណើ ដែលក្នុងនោះយើងនឹងលើកយកសំណើសំខាន់ៗ[78]មកធ្វើការបង្ហាញដូចខាងក្រោមៈ

- នៅក្នុងឆ្នាំ ១៩៩៩ ក្រុមប្រឹក្សាធម្មនុញ្ញ បានត្រួតពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា តាមសំណើរបស់ប្រធានព្រឹទ្ធសភា។
- នៅក្នុងឆ្នាំ ២០០៣ ក្រុមប្រឹក្សាធម្មនុញ្ញ បានត្រួតពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មប្រការ ៣៦ និងប្រការ ៣៨ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា តាមសំណើរបស់ប្រធានរដ្ឋសភា។
- នៅក្នុងឆ្នាំ ២០០៤ ក្រុមប្រឹក្សាធម្មនុញ្ញ បានត្រួតពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា តាមសំណើរបស់ប្រធានស្តីទីរដ្ឋសភា។
- នៅក្នុងឆ្នាំ ២០០៥ ក្រុមប្រឹក្សាធម្មនុញ្ញ បានត្រួតពិនិត្យធម្មនុញ្ញភាពនេះ
  ១-ប្រការ ៤៤ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា តាមសំណើរបស់ប្រធានព្រឹទ្ធសភា

[77] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ នស/រកម/០១០៧/០០៥, ៣១ មករា ២០០៧, មាត្រា១៦ថ្មី វាក្យខណ្ឌទី២ និងទី៣។

[78] ក្រុមប្រឹក្សាធម្មនុញ្ញ, *កម្រងសេចក្តីសម្រេចពីឆ្នាំ២០០៣ ដល់ឆ្នាំ២០២១* (ភ្នំពេញៈ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, ២០២១), https://www.ccc.gov.kh/decision_kh.php (ចូលទស្សនាថ្ងៃទី១៧ ឧសភា ២០២១)។

២-ប្រការ ៤៧ថ្មី(ពីរ) នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា តាមសំណើរបស់ប្រធានរដ្ឋសភាស្តីទី និង
៣-វិសោធនកម្មប្រការ២ ៣ ៤ ៥ ៦ ៧ ៩ ១០ ១៤ ១៥ ១៧ ២២ ៣១ថ្មី ៣៣ ៤០ ៤១ ៤៨ ៥១ ៥៥ ៥៦ ៥៨ ៥៩ ៦០ និងប្រការ ៨៣ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា តាមសំណើរបស់ប្រធានរដ្ឋសភា។

- នៅក្នុងឆ្នាំ ២០០៦ ក្រុមប្រឹក្សាធម្មនុញ្ញ បានត្រួតពិនិត្យធម្មនុញ្ញភាពនៃៈ

១-វិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា តាមសំណើរបស់ប្រធានព្រឹទ្ធសភា
២-បទបញ្ជាផ្ទៃក្នុងថ្មីនៃព្រឹទ្ធសភា តាមសំណើរបស់ប្រធានព្រឹទ្ធសភា
៣-វិសោធនកម្មប្រការ១៥ថ្មី និងប្រការ៤៨ថ្មី នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា តាមសំណើរបស់ប្រធានរដ្ឋសភា
៤-វិសោធនកម្មប្រការ២ថ្មី ៥ថ្មី ១០ថ្មី ៣៥ ៤៧ថ្មី(ពីរ) និងប្រការ៨២ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា តាមសំណើរបស់អនុប្រធានទី១ រដ្ឋសភា។

- នៅក្នុងឆ្នាំ ២០១៤ ក្រុមប្រឹក្សាធម្មនុញ្ញ បានត្រួតពិនិត្យធម្មនុញ្ញភាពនៃៈ

១-វិសោធនកម្ម ជំពូកទី១២ ប្រការ៤៨ថ្មី(ពីរ) នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា តាមសំណើរបស់ប្រធានរដ្ឋសភា
២-វិសោធនកម្ម ប្រការ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣ តាមសំណើរបស់ប្រធានស្តីទីព្រឹទ្ធសភា និង
៣-វិសោធនកម្ម ប្រការ១៦ ថ្មី នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា តាមសំណើរបស់ប្រធានរដ្ឋសភា។

- នៅក្នុងឆ្នាំ ២០១៧ ក្រុមប្រឹក្សាធម្មនុញ្ញ បានត្រួតពិនិត្យធម្មនុញ្ញភាពនៃៈ

១-វិសោធនកម្មប្រការ៩ ប្រការ១១ ប្រការ១២ ប្រការ១៤ ប្រការ៧៨ ប្រការ៧៩ ប្រការ៨០ ប្រការ៨១ និងចំណងជើងជំពូកទី១៣ ព្រមទាំងបន្ថែមជំពូកទី១២ (ស្ទួន) ប្រការ៧៥(ស្ទួន) និងប្រការ ៧៧(ស្ទួន) នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា តាមសំណើរបស់ប្រធានស្តីទីព្រឹទ្ធសភា និង
២-វិសោធនកម្ម ជំពូកទី១២ថ្មី ប្រការ៤៨ថ្មី(បី) នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា តាមសំណើរបស់ប្រធានរដ្ឋសភា។

ដូច្នេះ គេអាចសន្និដ្ឋានបានថា ក្រុមប្រឹក្សាធម្មនុញ្ញ បានបំពេញតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនជុំវិញការត្រួតពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ព្រឹទ្ធសភា និងវិសោធនកម្មនានានៃបទបញ្ជាផ្ទៃក្នុងរបស់ស្ថាប័នទាំងពីរ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ សុចរិតភាព ឯករាជ្យភាព និងអព្យាក្រឹត្យភាព។

## ផ្នែកទី៣ៈ សមិទ្ធផលដែលជាបច្ច័យនៃការដោះស្រាយវិវាទបោះឆ្នោត

ក្រុមប្រឹក្សាធម្មនុញ្ញ ពុំមែនមានតែសមត្ថកិច្ចក្នុងការបកស្រាយរដ្ឋធម្មនុញ្ញ ឬច្បាប់ និងធ្វើការត្រួតពិនិត្យធម្មនុញ្ញនៃច្បាប់ប៉ុណ្ណោះទេ។ ប៉ុន្តែស្ថាប័ននេះ ក៏បន្តមានសមត្ថកិច្ចក្នុងការសម្រេចអំពីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាផងដែរ។ បើយើងក្រឡេកទៅ

មើលពីសមិទ្ធផលរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ទាក់ទងនឹងវិវាទកម្មនៃការបោះឆ្នោតវិញ ដោយគិតចាប់តាំងពីឆ្នាំ ១៩៩៨ មកទល់នឹងពេលបច្ចុប្បន្ន ស្ថាប័ននេះបានដោះស្រាយ និងចេញសេចក្តីសម្រេចផ្លូវការចំនួន ១៤៣ ដែលស្មើនឹង១៤៣ បណ្តឹង។[79] កត្តានេះហើយ យើងនឹងធ្វើការសិក្សាទៅលើសមិទ្ធផលរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលជាបច្ច័យនៃការដោះស្រាយបណ្តឹងតវ៉ានឹងសេចក្តីសម្រេច របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(៣.១) ការដោះស្រាយបណ្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត(៣.២) និងការដោះស្រាយបណ្តឹងទាមទារឲ្យលុបឈ្មោះអ្នកបោះឆ្នោតចេញពីបញ្ជីបោះឆ្នោត(៣.៣)។

### ៣.១. ការដោះស្រាយបណ្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់គ.ជ.ប

ការដោះស្រាយបណ្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាផ្នែកមួយនៃសមត្ថកិច្ចក្នុងការដោះស្រាយវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្រ្ត និងសមាជិកព្រឹទ្ធសភារបស់ក្រុមប្រឹក្សាធម្មនុញ្ញ។ សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មិនមែនជាសេចក្តីសម្រេចបិទផ្លូវតវ៉ានោះទេ។ ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលបណ្តឹងតវ៉ា និងបានប្រជុំពេញអង្គរួចហើយ ដោយចេញសេចក្តីសម្រេចផ្លូវការ ក្នុងអត្ថន័យតម្កល់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល បានសេចក្តីថាសេចក្តីសម្រេចរបស់គ.ជ.ប ដែលត្រូវបានប្តឹងតវ៉ានោះ នឹងក្លាយជាសេចក្តីសម្រេចចុងក្រោយបិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្ត ដោយអនុលោមតាមខ្លឹមសារនៃសេចក្តីសម្រេចរបស់ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ។

ក្រុមប្រឹក្សាធម្មនុញ្ញ ធ្វើការពិនិត្យ និងសម្រេចៈ

- លើបណ្តឹងតវ៉ាជាលាយលក្ខណ៍អក្សររបស់គណបក្សនយោបាយ ឬរបស់បេក្ខជន ចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធបេក្ខភាព ឬសម្រេចបដិសេធបញ្ជីរាយនាមបេក្ខជនរបស់ខ្លួន។ ការប្តឹងនេះ ត្រូវធ្វើឡើងក្នុងរយៈពេល ០៥ថ្ងៃ យ៉ាងយូរ ក្រោយពីបានទទួលលិខិតជូនដំណឹងបដិសេធពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។[80]
- លើបណ្តឹងតវ៉ាជាលាយលក្ខណ៍អក្សររបស់បុគ្គល ឬតំណាង ចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធបណ្តឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោតរបស់ខ្លួន។ ការប្តឹងនេះត្រូវធ្វើឡើងក្នុងរយៈពេល ០៥ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃដែលទទួលបានសេចក្តីចម្លងសេចក្តីសម្រេចពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។[81]

---

[79] ក្រុមប្រឹក្សាធម្មនុញ្ញ, *លទ្ធផលដែលសម្រេចបានពាក់ព័ន្ធនឹងការដោះស្រាយវិវាទបោះឆ្នោត* (ភ្នំពេញៈ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, ២០២០), https://www.ccc.gov.kh/whatisccc_kh.php (ចូលទស្សនាថ្ងៃទី១៣ ឧសភា ២០២១)។

[80] ច្បាប់ស្តីពីវិសោធនកម្ម មាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ នស/រកម/០៣១៨/០០៥, ១០ មីនា ២០១៨, មាត្រា២៦.១ថ្មី វាក្យខណ្ឌទី១។

[81] ច្បាប់ស្តីពីវិសោធនកម្ម មាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ នស/រកម/០៣១៨/០០៥, ១០ មីនា ២០១៨, មាត្រា២៦.២ថ្មី វាក្យខណ្ឌទី១។

គេសង្កេតឃើញថា ក្រុមប្រឹក្សាធម្មនុញ្ញ បានសម្រេចលទ្ធផលវិជ្ជមានជាច្រើន ពាក់ព័ន្ធនឹងការដោះស្រាយបណ្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានប្តឹងឡើងពីគណបក្សនយោបាយ ឬតំណាងដែលមានចំនួន ៤៨ សេចក្តីសម្រេច ស្មើនឹង៤៨ បណ្តឹងតវ៉ា ហើយក្នុងនោះយើងនឹងលើកយកបណ្តឹងមួយចំនួន[82]មកបង្ហាញដូចខាងក្រោមៈ

- ក្នុងឆ្នាំ ២០០៨ ក្រុមប្រឹក្សាធម្មនុញ្ញ បានចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងៈ

១-ពាក្យបណ្តឹងរបស់លោកមេធាវី គង់ សំអុន ជាដើមបណ្តឹងតំណាងឲ្យគណបក្ស សម រង្ស៊ី ដែលបានប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ៥៨៩/០៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១២ ខែ សីហា ឆ្នាំ២០០៨

២-ពាក្យបណ្តឹងរបស់លោក ប៉ែនសុន សម័យ និងលោក គា អ៊ាវ ជាមេធាវីតំណាងគណបក្សប្រជាជនកម្ពុជា ដែលប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០០៨

៣-ពាក្យបណ្តឹងរបស់លោក ហ៊ុល ថុល ជាបេក្ខជនបម្រុងលំដាប់លេខ២ មណ្ឌលភ្នំពេញ គណបក្ស សម រង្ស៊ី តំណាងលោកស្រី ថៃ ណារី ដែលប្តឹងបដិសេធនឹងសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៨។

- ក្នុងឆ្នាំ ២០១៣ ក្រុមប្រឹក្សាធម្មនុញ្ញ បានចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងៈ

១-ពាក្យបណ្តឹងរបស់ឯកឧត្តម អេង ឆៃអ៊ាង ជាតំណាងគណបក្សសង្គ្រោះជាតិ ដែលប្តឹងតវ៉ានឹងសម្រង់សេចក្តីសម្រេចលេខ ០២១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

២-ពាក្យបណ្តឹងរបស់លោកជំទាវ កែ សុវណ្ណរតន៍ ជាតំណាងគណបក្សសង្គ្រោះជាតិ ដែលប្តឹងតវ៉ានឹងសម្រង់សេចក្តីសម្រេចលេខ ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

៣-ពាក្យបណ្តឹងរបស់លោក សួន ចំរើន ជាតំណាងគណបក្សសង្គ្រោះជាតិ ដែលប្តឹងតវ៉ានឹងសម្រង់សេចក្តីសម្រេចលេខ ០២០/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង

[82] ក្រុមប្រឹក្សាធម្មនុញ្ញ, *កម្រងសេចក្តីសម្រេចពីឆ្នាំ២០០៣ ដល់ឆ្នាំ២០២១* (ភ្នំពេញ៖ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, ២០២១), https://www.ccc.gov.kh/decision_kh.php (ចូលទស្សនាថ្ងៃទី១៧ ឧសភា ២០២១)។

៤-ពាក្យបណ្តឹងរបស់លោក គុល ប្រាសាទ ជាតំណាងគណបក្សសង្គ្រោះជាតិ ដែលប្តឹងជំទាស់នឹងសម្រេចសេចក្តីសម្រេចលេខ ០១១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

- ក្នុងឆ្នាំ ២០២០ ក្រុមប្រឹក្សាធម្មនុញ្ញ បានចេញសេចក្តីសម្រេចពាក់ព័ន្ធនឹង:

១-ពាក្យបណ្តឹងរបស់សមាជិក និងភ្នាក់ងារគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ដែលបានប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចលេខ ០០៦ គ.ជ.ប លេខ០០៩ គ.ជ.ប លេខ០១១ គ.ជ.ប លេខ០១៤ គ.ជ.ប ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០ លេខ០៣២ គ.ជ.ប លេខ០៣៧ គ.ជ.ប លេខ០៤៤ គ.ជ.ប លេខ០៤៥ គ.ជ.ប លេខ០៤៧ គ.ជ.ប ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

២-ពាក្យបណ្តឹងរបស់សមាជិក និងភ្នាក់ងារគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ដែលប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០៣៥ គ.ជ.ប លេខ០៣៦ គ.ជ.ប លេខ០៣៨ គ.ជ.ប លេខ០៣៩ លេខ០៤០គ.ជ.ប ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០ លេខ០៦៣ គ.ជ.ប លេខ០៦៧ គ.ជ.ប ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ លេខ០៨៨ គ.ជ.ប លេខ០៨៩ គ.ជ.ប ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង

៣-ពាក្យបណ្តឹងរបស់សមាជិក និងភ្នាក់ងារគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ដែលប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០១២ គ.ជ.ប លេខ០១៣ គ.ជ.ប លេខ០១៨ គ.ជ.ប លេខ០២៦ គ.ជ.ប លេខ០១៧ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០ លេខ០៣៣ គ.ជ.ប លេខ០៣៤ គ.ជ.ប លេខ០២៨ គ.ជ.ប លេខ០៥២ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០ លេខ០៥៧ គ.ជ.ប និងលេខ០៥៩ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

### ៣.២. ការដោះស្រាយបណ្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត

ក្នុងសង្គមប្រជាធិបតេយ្យ និងនីតិរដ្ឋ ការប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត គឺជាចំណុចរសើប ព្រោះថាការបោះឆ្នោតប្រកបដោយសេរី ស្មើភាព ត្រឹមត្រូវ និងយុត្តិធម៌ គឺជាគោលការណ៍គ្រឹះមួយនៃលទ្ធិប្រជាធិបតេយ្យ ដែលបង្ហាញពីឆន្ទៈពិតរបស់ប្រជាពលរដ្ឋក្នុងការជ្រើសតាំងតំណាងរបស់ខ្លួនសម្រាប់ដឹកនាំប្រទេស ដើម្បីឈានទៅរកភាពរីកចម្រើន សន្តិសុខ សណ្តាប់ធ្នាប់ និងសន្តិភាព។ គោលគំនិតនៃការបើកផ្លូវឲ្យប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ន បានបង្កប់ទស្សនៈវិស័យជាគោលដៅក្នុងការលើកកម្ពស់គុណតម្លៃនៃប្រជាធិបតេយ្យ និងនីតិរដ្ឋ បង្កើតសង្គមមួយដែលស្ថិរភាពនយោបាយ ព្រមទាំងបញ្ចៀសភាពអសកម្ម និងភាពមិនប្រក្រតីមួយចំនួនទាក់ទងនឹងដំណើរការនៃការបោះឆ្នោត ដោយគិតចាប់តាំងពីការរៀបចំការចាប់ផ្តើម ការប្រព្រឹត្តទៅ ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត។

ជាសក្ខីភាព តាមស្មារតីនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ប្រទេសកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ដែលបានលាតត្រដាងយ៉ាងច្បាស់ថាកម្ពុជា ធានានិងបើកសិទ្ធិយ៉ាងទូលំទូលាយដល់គណ-

បក្សនយោបាយទាំងអស់ចូលរួមក្នុងការប្រកួតប្រជែងបោះឆ្នោត។ នៅក្នុងបរិបទបែបនេះ ជាពិសេសបន្ទាប់ពីក្រោយពេលប្រកាសអំពីលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត គេអាចព្យាករបានថា ប្រាកដជាមានភាពមិនអស់ចិត្ត និងការតវ៉ានានាកើតឡើង។ កត្តាទាំងនេះហើយ បណ្ដាលឲ្យអ្នកតាក់តែងច្បាប់បានបង្កើតឲ្យមានយន្តការនៃការដោះស្រាយបណ្ដឹងតវ៉ានឹងលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភាឡើង ហើយបានប្រគល់ជូនសមត្ថកិច្ចទៅកាន់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជាអ្នកបំពេញតួនាទីក្នុងនាមជាស្ថាប័នកំពូលឯករាជ្យ និងអព្យាក្រឹត្យ។

ក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យនិងសម្រេចលើៈ

- បណ្ដឹងតវ៉ាដោយផ្ទាល់ ជាលាយលក្ខណ៍អក្សររបស់គណបក្សនយោបាយ ដែលបានឈរឈ្មោះបោះឆ្នោត ចំពោះលទ្ធផលបោះឆ្នោតបណ្ដោះអាសន្ន។ បណ្ដឹងនេះ ត្រូវបានធ្វើឡើងក្នុងរយៈពេល៧២ ម៉ោង យ៉ាងយូរបន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតបណ្ដោះអាសន្ន។[83]
- បណ្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរពីសំណាក់បុគ្គល ឬគណបក្សនយោបាយ ចំពោះសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធបណ្ដឹងតវ៉ាទៅលើលទ្ធផលបោះឆ្នោតបណ្ដោះអាសន្នរបស់ខ្លួន។ បណ្ដឹងនេះ ត្រូវបានធ្វើឡើងក្នុងរយៈពេល៧២ម៉ោង យ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងពីការបដិសេធ។[84]

ជាក់ស្ដែង ក្រុមប្រឹក្សាធម្មនុញ្ញ បានសម្រេចសមិទ្ធផលជាផ្លែផ្កាជាច្រើន ទាក់ទងនឹងការដោះស្រាយបណ្ដឹងតវ៉ានឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ដែលមានចំនួន ១៥ សេចក្ដីសម្រេច ស្មើនឹង១៥ បណ្ដឹងតវ៉ា ហើយក្នុងនោះ យើងនឹងលើកយកបណ្ដឹងមួយចំនួន[85]មកបង្ហាញដូចខាងក្រោមៈ

- នៅក្នុងឆ្នាំ ២០០៣ ក្រុមប្រឹក្សាធម្មនុញ្ញ បានចេញសេចក្ដីសម្រេចពាក់ព័ន្ធនឹងបណ្ដឹងរបស់ ឯកឧត្តម សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី ដែលប្ដឹងតវ៉ាអំពីលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅឆ្នាំ ២០០៣។
- នៅក្នុងឆ្នាំ ២០០៨ ក្រុមប្រឹក្សាធម្មនុញ្ញ បានចេញសេចក្ដីសម្រេចពាក់ព័ន្ធនឹងៈ

១-បណ្ដឹងរបស់លោក ញឹក វណ្ណារ៉ា តំណាងគណបក្សសិទ្ធិមនុស្ស ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៨ ដែលប្ដឹងជំទាស់ទៅនឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៤ ដោយគណៈក-

[83] ច្បាប់ស្ដីពីវិសោធនកម្ម មាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ នស/រកម/០៣១៨/០០៥, ១០ មីនា ២០១៨, មាត្រា២៦.៤ថ្មី វាក្យខណ្ឌទី១។

[84] ច្បាប់ស្ដីពីវិសោធនកម្ម មាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ នស/រកម/០៣១៨/០០៥, ១០ មីនា ២០១៨, មាត្រា២៦.៥ថ្មី វាក្យខណ្ឌទី១។

[85] ក្រុមប្រឹក្សាធម្មនុញ្ញ, *កម្រងសេចក្ដីសម្រេចពីឆ្នាំ២០០៣ ដល់ឆ្នាំ២០២១* (ភ្នំពេញៈ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, ២០២១), https://www.ccc.gov.kh/decision_kh.php (ចូលទស្សនាថ្ងៃទី១៧ ឧសភា ២០២១)។

ម្មាធិការជាតិរៀបចំការបោះឆ្នោត បំប៉ោងបញ្ជីឈ្មោះបោះឆ្នោត ដោយបន្ថែមឈ្មោះស្ទួនច្រើននាក់ក្នុងបញ្ជីបោះឆ្នោតតាមការិយាល័យនីមួយៗ និង

២-បណ្តឹងរបស់លោក មាស ខេង តំណាងគណបក្ស សម រង្ស៊ី ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៨ ដែលប្តឹងពីភាពមិនប្រក្រតីនៃការរាប់សន្លឹកឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសូមឲ្យរាប់សន្លឹកឆ្នោតទាំង ៦៥០ ការិយាល័យឡើងវិញ(បដិសេធពាក្យបណ្តឹងរបស់លោកមាស ខេង ប្តឹងបដិសេធលទ្ធផលបោះឆ្នោតបណ្តោះអាសន្ននៅខេត្តស្វាយរៀង)។

- នៅក្នុងឆ្នាំ ២០១៣ ក្រុមប្រឹក្សាធម្មនុញ្ញ បានចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងៈ

១-បណ្តឹងរបស់លោក រស់ សួ ជាតំណាងគណបក្សសង្គ្រោះជាតិ ដែលប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តបន្ទាយមានជ័យ។

២-បណ្តឹងរបស់លោក ហូរ វ៉ាន ជាតំណាងគណបក្សសង្គ្រោះជាតិ ដែលប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលរាជធានីភ្នំពេញ។

៣-បណ្តឹងរបស់លោក ងឹម ញៀង ជាតំណាងគណបក្សសង្គ្រោះជាតិ ដែលប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តពោធិ៍សាត់។

៤-បណ្តឹងរបស់លោក រស់ សួ ជាតំណាងគណបក្សសង្គ្រោះជាតិ ដែលប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តកំពង់ស្ពឺ។

៥-បណ្តឹងរបស់លោក ឡុង ប៊ុន្នី ជាតំណាងគណបក្សសង្គ្រោះជាតិ ដែលប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តព្រៃវែង។ល។

### ៣.៣. ការដោះស្រាយបណ្តឹងទាមទារឲ្យលុបឈ្មោះអ្នកបោះឆ្នោត ចេញពីបញ្ជីបោះឆ្នោត

បញ្ជីឈ្មោះបោះឆ្នោតត្រូវបែងចែកជា២ប្រភេទគឺៈ បញ្ជីឈ្មោះបោះឆ្នោតដំបូង និងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការ។ បញ្ជីឈ្មោះបោះឆ្នោតផ្លូវការ ជាបញ្ជីឈ្មោះ ដែលត្រូវបានផ្តល់សុពលភាពដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងត្រូវប្រកាសផ្សាយ ៩០ថ្ងៃយ៉ាងតិច មុនថ្ងៃបោះឆ្នោត។[86] ជាងនេះទៅទៀត មានតែអ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីផ្លូវការប៉ុណ្ណោះ ទើបមានសិទ្ធិចូលរួមបោះឆ្នោតបាន។ ម្យ៉ាងវិញទៀត ដើម្បីបោះឆ្នោតបាន ប្រជាពលរដ្ឋខ្មែរត្រូវតែបំពេញគ្រប់ទៅតាមលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ក្នុងស្ថានភាពជាក់ស្តែង គេតែងតែជួបប្រទះនូវបញ្ហាមួយចំនួនពាក់ព័ន្ធទៅនឹងការទាមទារឲ្យលុបឈ្មោះអ្នកបោះឆ្នោតចេញពីបញ្ជីឈ្មោះបោះឆ្នោត ដោយលើកឡើងអំពីលក្ខណៈសម្បត្តិរបស់អ្នកបោះឆ្នោតនោះមិនបានបំពេញគ្រប់ទៅតាមលក្ខខណ្ឌដែលច្បាប់បានតម្រូវ។ ហេតុនេះហើយ ច្បាប់បានប្រគល់សមត្ថកិច្ចនៃការដោះស្រាយបណ្តឹងទាមទារឲ្យលុបឈ្មោះអ្នកបោះឆ្នោត ចេញពីបញ្ជីឈ្មោះបោះឆ្នោត

[86] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ, លេខ នស/រកម/០៣១៥/០០៣, ២៦ មីនា ២០១៥, មាត្រា៤៤ វាក្យខណ្ឌទី៦។

ទៅកាន់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលជាស្ថាប័នមានសិទ្ធិសម្រេចជាផ្លូវការ បន្ទាប់ពីមានសេចក្តីសម្រេចដំបូងរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

ក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ា ឬជំទាស់ជាលាយលក្ខណ៍អក្សររបស់បុគ្គល ឬតំណាងចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធការតវ៉ាអំពីការបាត់ឈ្មោះ ឬលើការជំទាស់អំពីការចុះឈ្មោះ ឬការរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃបុគ្គលម្នាក់ដែលមានលក្ខណៈមិនត្រឹមត្រូវតាមលក្ខខណ្ឌនៃច្បាប់បោះឆ្នោត។ បណ្តឹងនេះ ត្រូវបានធ្វើឡើងក្នុងរយៈពេល ០៥ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានសេចក្តីចម្លងសេចក្តីសម្រេចពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។[87]

ដោយឡែក ក្រុមប្រឹក្សាធម្មនុញ្ញ បានសម្រេចលទ្ធផលមួយចំនួនជុំវិញការដោះស្រាយបណ្តឹងទាមទារឲ្យលុបឈ្មោះអ្នកបោះឆ្នោតចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ដែលមានចំនួន០៦ សេចក្តីសម្រេច ស្មើនឹង០៦បណ្តឹង ហើយក្នុងនោះ យើងនឹងលើកយកបណ្តឹងខ្លះៗ[88]មកបង្ហាញដូចខាងក្រោមៈ

- ក្នុងឆ្នាំ ២០០៦ ក្រុមប្រឹក្សាធម្មនុញ្ញ បានចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងៈ

១-បណ្តឹងរបស់លោក ពឹម សំណាង ជាសមាជិកគណៈកម្មាធិការបោះឆ្នោត គណបក្ស សម រង្ស៊ី ដែលប្តឹងទាមទារលុបឈ្មោះជនជាតិវៀតណាម ចេញពីបញ្ជីឈ្មោះបោះឆ្នោត និងបដិសេធសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះហត្ថលេខាដោយឯកឧត្តម អ៊ឹម សួស្តី នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៦។

២-បណ្តឹងរបស់លោក ទូច វិទ្ធី ជាសមាជិកគណៈកម្មាធិការបោះឆ្នោត គណបក្ស សម រង្ស៊ី ដែលប្តឹងទាមទារលុបឈ្មោះជនជាតិវៀតណាម ចំនួន ៥.៤១៣នាក់ ចេញពីបញ្ជីឈ្មោះបោះឆ្នោត និងបដិសេធសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះហត្ថលេខាដោយឯកឧត្តម អ៊ឹម សួស្តី នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៦។

៣-បណ្តឹងរបស់លោក ឡេង សេង ជាសមាជិកគណៈកម្មាធិការបោះឆ្នោត គណបក្ស សម រង្ស៊ី ដែលប្តឹងទាមទារលុបឈ្មោះជនជាតិវៀតណាមចំនួន ២៥៧នាក់ ចេញពីបញ្ជីឈ្មោះបោះឆ្នោត និងបដិសេធសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះហត្ថលេខាដោយឯកឧត្តម អ៊ឹម សួស្តី នៅថ្ងៃទី១២ និងទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៦។

៤-បណ្តឹងរបស់លោក ឌីណា សាគុណ ជាសមាជិកគណៈកម្មាធិការបោះឆ្នោត គណបក្ស សម រង្ស៊ី ដែលប្តឹងទាមទារលុបឈ្មោះជនជាតិវៀតណាម ចំនួន១.៦០៤នាក់ ចេញពីបញ្ជីឈ្មោះបោះឆ្នោត និងបដិសេធ

[87] ច្បាប់ស្តីពីវិសោធនកម្ម មាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ នស/រកម/០៣១៨/០០៥, ១០ មីនា ២០១៨, មាត្រា២៦.៣ថ្មី វាក្យខណ្ឌទី១។

[88] ក្រុមប្រឹក្សាធម្មនុញ្ញ, *កម្រងសេចក្តីសម្រេចពីឆ្នាំ២០០៣ ដល់ឆ្នាំ២០២១* (ភ្នំពេញៈ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, ២០២១), https://www.ccc.gov.kh/decision_kh.php (ចូលទស្សនាថ្ងៃទី១៧ ឧសភា ២០២១)។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះហត្ថលេខាដោយឯកឧត្តម អ៊ឹម សួស្តី នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៦។

៥-បណ្តឹងរបស់លោក ថាន់ ឃុនសារិន ជាសមាជិកគណៈកម្មាធិការបោះឆ្នោត គណបក្ស សម រង្ស៊ី ដែលប្តឹងទាមទារលុបឈ្មោះអ្នកបោះឆ្នោត ចំនួន០៨នាក់ នៅសង្កាត់ច្បារអំពៅទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ចេញពីបញ្ជីឈ្មោះបោះឆ្នោត។

- នៅក្នុងឆ្នាំ ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញ បានចេញសេចក្តីសម្រេចពាក់ព័ន្ធទៅនឹងបណ្តឹង របស់លោក ឡុង លឹមហ៊ា ជាសមាជិកគណៈកម្មាធិការបោះឆ្នោត គណបក្ស សម រង្ស៊ី ដែលប្តឹងទាមទារឲ្យលុបឈ្មោះជនជាតិវៀតណាម ចំនួន២.០៣៣នាក់ ចេញពីបញ្ជីឈ្មោះបោះឆ្នោត និងបដិសេធសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះហត្ថលេខាដោយឯកឧត្តម អ៊ឹម សួស្តី នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៧។

សរុបសេចក្តីមក ក្រុមប្រឹក្សាធម្មនុញ្ញ បានដើរតួនាទី និងចូលរួមយ៉ាងសកម្មក្នុងការសម្រេចសេចក្តីអំពីវិវាទកម្មទាក់ទងនឹងការបោះឆ្នោត ដោយបានចេញសេចក្តីសម្រេចជាផ្លូវការបិទផ្លូវតវ៉ា ប្រកបដោយឯករាជ្យភាព សុចរិតភាព អព្យាក្រឹត្យភាព ទំនួលខុសត្រូវ និងយុត្តិធម៌ចំពោះរាល់បណ្តឹងនានាដែលបានប្តឹងចូលមកកាន់ក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងគោលដៅដើម្បីពិនិត្យ និងដោះស្រាយ ព្រមទាំងសម្រេចសេចក្តី។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សា និងបកស្រាយយ៉ាងក្បោះក្បាយទៅលើប្រធានបទនៃសារណាបញ្ចប់ការសិក្សានេះរួចមក យើងអាចសន្និដ្ឋានបានថា ក្រុមប្រឹក្សាធម្មនុញ្ញ ឬតុលាការធម្មនុញ្ញ ស្ទើរតែមានសមត្ថកិច្ចដូចគ្នាទៅហើយ តាមបណ្តាប្រទេសមួយចំនួននៅលើសកលលោក ដោយឡែកមានចំណុចមិនដូចគ្នាមួយត្រង់ថា មានការប្រើប្រាស់ឈ្មោះស្ថាប័នខុសគ្នាតែប៉ុណ្ណោះ។ ក្រុមប្រឹក្សាធម្មនុញ្ញ ជាស្ថាប័នកំពូលមួយដែលមានភាពឯករាជ្យ និងអព្យាក្រឹត្យ ព្រមទាំងស្ថិតនៅចន្លោះអំណាចទាំងបីរបស់រដ្ឋ។ ជាងនេះទៅទៀត ត្បិតតែក្រុមប្រឹក្សាធម្មនុញ្ញ ជាស្ថាប័នកំពូលដាច់ដោយឡែកមួយក៏ពិតមែន ជាពិសេសមិនស្ថិតក្រោមឥទ្ធិពលនៃអំណាចនយោបាយណាមួយក៏ដោយ ប៉ុន្តែអង្គការនេះ ត្រូវបានប្រសូតឡើងតាមរយៈរដ្ឋធម្មនុញ្ញ ដែលត្រូវបានគេស្គាល់ថាជាច្បាប់កំពូលរបស់ជាតិ។ ក្នុងបរិបទកម្ពុជា ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានបង្កើតឡើងដោយផ្អែកទៅលើហេតុផលមួយចំនួនក្នុងគោលដៅ ដើម្បីធានាដំណើរនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការកសាងនីតិរដ្ឋ ការគោរពសិទ្ធិមនុស្ស និងការអនុវត្តយុទ្ធសាស្រ្ត គោលនយោបាយរបស់រាជរដ្ឋាភិបាល ការពារឆន្ទៈរបស់សភាធម្មនុញ្ញ ធានាឧត្តមភាពនៃរដ្ឋធម្មនុញ្ញ ក៏ដូចជាដើម្បីចូលរួមដោះស្រាយវិវាទទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភា។

ដើម្បីញ៉ាំងឲ្យស្ថាប័ននេះ កាន់តែមានស្ថិរភាព និងនិរន្តរភាព រដ្ឋសភាបានបង្កើតច្បាប់រៀបចំអង្គការមួយសម្រាប់ការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គការកំពូលមួយនេះ ដែលគេហៅថា« **ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ**»។ លើសពីនេះទៅទៀត រដ្ឋធម្មនុញ្ញ និងច្បាប់រៀបចំអង្គការនេះ បានបញ្ញត្តិអំពីសមាសភាពរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ អាជ្ញាធរមានសមត្ថកិច្ចតែងតាំង និងជ្រើសតាំង មុខងារវិសមិតភាព ការចូលកាន់តំណែង ការដកចេញពីសមាជិកភាព ការតែងតាំង ឬជ្រើសតាំងសមាជិកថ្មី ឬសមាជិកជំនួស ជាពិសេសកំណត់អំពីសមត្ថកិច្ចជាក់លាក់ជាសារវន្តមួយចំនួនសម្រាប់អនុញ្ញាតឲ្យក្រុមប្រឹក្សាធម្មនុញ្ញអាចបំពេញតួនាទី និងអនុវត្តភារកិច្ចប្រកបដោយប្រក្រតីភាព សុចរិតភាព អព្យាក្រឹត្យភាព និងឯករាជ្យភាព។ យ៉ាងណាមិញ ក្នុងនាមជាស្ថាប័នកំពូលរបស់ជាតិ ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែមានបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន សម្រាប់គោរព និងប្រតិបត្តិ ដោយមានគោលដៅដើម្បីបញ្ចៀសភាពអនាធិបតេយ្យ និងគ្មានសណ្តាប់ធ្នាប់ក្នុងដំណើរការប្រព្រឹត្តទៅក្នុងស្ថាប័ន ក៏ដូចជាដើម្បីរក្សាឲ្យបានភាពថ្លៃថ្នូរ និងពង្រឹងកិត្យានុភាពរបស់ស្ថាប័នខ្លួនផងដែរ។ បន្ថែមពីលើនេះទៅទៀត ក្រុមប្រឹក្សាធម្មនុញ្ញ ក៏បានបន្តអនុម័តបទបញ្ជាផ្ទៃក្នុងសម្រាប់អនុវត្តចំពោះមុខក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានចែងអំពីនីតិវិធីលម្អិតស្តីពីការអនុវត្ត ដោយចាប់ផ្តើមពីដំណាក់កាលពិនិត្យ និងចុះបញ្ជីសំណើ និងបណ្តឹងនានាពីអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងអគ្គលេខាធិការដ្ឋាន ដំណាក់កាលបែងចែកក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញសម្រាប់ពិនិត្យ ស្រាវជ្រាវ និងរាយការណ៍ ព្រមទាំងដំណាក់កាលនៃការចេញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ បន្ទាប់ពីបានសម្រេចជាផ្លូវការនៅក្នុងសម័យប្រជុំពេញអង្គ។

ម្យ៉ាងវិញទៀត បើយើងក្រឡេកមកសិក្សាពីសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញវិញ ស្ថាប័ននេះមានសមត្ថកិច្ចធានាការពារ ការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ព្រមទាំងមានសិទ្ធិពិនិត្យ ហើយសម្រេចអំពីករណីវិវាទកម្ម ទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាផងដែរ។ បន្ថែមពីលើនេះទៅទៀត អង្គការមួយនេះក៏មានសមត្ថកិច្ចពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ាការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ប្រកាសមោឃភាពរាល់ការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឲ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ ជាពិសេសផ្តល់មតិថ្វាយព្រះមហាក្សត្រ នៅពេលដែលទ្រង់ពិគ្រោះយោបល់ជុំវិញសេចក្តីស្នើទាំងឡាយ ដែលស្នើសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ។ ក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយច្បាប់ទាំងឡាយណាដែលត្រូវបានប្រកាសឲ្យប្រើរួចហើយតែប៉ុណ្ណោះ ហើយមិនអាចបកស្រាយច្បាប់ដោយគ្មានសំណើពីសំណាក់បុគ្គល ឬតស្សរជនដែលមានសិទ្ធិស្នើសុំឡើយ។ មុននឹងឈានទៅដល់ការបកស្រាយតបទៅនឹងសំណើ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវតែពិនិត្យមើលលក្ខខណ្ឌមួយចំនួនជាចាំបាច់ដូចជាៈ សមត្ថ-ភាពរបស់បុគ្គលដែលមានសិទ្ធិស្នើសុំ ការពិនិត្យលើទម្រង់ឬបែបបទ និងគោលបំណងនៃសំណើជាមុនសិន។ បន្ទាប់ពីសំណើត្រូវបានបំពេញគ្រប់លក្ខណៈវិនិច្ឆ័យហើយ ក្រុមប្រឹក្សាធម្មនុញ្ញ នឹងធ្វើការបកស្រាយ ពន្យល់អំពីមាត្រា ឬបទប្បញ្ញត្តិណាមួយនៃច្បាប់ ដោយផ្អែកទៅលើគោលការណ៍សភាធម្មនុញ្ញ(ទី១) គោលការណ៍មូលហេតុនៃច្បាប់(ទី២) និងគោលការណ៍ទ្រឹស្តី និងស្មារតីនៃច្បាប់(ទី៣)។ ជាងនេះទៅទៀត ក្នុងការបកស្រាយតាមបែបទ្រឹស្តី និងស្មារតីនៃច្បាប់នេះ ក្រុមប្រឹក្សាធម្មនុញ្ញ បានប្រកាន់យកទស្សនៈជាមូលដ្ឋាននៃការបកស្រាយដូចជាៈ ការបកស្រាយតាមបែបស្រប ការបកស្រាយតាមបែបផ្ទុយ ការបកស្រាយតាមរយៈការប្រៀបធៀប ការបកស្រាយដោយពន្យល់ទៅលើពាក្យពេចន៍ក្នុងអត្ថបទច្បាប់ និងការបកស្រាយដោយសម្អាងទៅលើគោលគំនិតរបស់អ្នកតាក់តែងសេចក្តីព្រាង ឬសេចក្តីស្នើនៃច្បាប់នោះ។ កាន់តែពិសេសជាងនេះទៅទៀត ការបកស្រាយច្បាប់របស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវធ្វើឡើងចំពោះតែច្បាប់ដែលស្របនឹងរដ្ឋធម្មនុញ្ញតែប៉ុណ្ណោះ ដោយហេតុថាក្រុមប្រឹក្សាធម្មនុញ្ញ ធ្វើការពន្យល់ និងស្រាយបំភ្លឺច្បាប់ក្នុងក្របខណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាព។

ជារួមមក ក្រុមប្រឹក្សាធម្មនុញ្ញ នឹងចេញសេចក្តីសម្រេចក្នុងទម្រង់ផ្លូវការបិទផ្លូវតវ៉ា ដែលមានអានុភាពអនុ-វត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។ គួរបញ្ជាក់ផងដែរថាស្ថាប័ននេះ បានសម្រេចសមិទ្ធ-ផលគួរឲ្យស្ញប់ស្ញែងជាច្រើនសម្រាប់បម្រើឲ្យផលប្រយោជន៍ជាតិ និងប្រជាជនដោយគិតចាប់តាំងពីឆ្នាំ១៩៩៨ មកទល់នឹងពេលបច្ចុប្បន្ន ដែលរួមមានដូចខាងក្រោមៈ

- ពិគ្រោះមតិយោបល់ និងសំណើផ្សេងៗ ចំនួន១៣ សំណើ
- ធ្វើការដោះស្រាយវិវាទបោះឆ្នោត ចំនួន១៤៣ សំណុំរឿង

- ចេញសេចក្តីសម្រេចតបនឹងសំណើសុំបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ចំនួន២១ សំណើ
- ត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ព្រមទាំងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងព្រឹទ្ធសភា ចំនួន៩៥ សំណើ
- ពិចារណាលើសំណើមិនចូលសមត្ថកិច្ច ឬខុសទម្រង់ ចំនួន៥២ សំណើ៕

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានសិក្សាយ៉ាងស៊ីជម្រៅទៅលើប្រធានបទនៃសារណានេះហើយ គេសង្កេតឃើញថារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានចាត់ទុកក្រុមប្រឹក្សាធម្មនុញ្ញ ជាស្ថាប័នកំពូលមួយរបស់ជាតិដែលមានឯករាជ្យភាព និងអព្យាក្រឹត្យ ក្នុងការបំពេញសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលកំពុងនៅជាធរមាន។ ជាងនេះទៅទៀត សមាសភាព និងអាណត្តិរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មិនមែនជាបញ្ហាចោទនោះទេ ប៉ុន្តែហាក់បីដូចជាមានចំណុចអសកម្មមួយចំនួនពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលគប្បីកែសម្រួលដើម្បីជាភាពល្អប្រសើរនៃស្ថាប័ន។

ក្នុងនាមជាស្ថាប័នមួយនៃនីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យសេរី ដែលទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ ក៏មានចំណុចមួយចំនួនដែលគប្បីត្រូវកែលម្អផងដែរ ដែលមានដូចខាងក្រោមៈ

- ក្រុមប្រឹក្សាធម្មនុញ្ញ គួរតែមានសមត្ថកិច្ចក្នុងការបកស្រាយច្បាប់ឲ្យបានទូលំទូលាយជាងនេះ តាមរយៈការយកច្បាប់ណាមួយមកធ្វើការពន្យល់ ឬ បកស្រាយដោយខ្លួនឯង ក្នុងករណីដែលក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា មាត្រា ឬបទប្បញ្ញត្តិណាមួយនៃច្បាប់នោះ មានភាពសាំញ៉ាំ និងស្មុគស្មាញដែលជាឧបសគ្គសម្រាប់ការអនុវត្តក្នុងក្របខណ្ឌណាមួយ ព្រមទាំងពិចារណាឃើញថា ការអនុវត្តទាំងមិនច្បាស់លាស់បែបនោះ នឹងនាំមកភាពអនាធិបតេយ្យដល់សង្គម និងប៉ះពាល់ដល់ឧត្តមប្រយោជន៍ជាតិ ផលប្រយោជន៍សា-ធារណៈ ជាពិសេសឧត្តមប្រយោជន៍របស់ប្រជាពលរដ្ឋ។
- ច្បាប់ គួរតែអនុញ្ញាតឲ្យក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលសំណើ ឬបណ្តឹងពីប្រជាពលរដ្ឋដោយផ្ទាល់ដោយពិចារណាទៅលើលក្ខខណ្ឌដែលមាត្រាឬបទប្បញ្ញត្តិណាមួយនៃច្បាប់ ឬសេចក្តីសម្រេចណាមួយនៃស្ថាប័នរដ្ឋ នោះមានផលប៉ះពាល់ជាសារវន្តទៅលើផលប្រយោជន៍របស់ប្រជាជន ដើម្បីឲ្យស្របនឹងទិសដៅនៃពាក្យស្លោកមួយថា«***ច្បាប់បង្កើតឡើងដើម្បីបម្រើប្រជាជនគ្រប់រូបដោយស្មើភាព សុចរិតភាព និងយុត្តិធម៌ ហើយច្បាប់មិនមែនបង្កើតឡើងដើម្បីគាបសង្កត់ ឬជិះជាន់ប្រជាជន និងសម្រាប់បម្រើផលប្រយោជន៍របស់បក្សពួក ឬក្រុមណាមួយនៅក្នុងសង្គមឡើយ***»។
- គួរតែលុបបំបាត់យន្តការនៃការប្តឹងចូលទៅកាន់ក្រុមប្រឹក្សាធម្មនុញ្ញ ដោយឲ្យប្រជាពលរដ្ឋប្តឹងតាមរយៈតំណាងដូចជាៈ ប្រធានរដ្ឋសភា តំណាងរាស្ត្រចំនួនមួយភាគដប់ ប្រធានព្រឹទ្ធសភា សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន ដោយហេតុថាការប្តឹងតាមមធ្យោបាយនេះ គឺមានភាពលំបាកខ្លាំងណាស់។ តួយ៉ាង ទោះបីជាប្រទេសកម្ពុជាបាននឹងកំពុងប្រកាន់យក និងអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្សក៏ដោយ ប៉ុន្តែប្រជាពលរដ្ឋភាគច្រើន ពួកគាត់ស្ទើរតែមិនស្គាល់មុខរបស់តំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភាដែលបានឈរឈ្មោះនៅក្នុងមណ្ឌល ឬភូមិភាគរបស់ពួកគាត់ផង ជាហេតុនាំឲ្យការបញ្ចុះបញ្ចូលឲ្យគ្រប់តាមសម្លេងដែលច្បាប់បានតម្រូវ ជារឿងមួយដែលស្ទើរតែមិនអាចទៅរួច ឬមានអត្រាជោគជ័យទាប។

- ក្រុមប្រឹក្សាធម្មនុញ្ញ គួរតែមានសមត្ថកិច្ចត្រួតពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្តីពីវិសោធនកម្មទាំងអស់ ដោយមិនអាចបណ្តាលឲ្យមានចន្លោះណាមួយឡើយ ដើម្បីធានាឲ្យបានថា រាល់ការធ្វើវិសោធនកម្មច្បាប់ទាំងឡាយ ជាពិសេសរដ្ឋធម្មនុញ្ញ ត្រូវបានធ្វើឡើងដោយគិតគូរអំពីផលប្រយោជន៍ជាតិ និងប្រជាជនជាធំ ក្នុងគោលដៅដើម្បីបញ្ចៀសការរំលោភបំពានទៅលើឋានានុក្រមនៃច្បាប់ និងបាត់បង់តម្លៃគតិយុត្តនៃរដ្ឋធម្មនុញ្ញ។
- ក្រុមប្រឹក្សាធម្មនុញ្ញ គប្បីមានថវិកាស្វយ័ត សម្រាប់ដំណើរការស្ថាប័នរបស់ខ្លួន ដូចគ្នានឹងរដ្ឋសភា និងព្រឹទ្ធសភាផងដែរ។
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ គប្បីត្រូវបានផ្សព្វផ្សាយឲ្យបានទូលំទូលាយជាងនេះ ដោយគួរតែមានកិច្ចសហការរវាងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ ជាមួយនឹងក្រសួងព័ត៌មាន ដែលដើរតួនាទីជាសេនាធិការរបស់រាជរដ្ឋាភិបាល និងបណ្តាញផ្សព្វផ្សាយផ្លូវការក្នុងស្រុកនានា ពីព្រោះថាសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើគ្រប់អំណាចទាំងអស់ ដែលមានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ។ អាស្រ័យហេតុនេះ ប្រជាពលរដ្ឋគ្រប់រូប គួរតែទទួលបានព័ត៌មាន និង យល់ដឹងបន្ថែមទៀតអំពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងនាមខ្លួនជាម្ចាស់វាសនានៃប្រទេសជាតិ។

ដូចនេះ ដើម្បីពង្រឹងស្មារតី និងសក្តានុពល ជាស្ថាប័នកំពូលនៃនីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យសេរី ក្រុមប្រឹក្សាធម្មនុញ្ញ គប្បីសម្លឹងទៅរកការធ្វើកំណែទម្រង់មួយចំនួនដូចដែលបានរៀបរាប់ខាងលើ ក្នុងគោលដៅអភិវឌ្ឍសមត្ថភាពរបស់ស្ថាប័ន និងសមត្ថកិច្ចឲ្យកាន់តែមានឯករាជ្យភាព អព្យាក្រឹត្យភាព តម្លាភាព ប្រសិទ្ធភាព សុចរិតភាព និងយុត្តិធម៌ ប្រកបដោយស្មារតីទទួលខុសត្រូវយ៉ាងយកចិត្តទុកដាក់បំផុត និងការវាយតម្លៃខ្ពស់៕

# ឯកសារយោង

# ឯកសារយោង

## ក. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

### ក.១. រដ្ឋធម្មនុញ្ញ

- រដ្ឋធម្មនុញ្ញប្រទេសកម្ពុជាឆ្នាំ១៩៤៧, លេខ ១.០៤២ ក.ទ.ទ, ០៦ ឧសភា ១៩៤៧។
- រដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរឆ្នាំ១៩៧២, បញ្ញត្តិលេខ ១៩/៧២ បសខ, ១០ ឧសភា ១៩៧២។
- រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៦, ១៤ ធ្នូ ១៩៧៥, ០៥ មករា ១៩៧៦។
- រដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជាឆ្នាំ១៩៨១, ២៥ មិថុនា ១៩៨១, ២៥ មិថុនា ១៩៨១។
- រដ្ឋធម្មនុញ្ញរដ្ឋកម្ពុជាឆ្នាំ១៩៨៩, ៣០ មេសា ១៩៨៩, ៣០ មេសា ១៩៨៩។
- រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, ២១ កញ្ញា ១៩៩៣, ២៤ កញ្ញា ១៩៩៣។
- រដ្ឋធម្មនុញ្ញសាធារណរដ្ឋបារាំងទី៥, ២៨ កញ្ញា ១៩៥៨, ០៤ តុលា ១៩៥៨។

### ក.២. ច្បាប់

- ច្បាប់ស្តីពីវិសោធនកម្ម មាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ នស/រកម/០៣១៨/០០៥, ១០ មីនា ២០១៨។
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ, លេខ នស/រកម/០៣១៥/០០៣, ២៦ មីនា ២០១៥។
- ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ នស/រកម/០១០៧/០០៥, ៣១ មករា ២០០៧។
- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ ជស/រកម/០៤៩៨/០៦, ០៨ មេសា ១៩៩៨។

### ក.៣. វិធានគតិយុត្តផ្សេងៗ

- អនុក្រឹត្យ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ១៣៨ អនក្រ.បក, ០៧ កក្កដា ២០១៦។
- អនុក្រឹត្យ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ៤៣ អនក្រ.បក, ០៧ មីនា ២០០៥។
- អនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, ០១ កក្កដា ១៩៩៨។
- សេចក្តីសម្រេច ស្តីពីវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ៣៨/២០១៧ កបធ.សសរ, ៣០ សីហា ២០១៧។
- វិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខ ២៤/២០០៧ កបធ.សសរ, ០៧ សីហា ២០០៧។

➢ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្ដីពីវិសោធនកម្មបទបញ្ជាផ្ទៃក្នុងស្ដីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ, លេខ២៥/២០០៧ កបធ.សសរ, ០៩ មីនា ២០០៧។
➢ បទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ, ២៨ កក្កដា ១៩៩៨។
➢ បទបញ្ជាផ្ទៃក្នុងស្ដីពីនីតិវិធីដែលត្រូវអនុវត្តមុខក្រុមប្រឹក្សាធម្មនុញ្ញ, លេខ២៤ កបធ, ០៨ កក្កដា ១៩៩៨។
➢ បទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ, ២៦ មិថុនា ១៩៩៨។
➢ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្ដីពីការបកស្រាយមាត្រា៩១ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, លេខ១៥៥/០០៣/២០១៥ កបធ.ច, ២៧ កក្កដា ២០១៥។
➢ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្ដីពីការបកស្រាយមាត្រា១៦ វាក្យខណ្ឌទី៤ នៃច្បាប់ភូមិបាល, លេខ១០៩/០០២/២០១០ កបធ.ច, ១២ មីនា ២០១០។
➢ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្ដីពីការបកស្រាយ និងត្រួតពិនិត្យធម្មនុញ្ញភាពនៃមាត្រា២៩ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ, លេខ១០៦/០០២/២០០៩ កបធ.ច, ១៦ មីនា ២០០៩។
➢ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្ដីពីការបកស្រាយមាត្រា១៧ និង១៨ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ, លេខ១០៥/០០១/២០០៩ កបធ.ច, ២៥ កុម្ភៈ ២០០៩។
➢ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្ដីពីការបកស្រាយមាត្រា៧ នៃរដ្ឋធម្មនុញ្ញ, លេខ០៦១/០០៣/២០០៤ កបធ.ច, ០៧ កញ្ញា ២០០៤។
➢ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្ដីពីការបកស្រាយមាត្រា១២៤ថ្មី វាក្យខណ្ឌទី១ នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ, លេខ០៥៨/០០៩/២០០៣ កបធ.ច, ១៦ តុលា ២០០៣។
➢ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្ដីពីការបកស្រាយមាត្រា៧៦ វាក្យខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, លេខ០៥៤/០០៥/២០០៣ កបធ.ច, ២២ កក្កដា ២០០៣។

## ខ. សៀវភៅ និងឯកសារចងក្រង

➢ ឈុន ណារ៉េត. ២០១៦, *សេចក្ដីផ្ដើមនីតិរដ្ឋធម្មនុញ្ញ*, បោះពុម្ពលើកទី២. ភ្នំពេញ៖ រោងពុម្ពដារ៉ា។
➢ ជុំ អ៊ឹម. ២០១២, *ស្ថាប័ននយោបាយនៃព្រះរាជាណាចក្រកម្ពុជា*, បោះពុម្ពលើកទី១. ភ្នំពេញ៖ រោងពុម្ពសុខ ចេង។
➢ ណើ ណារី. ២០១២, *សមត្ថកិច្ចក្រុមប្រឹក្សាធម្មនុញ្ញ*. សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
➢ មាស បូរ៉ា. ២០២០, *ចំណេះដឹងទូទៅស្ដីពីច្បាប់*, បោះពុម្ពលើកទី១. ភ្នំពេញ។

➢ ម៉ែន វុធ. ២០២០, *នីតិរដ្ឋធម្មនុញ្ញ និងស្ថាប័ននយោបាយ*, បោះពុម្ពលើកទី១. ភ្នំពេញ។

➢ សុខ ចិន្តា និងសុខ យ៉ាន. ២០១៨, *នីតិរដ្ឋធម្មនុញ្ញ*, បោះពុម្ពលើកទី១. ភ្នំពេញ៖ Good News Printing House។

➢ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ. ២០១១, *កម្រងឯកសារសំណួរ ចម្លើយទាក់ទងទៅនឹងរដ្ឋធម្មនុញ្ញ.* ភ្នំពេញ៖ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ។

**គ. គេហទំព័រ**

➢ ក្រុមប្រឹក្សាធម្មនុញ្ញ. ២០២១, *កម្រងសេចក្តីសម្រេចពីឆ្នាំ២០០៣ ដល់ឆ្នាំ២០២១.* ភ្នំពេញ៖ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, https://www.ccc.gov.kh/decision_kh.php (ចូលទស្សនាថ្ងៃទី១៧ ឧសភា ២០២១)។

➢ ក្រុមប្រឹក្សាធម្មនុញ្ញ. ២០២០, *លទ្ធផលដែលសម្រេចបាន.* ភ្នំពេញ៖ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, https://www.ccc.gov.kh/whatisccc_kh.php (ចូលទស្សនាថ្ងៃទី១៣ ឧសភា ២០២១)។

➢ ក្រុមប្រឹក្សាធម្មនុញ្ញ. ២០២០, *លទ្ធផលដែលសម្រេចបានទាក់ទងនឹងការបកស្រាយរដ្ឋធម្មនុញ្ញ.* ភ្នំពេញ៖ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, https://www.ccc.gov.kh/whatisccc_kh.php (ចូលទស្សនាថ្ងៃទី១៣ ឧសភា ២០២១)។

➢ ក្រុមប្រឹក្សាធម្មនុញ្ញ. ២០២០, *លទ្ធផលដែលសម្រេចបានពាក់ព័ន្ធនឹងការបកស្រាយច្បាប់.* ភ្នំពេញ៖ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, https://www.ccc.gov.kh/whatisccc_kh.php (ចូលទស្សនាថ្ងៃទី១៣ ឧសភា ២០២១)។

➢ ក្រុមប្រឹក្សាធម្មនុញ្ញ. ២០២០, *លទ្ធផលដែលសម្រេចបានពាក់ព័ន្ធនឹងការដោះស្រាយវិវាទបោះឆ្នោត.* ភ្នំពេញ៖ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ, https://www.ccc.gov.kh/whatisccc_kh.php (ចូលទស្សនាថ្ងៃទី១៣ ឧសភា ២០២១)។

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

- **ឧបសម្ព័ន្ធទី១៖** សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពីការបកស្រាយមាត្រា៩១ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, លេខ១៥៥/០០៣/២០១៥ កបធ.ច, ២៧ កក្កដា ២០១៥។
- **ឧបសម្ព័ន្ធទី២៖** សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពីការបកស្រាយមាត្រា១៦ វាក្យខណ្ឌទី៤ នៃច្បាប់ភូមិបាល, លេខ១០៩/០០២/២០១០ កបធ.ច, ១២ មីនា ២០១០។
- **ឧបសម្ព័ន្ធទី៣៖** សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពីការបកស្រាយ និងត្រួតពិនិត្យធម្មនុញ្ញភាពនៃមាត្រា២៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ, លេខ១០៦/០០២/២០០៩ កបធ.ច, ១៦ មីនា ២០០៩។
- **ឧបសម្ព័ន្ធទី៤៖** សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពីការបកស្រាយមាត្រា១៧ និង១៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ, លេខ១០៥/០០១/២០០៩ កបធ.ច, ២៥ កុម្ភៈ ២០០៩។
- **ឧបសម្ព័ន្ធទី៥៖** សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពីការបកស្រាយមាត្រា៧ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា, លេខ០៦១/០០៣/២០០៤ កបធ.ច, ០៧ កញ្ញា ២០០៤។
- **ឧបសម្ព័ន្ធទី៦៖** សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពីការបកស្រាយមាត្រា១២៤ថ្មី វាក្យខណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ, លេខ ០៥៨/០០៩/២០០៣ កបធ.ច, ១៦ តុលា ២០០៣។
- **ឧបសម្ព័ន្ធទី៧៖** សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពីការបកស្រាយមាត្រា៧៦ វាក្យខណ្ឌទី១ និងមាត្រា៩៥ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, លេខ០៥៤/០០៥/២០០៣ កបធ.ច, ២២ កក្កដា ២០០៣។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ឧបសម្ព័ន្ធទី១**

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ២៥៦/០០៣/២០១៥

ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥

**សេចក្តីសម្រេច**

លេខ : ១៥៥/០០៣/២០១៥ កបធ.ច

ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ១០៨/០៧១៥/ពស/នវ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥ របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥ វេលាម៉ោង ១៥ និង ៥១ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា លិខិតលេខ ១០៨/០៧១៥/ពស/នវ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥ របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ដែលស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើឡើងស្របនឹងវាក្យខ័ណ្ឌទី១ មាត្រា១៣៦ថ្មី

មាត្រា១៤១ថ្មីនៃរដ្ឋធម្មនុញ្ញ និងមាត្រា១៥ថ្មី មាត្រា១៨ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំបកស្រាយមាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា នេះមកពិនិត្យបាន

- យល់ឃើញថា មាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាន២វាក្យខ័ណ្ឌ ដែលចែងថា :

*"សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។ តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះសំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ ។"*

វាក្យខ័ណ្ឌទី១នៃមាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញ បានកំណត់អំពីសិទ្ធិរបស់សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី ក្នុងការផ្តួចផ្តើមគំនិតធ្វើច្បាប់ ។ វាក្យខ័ណ្ឌទី១នេះ មានន័យថា :

- សមាជិកព្រឹទ្ធសភា ១រូប ឬច្រើនរូប មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ និងមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន ។
- សមាជិករដ្ឋសភា ១រូប ឬច្រើនរូប មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ និងមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន ។
- សមាជិកព្រឹទ្ធសភានិងសមាជិករដ្ឋសភា មានសិទ្ធិរួមគ្នាផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ ឬមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន ។

ការផ្តួចផ្តើមគំនិតធ្វើច្បាប់ និងការផ្តួចផ្តើមគំនិតធ្វើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន ពីសំណាក់សមាជិកព្រឹទ្ធសភា ឬពីសមាជិករដ្ឋសភា ឬពីសមាជិកព្រឹទ្ធសភានិងសមាជិករដ្ឋសភារួមគ្នាជាហត្ថលេខី ត្រូវធ្វើជាសេចក្តីស្នើច្បាប់ និងត្រូវបំពេញទម្រង់បែបបទទៅតាមនីតិវិធីនៃការធ្វើច្បាប់ ។

- នាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីព្រាងច្បាប់ និងមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន ។ នាយករដ្ឋមន្ត្រីត្រូវធ្វើជាសេចក្តីព្រាងច្បាប់ និងត្រូវបំពេញទម្រង់បែបបទទៅតាមនីតិវិធីនៃការធ្វើច្បាប់ ។

វាក្យខ័ណ្ឌទី២នៃមាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញ មានន័យថា ជាការបញ្ជាក់បន្ថែមទៅលើខ្លឹមសារនៃវាក្យខ័ណ្ឌទី១ ដោយហាមតំណាងរាស្ត្រមិនឱ្យធ្វើវិសោធនកម្មច្បាប់ដែលសំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ ។

- យល់ឃើញថា តាមការបកស្រាយខាងលើនេះ សមាជិកព្រឹទ្ធសភាមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់បាន ។

## សម្រេច

**មាត្រា ១.-** មាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល

**ឧបសម្ព័ន្ធទី២**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៧២/០០៣/២០១០

ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១០

**សេចក្តីសម្រេច**

លេខ : ១០៩/០០២/២០១០ កបធ.ច

ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០១០

**ក្រុមប្រឹក្សាធម្មនុញ្ញ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញលិខិត ០០២/១០ រ.ស.គសរ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១០ របស់ឯកឧត្តម លោកជំទាវ អ្នកតំណាងរាស្ត្រ ១៥ រូប ជូនមកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយ មាត្រា១៦ វាក្យខ័ណ្ឌទី ៤ នៃច្បាប់ភូមិបាល ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១០ វេលាម៉ោង ១០ និង ៣០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា សំណើរបស់ឯកឧត្តម លោកជំទាវ អ្នកតំណាងរាស្ត្រ ១៥ រូប ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយ មាត្រា ១៦ វាក្យខ័ណ្ឌទី ៤ នៃច្បាប់ភូមិបាល បានធ្វើឡើងស្របតាមមាត្រា ១៣៦ ថ្មី មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ

និង មាត្រា ១៥ ថ្មី មាត្រា ១៨ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ សំណើនេះអាចទទួលយកមកពិនិត្យបាន

-យល់ឃើញថា វាក្យខ័ណ្ឌទី ៤ មាត្រា ១៦ នៃច្បាប់ភូមិបាល បានចែងថា " **ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ នៅពេលបាត់បង់ផលប្រយោជន៍សាធារណៈ អាចត្រូវចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ តាមរយៈច្បាប់អនុបយោគ** " ។ បទប្បញ្ញត្តិនៃវាក្យខ័ណ្ឌនេះ មានន័យថា កាលណាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋណាមួយ ត្រូវបានឈប់ប្រើប្រាស់ជាផលប្រយោជន៍សាធារណៈតទៅទៀតហើយ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនោះ អាចត្រូវចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋបាន តាមរយៈច្បាប់អនុបយោគ ។ ពាក្យថា " **ច្បាប់អនុបយោគ**" គឺជា ច្បាប់ដែលរំសាយពីប្រភេទទ្រព្យសម្បត្តិមួយទៅប្រភេទទ្រព្យសម្បត្តិមួយទៀត ដូចជារំសាយពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ជាដើម ។

## សម្រេច

**មាត្រា ១.** បទប្បញ្ញត្តិ នៃវាក្យខ័ណ្ឌទី ៤ មាត្រា ១៦ នៃច្បាប់ភូមិបាល ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម លេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ។

**មាត្រា ២.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០១០ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០១០

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ឧបសម្ព័ន្ធទី៣**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៦៧/០០៥/២០០៩

ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០០៩

**សេចក្តីសម្រេច**

លេខ : ១០៦/០០២/២០០៩ កបធ.ច

ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០០៩

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៤១/០០៣/២០០១ កបធ.ច ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០០១
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៩៧/០០២/២០០៨ កបធ.ច ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០០៨
- បានឃើញលិខិតគ្មានលេខ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០០៩ របស់ក្រុមអ្នកតំណាងរាស្ត្រចំនួន ១៥នាក់ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយ និង ពិនិត្យធម្មនុញ្ញភាពមាត្រា ២៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និង បកស្រាយមាត្រា ១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០០៩ វេលាម៉ោង ១៦ និង ៥០ នាទី

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា សំណើរបស់អ្នកតំណាងរាស្ត្រចំនួន ១៥ នាក់ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០០៩ ដែលស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយ និងពិនិត្យធម្មនុញ្ញភាព មាត្រា ២៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងបកស្រាយមាត្រា ១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានធ្វើឡើងស្របតាមមាត្រា ១៣៦ ថ្មី មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ ថ្មី មាត្រា ១៨ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ សំណើនេះអាចទទួលយកមកពិនិត្យបាន
- យល់ឃើញថា ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ រួមទាំងមាត្រា ២៩ ផង ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៩៧/០០២/២០០៨ កបធ.ច ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០០៨ ។ ដូច្នេះ សំណើខាងលើនេះ ត្រូវចាត់ទុកថា **ជាសំណើសុំបកស្រាយច្បាប់**
- យល់ឃើញថា មាត្រា ៣៤ ថ្មី នៃរដ្ឋធម្មនុញ្ញ វាក្យខ័ណ្ឌទី១ បានចែងថា ***" ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។ "*** និងវាក្យខ័ណ្ឌទី៥ បានចែងថា ***" បទបញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និង សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវចែងក្នុងច្បាប់បោះឆ្នោត ។ "***
- យល់ឃើញថា បទបញ្ញត្តិមាត្រា ២៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ពាក់ព័ន្ធតែនឹងបញ្ជីបោះឆ្នោត ពោលគឺបញ្ជីអ្នកបោះឆ្នោតដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងមុខតំណែងតែប៉ុណ្ណោះ ។ មាត្រានេះ ចែកជា ៣ វាក្យខ័ណ្ឌ ត្រូវបានបកស្រាយដូចតទៅ ÷

ក/វាក្យខ័ណ្ឌទី១ បានចែងថា ***" គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្តល់សុពលភាពបញ្ជីបោះឆ្នោតក្នុងរយៈពេលយ៉ាងតិចសាមសិបប្រាំ ( ៣៥ ) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ "***

បទបញ្ញត្តិនៃវាក្យខ័ណ្ឌនេះ មានន័យថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពុំអាចផ្តល់សុពលភាពបញ្ជីបោះឆ្នោត ក្រោយសាមសិបប្រាំ ( ៣៥ ) ថ្ងៃ មុនថ្ងៃបោះឆ្នោតបានទេ ។

ខ/វាក្យខ័ណ្ឌទី២ បានចែងថា ***" បញ្ជីបោះឆ្នោតដែលត្រូវបានផ្តល់សុពលភាពរួចហើយ គឺជាបញ្ជីបោះឆ្នោតជាផ្លូវការ មិនអាចកែប្រែបានឡើយ លើកលែងតែមានអ្នកបោះឆ្នោតណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនោះទទួលមរណភាព ។ "***

បទបញ្ញត្តិនៃវាក្យខ័ណ្ឌនេះ មានន័យថា ក្នុងពេលដែលបញ្ជីបោះឆ្នោតត្រូវបានផ្តល់សុពលភាពរួចហើយ បញ្ជីនោះក្លាយជាបញ្ជីបោះឆ្នោតផ្លូវការដែលមិនអាចកែប្រែបានឡើយ លើកលែងតែករណីមានអ្នកបោះឆ្នោតណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការរួចហើយបានទទួលមរណភាព ។

គ/វាក្យខ័ណ្ឌទី៣ បានចែងថា " ***ក្នុងករណីមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទទួលមរណភាព ក្រសួងមហាផ្ទៃត្រូវបំពេញបែបបទ ផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នោះ ក្នុងរយៈពេលប្រាំពីរ ( ០៧ ) ថ្ងៃ យ៉ាងតិចមុនថ្ងៃបោះឆ្នោត ដើម្បីឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជំនួសក្នុងបញ្ជីបោះឆ្នោត ។*** "

បទបញ្ញត្តិនៃវាក្យខ័ណ្ឌនេះ មានន័យថា ក្នុងករណីមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការហើយ ហើយបានទទួលមរណភាព ក្រសួងមហាផ្ទៃត្រូវបំពេញបែបបទធ្វើការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នោះឱ្យបានរួចស្រេច ហើយផ្ញើទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឱ្យបានយ៉ាងតិចប្រាំពីរ (០៧) ថ្ងៃ មុនថ្ងៃបោះឆ្នោត ដើម្បីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជំនួសក្នុងបញ្ជីបោះឆ្នោតផ្លូវការបាន ។

**ចំពោះករណីផ្សេងទៀត មាត្រា ២៥ នេះ មិនអនុញ្ញាតឱ្យធ្វើការផ្លាស់ប្តូរឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឡើយ ។**

- យល់ឃើញថា បទបញ្ញត្តិមាត្រា ១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលចែកជា ២ វាក្យខ័ណ្ឌ ត្រូវបានបកស្រាយដូចខាងក្រោមនេះ ÷

ក/វាក្យខ័ណ្ឌទី១ បានចែងថា " ***សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយក្នុងចំណោមករណីដូចខាងក្រោម :***

- ***សាមីខ្លួនទទួលមរណភាព***
- ***សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច***
- ***សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់***
- ***សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ***
- ***សមាជិកត្រូវបានបណ្តេញចេញដោយប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៨៤ នៃច្បាប់នេះ***
- ***ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលត្រូវរំសាយ***
- ***សាមីខ្លួនត្រូវបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួនហើយ ។*** "

បទបញ្ញត្តិនៃវាក្យខ័ណ្ឌនេះ មានន័យថា សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិ ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ក្នុងករណីណាមួយនៃករណីទាំង ៧ ដូចបានរៀបរាប់ខាងលើ ។

ខ/វាក្យខ័ណ្ឌទី២ បានចែងថា " ***កាលបើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយត្រូវបាត់បង់សមាជិកភាពត្រូវជ្រើសរើសបេក្ខជនបន្ទាប់តាមលេខរៀងក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញឡើយ ។*** "

បទបញ្ញត្តិនៃវាក្យខ័ណ្ឌនេះ មានន័យថា ត្រូវបានជ្រើសរើសបេក្ខជនដែលមានឈ្មោះបន្ទាប់តាមលេខរៀងក្នុងបញ្ជីបេក្ខជនជាមួយ មកជំនួសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវបាត់បង់សមាជិកភាព ដោយមិនបាច់បោះឆ្នោតឡើងវិញឡើយ ។

# **សម្រេច**

**មាត្រា ១.** បទបញ្ញត្តិនៃមាត្រា ២៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ និង មាត្រា ១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

**មាត្រា ២.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៩ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០០៩

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ឧបសម្ព័ន្ធទី៤**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ :១៦៤/០០២/២០០៩

ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៩

**សេចក្តីសម្រេច**

លេខ :១០៥/០០១/២០០៩ កបធ.ច

ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញលិខិតលេខ ១៦៨ លស ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ១៧ និងមាត្រា ១៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៩ វេលាម៉ោង ១៦ និង ៥០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ស្របតាមមាត្រា១៣៦ថ្មី មាត្រា១៤១ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា១៥ថ្មី មាត្រា១៨ថ្មី នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលសំណើសុំបកស្រាយ លេខ ១៦៨ លស ចុះថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី យកមកពិនិត្យបាន
- យល់ឃើញថា បទបញ្ញត្តិនៃមាត្រា ១៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានបកស្រាយថា ទាំងមន្ត្រីរាជការស៊ីវិល ទាំងយោធា ដែលកំពុងបំពេញមុខងារជាសកម្ម គ្មានសិទ្ធិជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាបានទេ មានន័យម្យ៉ាងទៀតថា មន្ត្រីរាជការស៊ីវិល និង យោធា មិនអាចធ្វើការងាររបស់ខ្លួនផង និងជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាផងបានទេ ។ ពាក្យថា **" មន្ត្រីរាជការស៊ីវិល "** រួមមាន មន្ត្រីរាជការក្នុងក្របខណ្ឌនីតិបញ្ញត្តិ ក្របខណ្ឌនីតិប្រតិបត្តិ ក្របខណ្ឌតុលាការ និងក្របខណ្ឌពិសេសផ្សេងទៀត
- យល់ឃើញថា តាមស្មារតីនៃមាត្រា ៣៤ ថ្មី នៃរដ្ឋធម្មនុញ្ញ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ អាចឈរឈ្មោះឱ្យគេបោះឆ្នោត ។ បទបញ្ញត្តិបន្ថយសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត
- យល់ឃើញថា ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ពុំបានហាមឃាត់ដាច់ខាតមិនឱ្យឈរឈ្មោះឱ្យគេបោះឆ្នោតនោះទេ។ ប្រសិនបើមន្ត្រីរាជការស៊ីវិល និងយោធាទាំងនោះ មានបំណងចង់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា សាមីខ្លួនត្រូវតែបំពេញលក្ខខណ្ឌដែលមានចែងក្នុងបទបញ្ញត្តិនៃមាត្រា ១៨ នៃច្បាប់នេះ
- យល់ឃើញថា បទបញ្ញត្តិនៃមាត្រា១៨ ដែលចែកជា ៣ វាក្យខ័ណ្ឌ ត្រូវបានបកស្រាយដូចខាងក្រោមនេះ÷

ក/-បទបញ្ញត្តិនៃវាក្យខ័ណ្ឌទី ១ មានន័យថា ទាំងមន្ត្រីរាជការស៊ីវិល ទាំងយោធា ដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិចប្រាំពីរ (០៧) ថ្ងៃ មុនថ្ងៃបើកការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ ។ ពាក្យថា " **ដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិចប្រាំពីរ(០៧)ថ្ងៃ មុនថ្ងៃបើកការឃោសនាបោះឆ្នោតរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ** " មានន័យថា ដាក់ពាក្យសុំច្បាប់ឈប់សម្រាកពីការងារតែប៉ុណ្ណោះ មិនមែនមានន័យថា ដាក់ពាក្យសុំលាលែងពីមុខងារ ឬពីមុខតំណែងឡើយ ។ បទបញ្ញត្តិនេះមានន័យម្យ៉ាងទៀតថា មន្ត្រីរាជការស៊ីវិល និងយោធាដែលចង់ស្នើជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវសុំការអនុញ្ញាតអវត្តមានពីការងារ ក្នុងរយៈពេលដូចបានកំណត់ខាងលើ ។

ខ/-បទបញ្ញត្តិនៃវាក្យខ័ណ្ឌទី ២ មានន័យថា សាមីខ្លួនជាប់ឆ្នោត ត្រូវធ្វើពាក្យទៅក្រសួង ឬ ស្ថាប័នរបស់ខ្លួន សុំទៅបម្រើការងារក្រៅក្របខ័ណ្ឌដើម ក្នុងរយៈពេលនៃអាណត្តិរបស់ក្រុមប្រឹក្សាតែប៉ុណ្ណោះ ។ ម្យ៉ាងទៀតក្នុងរយៈពេលនៃអាណត្តិនោះ សាមីខ្លួនមានសិទ្ធិឡើងថ្នាក់ ឬ ឋានន្តរសក្តិ និងរក្សាអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍ទៀតផង ។

ប្រសិនបើបេក្ខជនជាប់ឆ្នោតហើយ ហើយគ្មានបំណងចង់នៅបម្រើការងារជាសមាជិកក្រុមប្រឹក្សាទេនោះ សាមីខ្លួនត្រូវធ្វើពាក្យទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីសុំដកបេក្ខភាពរបស់ខ្លួនចេញពីបញ្ជីឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។ ក្នុងករណីនេះ សាមីខ្លួនអាចមកកាន់ការងារដើមរបស់ខ្លួនវិញបាន ។

គ/-បទបញ្ញត្តិនៃវាក្យខ័ណ្ឌទី៣ មានន័យថា នៅពេលចប់អាណត្តិជាសមាជិកក្រុមប្រឹក្សា សាមីខ្លួនអាចត្រឡប់មកបម្រើការងារនៅក្រសួង ឬ ស្ថាប័នដើមរបស់ខ្លួនវិញបាន ប៉ុន្តែសាមីខ្លួននឹងអាចបានទទួលមុខងារ ឬ មុខតំណែងដើមរបស់ខ្លួនវិញបាននោះ គឺអាស្រ័យដោយក្រសួង ឬ ស្ថាប័នជាអ្នកសម្រេច មិនមែនសាមីខ្លួនអាចទទួលមុខងារ ឬ មុខតំណែងដើមរបស់ខ្លួនវិញ ដោយស្វ័យប្រវត្តិនោះឡើយ ។

## សម្រេច

**មាត្រា ១.-** បទបញ្ញត្តិនៃមាត្រា ១៧ និង មាត្រា ១៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩

**ჯ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ឧបសម្ព័ន្ធទី៥**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៨៣/០០៦/២០០៤

ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤

**សេចក្តីសំរេច**

លេខ : ០៦១ /០០៣/២០០៤ កបធ.ច

ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤

**ក្រុមប្រឹក្សាធម្មនុញ្ញ**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិត ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៤ របស់ក្រុមតំណាងរាស្ត្រចំនួន ១៦ រូប សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ក្នុងករណីព្រះមហាក្សត្រដាក់រាជសម្បត្តិ

-បានឃើញឯកសារទទួលពីរដ្ឋសភាទាក់ទងនឹងការពិភាក្សារបស់សភាធម្មនុញ្ញ លើមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ

**ក្រោយពីបានស្តាប់របាយការណ៍សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា តំណាងរាស្ត្រ ១៦ រូប គឺលើសពីមួយភាគដប់នៃចំនួនតំណាងរាស្ត្រនៅរដ្ឋសភា បានធ្វើលិខិតមួយមកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៤ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤ វេលាម៉ោង ១៤ :២៣ នាទី ។ ចំនួន ១៦ រូប នេះ គឺគ្រប់គ្រាន់តាមបទបញ្ញត្តិនៃមាត្រា ១៤១ ថ្មីនៃរដ្ឋធម្មនុញ្ញហើយ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលសំណើសុំបកស្រាយនេះមកពិនិត្យបាន ដោយស្របតាមមាត្រា ១៣៦ ថ្មីនៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៥ មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/ ០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ផងដែរ ។

-យល់ឃើញថា លិខិតតំណាងរាស្ត្រ សុំឱ្យបកស្រាយមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ដោយដាក់ជាបញ្ហា ក្នុងករណីព្រះមហាក្សត្រដាក់រាជសម្បត្តិ " ***ក្រោយពីមានព្រះរាជសាររបស់ព្រះមហាក្សត្រ ស្តីពីព្រះរាជបំណងចង់ដាក់រាជសម្បត្តិជាថ្មីកញ្ចប់នោះមក មានការបកស្រាយខុសៗគ្នា រវាងនាយករដ្ឋមន្ត្រី និង ក្រុមអ្នកច្បាប់មួយចំនួនស្តីពីការដាក់រាជសម្បត្តិនេះ ។*** " ពាក់ព័ន្ធសំខាន់លើវាក្យខ័ណ្ឌទី ២ នៃមាត្រា ៧ នៃរដ្ឋធម្មនុញ្ញដែលចែងថា " ***ព្រះមហាក្សត្រ ទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត*** " ។ ត្រង់នេះ មានន័យថា ព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ និងទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត ។ ព្រះរាជតួនាទី ក្នុងការគ្រងរាជសម្បត្តិ ជាប់ជាមួយព្រះរាជតួនាទី ជាព្រះប្រមុខរដ្ឋ ដោយមិនអាចផ្តាច់ចេញពីគ្នាបានទេ ។ ដូច្នេះ ព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ និង ទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត គឺរជ្ជកាលរបស់ព្រះមហាក្សត្រត្រូវបានកំណត់ចាប់ពីពេលដែលព្រះអង្គឡើងគ្រងរាជសម្បត្តិ រហូតដល់ពេលព្រះអង្គចូលទិវង្គត ។

-យល់ឃើញថា សភាធម្មនុញ្ញបានអនុម័តមាត្រា ១២ មាត្រា ១៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឱ្យមានការជ្រើសតាំងព្រះមហាក្សត្រថ្មី ក្នុងករណីព្រះមហាក្សត្រ សោយទិវង្គតតែប៉ុណ្ណោះ ។

-យល់ឃើញថា ការដាក់រាជសម្បត្តិ មិនមានចែងក្នុងរដ្ឋធម្មនុញ្ញទេ ។

**សំរេច**

**មាត្រា ១.-** មាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ត្រូវបកស្រាយដូចមានបញ្ជាក់ក្នុងមូលបទខាងលើ ។

**មាត្រា ២.-** សេចក្តីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**

**ឧបសម្ព័ន្ធទី៦**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៧៥/០១៩/២០០៣

ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ២០០៣

**សេចក្តីសម្រេច**

លេខ : ០៥៨/០០៩/២០០៣ កបធ.ច

ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០០៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ ០៤៦/០០១/២០០២ កបធ.ច ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០០២ របស់ក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ៤២៧ រស ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០០៣ របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភាបញ្ជូនលិខិតលោក **គល់ បញ្ញា** នាយកប្រតិបត្តិរបស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និង យុត្តិធម៌នៅកម្ពុជា ( COMFREL ) មកក្រុមប្រឹក្សាធម្មនុញ្ញសុំឱ្យធ្វើការបកស្រាយមាត្រា ១២៤ ថ្មី វាក្យខ័ណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំង-តំណាងរាស្ត្រ តាមពាក្យបណ្តឹង លេខ ២៨៧/គ.ប.ស.យ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០០៣ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញទទួលបាននៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ២០០៣

**ក្រោយពីបានស្ដាប់របាយការណ៍សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា តាមមាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៨ នៃព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ពាក្យបណ្ដឹងរបស់សម្ដេចក្រុមព្រះប្រធានរដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកមកពិនិត្យពិភាក្សាបាន
- យល់ឃើញថា មាត្រា ៧៦ វាក្យខ័ណ្ឌទី ៥ នៃរដ្ឋធម្មនុញ្ញ បានបញ្ញត្តិឱ្យច្បាប់បោះឆ្នោតកំណត់អំពី " អង្គការរៀបចំការបោះឆ្នោត បែបបទ និង ការប្រព្រឹត្តទៅនៃការបោះឆ្នោត "
- យល់ឃើញថា តាមការបញ្ជាក់របស់ក្រសួងមហាផ្ទៃ ដែលជាអ្នកតាក់តែងសេចក្ដីព្រាងដើមនៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គំនិតគឺឱ្យ គ.ជ.ប ជាអ្នកធ្វើការពិន័យ
- យល់ឃើញថា តាមកំណត់ហេតុនៃការពិភាក្សានៅរដ្ឋសភានាឆ្នាំ២០០២ និង ឆ្នាំ១៩៩៧ ពុំមានយោបល់សុំកែប្រែគំនិតដើមរបស់សេចក្ដីព្រាងមាត្រា ១២៤ ថ្មី និង មាត្រា ១២៤ ចាស់ លើចំណុចខាងលើនេះទេ
- យល់ឃើញថា មាត្រា ១២៤ ថ្មី វាក្យខ័ណ្ឌទី១ នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានចែងថា " ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតលុបបេក្ខភាពរបស់សាមីខ្លួន ឬ លុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ/ និង ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន ( ៥.០០០.០០០ ) រៀល ទៅម្ភៃប្រាំលាន ( ២៥.០០០.០០០ ) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ... " ។ ក្នុងឃ្លានេះ យោងតាមទឡ្ហីករណ៍ខាងលើ ការពិន័យជាប្រាក់ ក៏ស្ថិតនៅក្នុងសមត្ថកិច្ចរបស់ គ.ជ.ប ដែរ ។

## សម្រេច

**មាត្រា ១ :** មាត្រា ១២៤ ថ្មី វាក្យខ័ណ្ឌទី១ នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបកស្រាយដូចមានក្នុងមូលបទខាងលើ ។

**មាត្រា ២ :** សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០០៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ហត្ថលេខា និង ត្រា**

**ប៊ិន ឈិន**

**ឧបសម្ព័ន្ធទី៧**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៦៩/០១៣/២០០៣

ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៣

**សេចក្តីសម្រេច**

លេខ : ០៥៤/០០៥/២០០៣ កបធ.ច

ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០០៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨ /០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញលិខិតរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ០៩/០៣ កបធ.សជណ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០០៣
- បានឃើញលិខិតរបស់តំណាងរាស្ត្រចំនួន ១៨រូប ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៣ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយបំភ្លឺលើខ្លឹមសារវាក្យខ័ណ្ឌទី១ មាត្រា ៧៦ និង មាត្រា ៩៥ ជំពូកទី៧ នៃរដ្ឋធម្មនុញ្ញ ថាតើចំពោះមុខស្ថានភាពខាងលើនេះ ការប្រជុំពេញអង្គជាសាមញ្ញ ឬ ជាវិសាមញ្ញរបស់រដ្ឋសភានឹងអាចប្រព្រឹត្តទៅបានរហូតដល់រដ្ឋសភាថ្មីចូលកាន់តំណែង ស្របតាមរដ្ឋធម្មនុញ្ញដែរឬទេ ?

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា តំណាងរាស្ត្រចំនួន ១៨ នាក់ គឺលើសពីមួយភាគដប់ ( ១៣រូប ) នៃចំនួនតំណាងរាស្ត្រ នៅរដ្ឋសភាបានធ្វើលិខិតមួយមកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ២០០៣ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយវាក្យខ័ណ្ឌទី១ មាត្រា ៧៦ និង មាត្រា ៩៥ ជំពូកទី៧ នៃរដ្ឋធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៣ នៅវេលាម៉ោង ១០ ព្រឹក ។ ចំនួន ១៨ នាក់នេះ គ្រប់គ្រាន់តាមបទប្បញ្ញត្តិនៃមាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលសំណើសុំបកស្រាយនេះមកពិនិត្យបាន ដោយស្របតាមមាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ និង មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ផងដែរ ។
- យល់ឃើញថា លិខិតតំណាងរាស្ត្រ សុំឱ្យបកស្រាយបំភ្លឺនូវខ្លឹមសារវាក្យខ័ណ្ឌទី១ មាត្រា ៧៦ និង មាត្រា ៩៥ នៃរដ្ឋធម្មនុញ្ញក្នុងបរិបទនៃសំណួរមួយដែលសួរថា ចំពោះមុខស្ថានភាពនេះ តើការប្រជុំពេញអង្គជាសាមញ្ញ ឬ ជាវិសាមញ្ញរបស់រដ្ឋសភានឹងអាចប្រព្រឹត្តទៅបានរហូតដល់រដ្ឋសភាថ្មីចូលកាន់តំណែង ស្របតាមរដ្ឋធម្មនុញ្ញដែរឬទេ ?
- យល់ឃើញថា ចំពោះសំណួរនេះ បញ្ហានឹងកើតមានឡើងតែក្នុងករណីដែលគ្មានការជ្រើសតាំង អ្នកតំណាងរាស្ត្រថ្មីជំនួសអ្នកតំណាងរាស្ត្រដែលទទួលអនិច្ចកម្ម លាលែង ឬ ប្រាសចាក សមាជិកភាពរដ្ឋសភា ហើយដែលចំនួនតំណាងរាស្ត្ររដ្ឋសភាទាំងអស់ត្រូវចុះថយនៅសល់តិចជាង ១២០ រូបប៉ុណ្ណោះ ។ ក្នុងបរិបទនេះនេះ ក្រុមប្រឹក្សាធម្មនុញ្ញសូមធ្វើការបកស្រាយដូចតទៅ :

**១-វាក្យខ័ណ្ឌទី១ មាត្រា ៧៦ នៃរដ្ឋធម្មនុញ្ញ**

វាក្យខ័ណ្ឌទី ១ នៃមាត្រា ៧៦ នៃរដ្ឋធម្មនុញ្ញ ចែងថា : រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០ រូប ។ ត្រង់នេះមានន័យថា យ៉ាងតិចណាស់ត្រូវមានសមាជិកជាតំណាងរាស្ត្រចំនួន ១២០រូប ទើបអាចបង្កើតរដ្ឋសភាក្នុងនីតិកាលនីមួយៗបាន ។ ច្បាប់បោះឆ្នោតមិនអាចកំណត់ចំនួនតំណាងរាស្ត្រតិចជាង ១២០រូប បានទេ ។ វាក្យខ័ណ្ឌទី១ នេះជាល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ការបង្កើតរដ្ឋសភា ប៉ុន្តែមិនមែនសម្រាប់ដំណើរការរបស់រដ្ឋសភាទេ ។

នៅពេលបោះឆ្នោតចប់ហើយ លទ្ធផលត្រូវឱ្យបានតំណាងរាស្ត្រចាប់ពី ១២០រូប ឡើងទៅ ទៅតាមការកំណត់នៃច្បាប់បោះឆ្នោត ទើបអាចបង្កើតរដ្ឋសភានីតិកាលថ្មីមួយបាន ដោយគោរពទៅតាមនីតិវិធីដែល

មានចែងក្នុងមាត្រា ៨២ នៃរដ្ឋធម្មនុញ្ញ និង ប្រការ ៣ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ។ គឺថា រដ្ឋសភាដែលកើតចេញពីការបោះឆ្នោត ត្រូវចូលកាន់តំណែងជាផ្លូវការនៅពេលសម័យប្រជុំដំបូង តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ហើយនឹងមានការប្រកាសសម្រេចសុពលភាពឈ្មោះអ្នកតំណាងរាស្ត្របិទផ្សាយក្នុងមន្ទីររដ្ឋសភា និង ជាសាធារណៈ ។ ចាប់ពីពេលនេះមក រដ្ឋសភានឹងមានសុពលភាពរហូតដល់ចប់អាណត្តិរបស់ខ្លួនក្នុងករណីធម្មតា លើកលែងតែក្នុងករណីពិសេសនៃការរំលាយរដ្ឋសភាដោយមកពីមានការទម្លាក់រាជរដ្ឋាភិបាលពីរដងក្នុងរយៈពេល ១២ ខែ ដូចមានចែងក្នុងមាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញ ។ ហេតុដូច្នេះហើយ ទើបមាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញចែងថា " រដ្ឋសភាមិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ ... " ។

ការវិភាគខាងលើនេះ បង្ហាញឱ្យឃើញថាការប្រែប្រួលនៃចំនួនតំណាងរាស្ត្រ ក្នុងរយៈវេលានៃការប្រព្រឹត្តទៅនៃនីតិកាល មិនអាចធ្វើឱ្យប៉ះពាល់ដល់សុពលភាពរដ្ឋសភាទាំងមូលបានឡើយ ។ ដូច្នេះទោះបីចំនួនតំណាងរាស្ត្រប្រែប្រួលចុះថយក្រោម ១២០រូប យ៉ាងណាក៏ដោយ កុំឱ្យតែទាបជាងកូរ៉ុមប្រាំពីរភាគដប់នៃសមាជិករដ្ឋសភាទាំងមូល ក៏រដ្ឋសភានៅតែអាចដំណើរការបានដូចធម្មតា ហើយជាពិសេសការប្រជុំពេញអង្គជាសាមញ្ញ ឬ ជាវិសាមញ្ញក៏អាចនឹងប្រព្រឹត្តទៅបានរហូតដល់រដ្ឋសភាថ្មីចូលកាន់តំណែង ដោយពុំមានអ្វីខុសនឹងរដ្ឋធម្មនុញ្ញឡើយ ។

**២_មាត្រា ៩៥ នៃរដ្ឋធម្មនុញ្ញ**

មាត្រា ៩៥ នេះ ចែងថា : ក្នុងករណីមានសមាជិករដ្ឋសភាទទួលអនិច្ចកម្ម លាលែង ឬ ប្រាសចាកសមាជិកភាពដែលកើតមានឡើង ៦ ខែយ៉ាងតិចមុនចប់នីតិកាលត្រូវចាត់ការជ្រើសតាំងជំនួសសមាជិកនោះតាមល័ក្ខខ័ណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និង ក្នុងច្បាប់បោះឆ្នោត ។

ក្នុងបរិបទនៃសំណួររបស់អ្នកតំណាងរាស្ត្រទាំង ១៨ នាក់នោះ ការបកស្រាយមាត្រា ៩៥ នេះសំដៅតែទៅលើបញ្ហានៃការចាត់ការជ្រើសតាំងសមាជិកជំនួស និង រយៈពេល ៦ ខែ មុនចប់នីតិកាល ។ ដូច្នេះចំណុចផ្សេងៗទៀតនៃមាត្រា ៩៥ នឹងមិនត្រូវលើកយកមកពិនិត្យក្នុងទីនេះទេ ។

មានពីរករណីដែលត្រូវវែកញែក គឺ :

<u>ករណីទី១</u> : បើនីតិកាលនៅយូរជាង ៦ ខែ ឬ ស្មើនឹង ៦ ខែ ត្រូវមានការជ្រើសតាំងសមាជិកជំនួសតាមនីតិវិធីដែលមានចែងក្នុងច្បាប់បោះឆ្នោត ឧទាហរណ៍ដូចសព្វថ្ងៃនេះគឺមាត្រា ១២០ នៃច្បាប់បោះឆ្នោតជ្រើសតាំង-តំណាងរាស្ត្រ ។ តាមមាត្រា ១២០ នេះសាមីគណបក្សនយោបាយអាចស្នើជ្រើសតាំងសមាជិកថ្មីជំនួសដោយជ្រើសរើសក្នុងចំណោមបេក្ខជន ដែលមានឈ្មោះតាមលេខរៀងក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះ-ឆ្នោតនៃមណ្ឌលរបស់សាមីខ្លួននោះមកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញ ។ សាមីគណបក្ស

នយោបាយ ជាចាំបាច់ ត្រូវតែស្នើជ្រើសតាំងសមាជិកថ្មីជំនួស ទើបស្របនឹងមាត្រា ៩៥ នៃរដ្ឋធម្មនុញ្ញ ដែលបានចែងច្បាស់ថា " ត្រូវចាត់ការជ្រើសតាំងជំនួស ... " ។

ករណីទី២ : បើនីតិកាលនៅសល់តិចជាង ៦ ខែ ថ្វីបើមាត្រា ៩៥ នៃរដ្ឋធម្មនុញ្ញ និង ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រមិនបានបញ្ជាក់ក៏ដោយប៉ុន្តែតាមខ្លឹមសារ គឺមិនត្រូវមានការជ្រើសតាំងសមាជិកថ្មីជំនួសទេ ។

- យល់ឃើញថា ទោះក្នុងករណីណាក៏ដោយ លើកលែងតែចំនួនតំណាងរាស្ត្រនៅសល់តិចជាងកូរ៉ុមប្រាំពីរភាគដប់នៃសមាជិករដ្ឋសភាទាំងមូល ការប្រជុំពេញអង្គជាសាមញ្ញ ឬ ជាវិសាមញ្ញរបស់រដ្ឋសភានឹងអាចប្រព្រឹត្តទៅបានជានិច្ច រហូតដល់រដ្ឋសភាថ្មីចូលកាន់តំណែង ដោយឥតខុសនឹងរដ្ឋធម្មនុញ្ញឡើយ ។

## សម្រេច

**មាត្រា ១** : វាក្យខ័ណ្ឌទី១ មាត្រា ៧៦ និង មាត្រា ៩៥ នៃរដ្ឋធម្មនុញ្ញ និង សុពលភាពនៃការប្រជុំពេញអង្គ ជាសាមញ្ញ ឬ ជាវិសាមញ្ញរបស់រដ្ឋសភាត្រូវបកស្រាយដូចមានបញ្ជាក់ក្នុងមូលបទខាងលើ ។

**មាត្រា ២** : សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និងជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០០៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ហត្ថលេខា និង ត្រា**

**ប៊ិន ឈិន**